ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.



# របាយការណ៍ ប្រចាំឆ្នាំ ២០២៣





# មាតិកា

* * *

**អារម្ភកថា**......i
**អក្សរកាត់**......v
**ខ្លឹមសារសង្ខេប**......x
**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០២៣**
I- **ស្ថានភាពសេដ្ឋកិច្ចពិភពលោក**......១
II- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**......៥
១- កំណើនសេដ្ឋកិច្ច......៥
២- ស្ថានភាពអតិផរណា......១០
៣- អត្រាប្តូរប្រាក់......១២
៤- ស្ថានភាពជញ្ជីងទូទាត់......១៤
៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ......១៧
៦- សន្និដ្ឋាន......១៧
III- **ការគ្រប់គ្រងរូបិយវត្ថុ**......១៨
១- ស្ថានភាពរូបិយវត្ថុ......១៨
២- ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់......១៨
៣- អត្រាប្រាក់បម្រុងកាតព្វកិច្ច......២០
៤- មូលបត្រអាចជួញដូរបាន......២១
៥- ការបោះផ្សាយមូលបត្ររដ្ឋ......២២
៦- ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា......២៣
៧- ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី......២៤
៨- សន្និដ្ឋាន......២៥
IV- **ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា**......២៦
១- ស្ថានភាពទូទៅ......២៦
២- វិស័យធនាគារ......២៨
៣- វិស័យមីក្រូហិរញ្ញវត្ថុ......២៩
៤- គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ......៣១
៥- គ្រឹះស្ថានឥណទានជនបទ......៣១
៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន......៣២
៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ......៣៤
៨- ការងាររៀបចំបទប្បញ្ញត្តិ......៣៥

៩- ការរួមចំណែករបស់ប្រព័ន្ធធនាគារក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ... ៣៦
១០-ការងារបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ........ ៣៧
១១-កិច្ចសហការបញ្ជូនព័ត៌មាន ........ ៣៨
១២-សន្និដ្ឋាន ........ ៣៨
V- **ការផ្គត់ផ្គង់សេវាធនាគារកណ្ដាល** ........ ៣៩
១- ប្រព័ន្ធទូទាត់សងប្រាក់ ........ ៣៩
២- សេវាគ្រប់គ្រងគណនី ........ ៤៨
៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ........ ៤៩
៤- សន្និដ្ឋាន ........ ៥០
VI- **ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** ........ ៥១
១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ៥២
២- ការងារវិភាគ និងបញ្ជូនរបាយការណ៍ ........ ៥២
៣- កិច្ចសហប្រតិបត្តិការ ........ ៥៣
៤- ការបណ្ដុះបណ្ដាលនិងនីតិកម្ម ........ ៥៥
៥- សន្និដ្ឋាន ........ ៥៦
VII- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** ........ ៥៧
១- កិច្ចសហប្រតិបត្តិការពហុភាគី ........ ៥៧
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ........ ៦៧
៣- សន្និដ្ឋាន ........ ៧១
VIII- **ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា** ........ ៧២
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ........ ៧២
២- ការអភិវឌ្ឍធនធានមនុស្ស ........ ៧៤
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........ ៧៨
៤- សាខាធនាគារជាតិនៃកម្ពុជា ........ ៨០
៥- សន្និដ្ឋាន ........ ៨០
IX- **ការងារផ្សព្វផ្សាយសាធារណៈ** ........ ៨១
១- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល ........ ៨១
២- ការអនុវត្តការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ........ ៨៣
៣- ការអនុវត្តតាមទីផ្សារ និងយន្តការនៃកិច្ចការពារអ្នកប្រើប្រាស់ ........ ៨៨
៤- ប្រព័ន្ធបាគង ........ ៩០

៥- សារមន្ទីរព្រះស្រីឮសានវង្សែ ........................................ ៩២

៦- សន្និដ្ឋាន ........................................ ៩៤

**សេចក្តីសន្និដ្ឋាន** ........................................ ៩៥

**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៤**

១- ការអនុវត្តនយោបាយរូបិយវត្ថុ ........................................ ១០១

២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........................................ ១០១

៣- ប្រព័ន្ធទូទាត់សងប្រាក់ ........................................ ១០១

៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................ ១០២

៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........................................ ១០២

៦- ការងារប្រតិបត្តិការ ........................................ ១០៣

៧- ការងារបោះផ្សាយនិងឃ្លាំងបេឡា ........................................ ១០៣

៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........................................ ១០៣

៩- ការគ្រប់គ្រងសាខា ........................................ ១០៤

១០- គណនេយ្យ ........................................ ១០៤

១១- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស ........................................ ១០៤

១២- កិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................ ១០៤

១៣- ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ........................................ ១០៥

១៤- ការងារស្ថិតិ ........................................ ១០៥

១៥- ការងារសារមន្ទីរ ស.ស.រ. ........................................ ១០៦

**ផ្នែកទី៣ - ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ តារាង ១ -ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........................................ ១០៧

ឧបសម្ព័ន្ធ ២ តារាង ២ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ) .. ១០៨

ឧបសម្ព័ន្ធ ៣ តារាង ៣ -ស្ថិតិស្ថានភាពធនាគារកណ្តាល ........................................ ១០៩

ឧបសម្ព័ន្ធ ៤ តារាង ៤ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត ........................................ ១១០

ឧបសម្ព័ន្ធ ៥ តារាង ៥ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ ........................................ ១១១

ឧបសម្ព័ន្ធ ៦ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ........................................ ១១២

ឧបសម្ព័ន្ធ ៧ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ ........................................ ១១៣

ឧបសម្ព័ន្ធ ៨ តារាង ៨ -ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ........................................ ១១៤

ឧបសម្ព័ន្ធ ៩ តារាង ៩ -សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ........................................ ១១៥

ឧបសម្ព័ន្ធ ១០ តារាង ១០ -ជញ្ជីងទូទាត់ប្រទេសកម្ពុជា ........................................ ១១៦

ឧបសម្ព័ន្ធ ១១ តារាង ១១ -បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
ពីឆ្នាំ២០១៧ - កញ្ញា ២០២៣ ........................................ ១១៧

ឧបសម្ព័ន្ធ ១២ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹង
ការប្រើប្រាស់សេវាហិរញ្ញវត្ថុ ........................................ ១១៩

# អារម្ភកថា

នាឆ្នាំ២០២៣នេះ សេដ្ឋកិច្ចពិភពលោកបានឆ្លងកាត់ឧបសគ្គជាបន្តបន្ទាប់ក្រោយពីបានងើបឡើងវិញពីវិបត្តិកូវីដ-១៩។ ការបន្តដំឡើងអត្រាការប្រាក់គោលដើម្បីកាត់បន្ថយអតិផរណា ការរួមតូចនៃលំហនយោបាយសារពើពន្ធ ការកើនឡើងហានិភ័យនៃការបែងចែកភូមិសាស្ត្រនយោបាយ និងវិបត្តិអចលនទ្រព្យនិងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុកនៅប្រទេសចិន បានដាក់បន្ទុកដល់ពាណិជ្ជកម្ម ការប្រើប្រាស់ និងការវិនិយោគសកល។ ក្នុងស្ថានភាពនេះ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថាអាចសម្រេចបានទាបជាងឆ្នាំ២០២២។

ការថមថយកំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់ បានដាក់សម្ពាធដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេសការនាំចេញផលិតផលកាត់ដេរ និងកំណើនវិស័យសំណង់និងអចលនទ្រព្យ។ ប៉ុន្តែ ការងើបឡើងនៃវិស័យទេសចរណ៍ កំណើនការនាំចេញផលិតផលមិនមែនកាត់ដេរ និងកំណើនតម្រូវការក្នុងស្រុក បានរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជាឱ្យកើនឡើងក្នុងអត្រា ៥,៥% ខ្ពស់ជាងឆ្នាំ២០២២បន្តិច (៥,៣%)។ ការសម្រេចបានកំណើននេះ កើតឡើងដោយសារមានការគាំទ្រមិនអាចខ្វះបាននូវស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿទុកចិត្តនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ រាជរដ្ឋាភិបាលអាណត្តិថ្មីដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ជាប្រមុខ បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលមានគោលដៅច្បាស់លាស់និងទស្សនវិស័យវែងឆ្ងាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដោយផ្តោតលើអាទិភាពគន្លឹះចំនួន៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

ស្ថិរភាពថ្លៃបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ នាឆ្នាំ២០២៣ អតិផរណាបានថមថយមកក្នុងកម្រិតទាបវិញ ដោយសារការថយចុះនៃថ្លៃប្រេងឥន្ធនៈនិងម្ហូបអាហារ ជាមួយនឹងការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ និងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតមួយសមស្រប។ តម្លៃប្រាក់រៀលបានរងសម្ពាធថយថ្លៃ ដែលមួយផ្នែកដោយសារការថយល្បឿននៃលំហូរចូលសុទ្ធនៃប្រាក់ដុល្លារអាមេរិក និងកំណើនចំណាយសាធារណៈ។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ដោយដេញថ្លៃលក់ប្រាក់ដុល្លារអាមេរិក និងបានស្រូបយកប្រាក់រៀលដែលកំពុងចរាចរណ៍នៅក្នុងសេដ្ឋកិច្ច ហើយជាលទ្ធផលបានធ្វើឱ្យអត្រាប្តូរប្រាក់រៀលបន្តមានស្ថិរភាពល្អ។

ក្នុងបរិការណ៍ដែលទីផ្សារហិរញ្ញវត្ថុអន្តរជាតិប្រឈមនឹងភាពមិនច្បាស់លាស់ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន ហើយបានគរពូនឱ្យមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន និងបម្រើដល់ការអនុវត្តនយោបាយរូបិយវត្ថុ។ ទោះយ៉ាងណាកម្រិតខ្ពស់នៃដុល្លារូបនីយកម្មបានដាក់កំហិតដល់ប្រសិទ្ធភាពនៃការអនុវត្តនយោបាយរូបិយវត្ថុ និងធ្វើឱ្យកម្ពុជាងាយរងគ្រោះនឹងវិបត្តិ ដែលទាមទារការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ទន្ទឹមនេះ ក្របខ័ណ្ឌនយោបាយរូបិយវត្ថុនឹងត្រូវពង្រឹង តាមរយៈការបង្កើតឱ្យមានអត្រាការប្រាក់គោលរបស់ធនាគារកណ្តាល ដើម្បីតម្រង់ទិសដល់ការប្រែប្រួលអត្រាការប្រាក់នៅលើទីផ្សារ។

ទំនុកចិត្តមកលើប្រព័ន្ធធនាគារកម្ពុជាបន្តមានភាពរឹងមាំ បើទោះបីជាឆ្នាំ២០២៣ជាឆ្នាំនៃការបោះឆ្នោត ហើយប្រព័ន្ធធនាគារនៅក្នុងប្រទេសមួយចំនួនបានរងការប៉ះទង្គិចដោយការដួលរលំ

នៃគ្រឹះស្ថានធនាគារពាណិជ្ជក៏ដោយ។ ប៉ុន្តែ ការងើបឡើងទន់ខ្សោយនៃវិស័យមួយចំនួនបានបណ្តាលឱ្យកំណើនឥណទានថយចុះមកនៅអត្រាមួយខ្ទង់ជាលើកដំបូងក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ។ ការថយចុះកំណើនឥណទាន គួបផ្សំនឹងការបញ្ចប់ការរៀបចំឥណទានឡើងវិញក្នុងអំឡុងវិបត្តិកូវីដ-១៩ បានបណ្តាលឱ្យអនុបាតឥណទានមិនដំណើរការកើនឡើង ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តបង្កើនការតាមដាន វាយតម្លៃ និងធ្វើស្រ្តេសតេស្តជាប់ជាប្រចាំលើហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

ធនាគារជាតិនៃកម្ពុជាបានពង្រឹងក្របខ័ណ្ឌការពារហានិភ័យ ជាពិសេសការចេញប្រកាសកែសម្រួលការវាយតម្លៃហានិភ័យឥណទាន ស្របពេលដែលស្តង់ដាកិច្ចសន្យាឥណទាននិងការកំណត់ខចែងស្តង់ដានៃកិច្ចសន្យាឥណទាន ត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីធានាពីសិទ្ធិនិងអត្ថប្រយោជន៍របស់អតិថិជន និងផ្តល់ការប្រកួតប្រជែងដោយយុត្តិធម៌និងសមភាព។ ដើម្បីជួយរក្សាសន្ទនីយភាពខ្ពស់នៃប្រព័ន្ធធនាគារ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ច ការអនុគ្រោះផ្នែកបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តផងដែរ ដូចជា ការបន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើរវេសិនត្រឹម ១,២៥% ការបន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចចំពោះប្រាក់បញ្ញើនិងការខ្ចីពីបរទេសជារូបិយប័ណ្ណមក ៧% និងការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញចំពោះអតិថិជនពាក់ព័ន្ធនឹងវិស័យទេសចរណ៍នៅខេត្តសៀមរាប។

ស្របតាមការវិវត្តរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចាប់យកឱកាសក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ ដើម្បីធ្វើជាមុខព្រួញរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល តាមរយៈការបង្កើតប្រព័ន្ធបាគង ស្តង់ដាខេអេចឃ្យូអរ (KHQR) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ជាដើម។ បច្ចុប្បន្ន ប្រព័ន្ធទូទាត់កម្ពុជាកំពុងរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការដោះដូរ និងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការធ្វើឱ្យការទូទាត់កាន់តែមានភាពងាយស្រួល សុវត្ថិភាព ចំណាយទាប និងអាចធ្វើប្រតិបត្តិការឆ្លងពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយបានដោយប្រសិទ្ធភាព។ ទោះយ៉ាងណា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបង្កើនការវិនិយោគទៅលើប្រព័ន្ធការពារសុវត្ថិភាពបច្ចេកវិទ្យា ដើម្បីធានាដំណើរការដោយពិលាស់នៃសេវាហិរញ្ញវត្ថុឌីជីថលនិងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ ខណៈដែលអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលត្រូវមានការប្រុងប្រយ័ត្នខ្ពស់ផងដែរ។ លើសពីនេះ ប្រព័ន្ធទូទាត់កម្ពុជាត្រូវបានបង្កើនការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងប្រព័ន្ធទូទាត់អន្តរជាតិជាលំដាប់ ដែលផ្តល់លទ្ធភាពកាន់តែទូលំទូលាយក្នុងការទូទាត់ដល់ប្រជាជនកម្ពុជា និងទេសចរអន្តរជាតិ។

ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់លើការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព តាមរយៈការបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាព ការគាំទ្រការអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការចូលរួមបង្កើតប្រព័ន្ធវគ្គីករសាស្ត្រសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាព និងការពង្រឹងកិច្ចសហការនានាជាមួយស្ថាប័នទាំងក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិលើការជំរុញការផ្តល់ហិរញ្ញប្បទានបៃតង។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិមួយផ្នែកក៏ត្រូវបានវិនិយោគលើសញ្ញាប័ណ្ណបៃតងផងដែរ ដែលបានធ្វើឱ្យធនាគារជាតិនៃកម្ពុជាជាធនាគារកណ្តាលឈានមុខមួយក្នុងតំបន់ ក្នុងការជំរុញហិរញ្ញប្បទានបៃតង។ នៅចំពោះមុខ

គំនិតផ្តួចផ្តើមសំខាន់ៗជាច្រើនទៀតនឹងត្រូវអនុវត្ត ក្នុងគោលដៅបង្កើតឱ្យមានយន្តការគាំទ្រ និងប្រព័ន្ធអេកូឡូស៊ីចាំបាច់ ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព។

ឥទ្ធិពលនៃភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ និងភាពមិនប្រាកដប្រជានៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិ បានប៉ះពាល់ដល់និម្មាបនកម្មហិរញ្ញវត្ថុពិភពលោក ដែលទាមទារការពង្រឹងបន្ថែមនូវសមាហរណកម្មនិងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់។ ក្នុងស្ថានភាពនេះ កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាល អាជ្ញាធររូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ត្រូវបានបន្តពង្រឹងកាន់តែស៊ីជម្រៅ ទាំងក្នុងក្របខ័ណ្ឌតំបន់និងពិភពលោក ដើម្បីពង្រឹងភាពធន់និងបង្កើនវិសាលភាពនៃការរីកចម្រើនប្រព័ន្ធធនាគារ។ ក្នុងនាមជាប្រធានប្តូរវេនឆ្នាំ២០២៣ នៃក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន (BOG) ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាល ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការកសាងសមត្ថភាពជំនាញរបស់មន្ត្រីធនាគារកណ្តាលក្នុងតំបន់។

ដោយឡែក ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គឺជាការងារអាទិភាពមួយរបស់រាជរដ្ឋាភិបាល សំដៅរួមចំណែកការពារនិងពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ឱ្យកាន់តែមានភាពរឹងមាំនិងមានជំនឿទុកចិត្តពីសាធារណជន ទាំងវិនិយោគិនក្នុងនិងក្រៅប្រទេស។ ក្នុងស្មារតីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបាននិងកំពុងបំពេញភារកិច្ចស្នូលរបស់ខ្លួន ក្នុងការពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ស្តីពី ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការត្រួតពិនិត្យបុគ្គលរាយការណ៍ ការទទួលនិងវិភាគរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់និងរបាយការណ៍ប្រតិបត្តិការសង្ស័យ និងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ។ លើសពីនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមសមត្ថកិច្ចរៀងៗខ្លួនរហូតសម្រេចបានលទ្ធផលនៃការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) កាលពីខែកុម្ភៈ ឆ្នាំ២០២៣ ព្រមទាំងបន្តអនុវត្តការងារដ៏មានសារៈសំខាន់នេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

នាឆ្នាំ២០២៤ ខាងមុខ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងបន្តកើនក្នុងអត្រា ៦,៤% ខ្ពស់ជាងឆ្នាំ២០២៣ ថែមទៀត ដែលគាំទ្រដោយការបន្តងើបឡើងនៃវិស័យទេសចរណ៍ ការកើនឡើងវិញនៃការនាំចេញវិស័យកាត់ដេរ និងកំណើនខ្ពស់នៃការនាំចេញវិស័យមិនមែនកាត់ដេរ។ ប៉ុន្តែ ក្នុងស្ថានភាពដែលកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថាបន្តថយចុះបន្តិច ការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជាក៏អាចប្រឈមនឹងហានិភ័យមួយចំនួន ជាពិសេសកំណើនយឺតនៅបណ្តាប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ដែលអាចប៉ះពាល់ដល់ការនាំចេញ ការវិនិយោគ និងទេសចរមកកម្ពុជា, ភាពមិនប្រាកដប្រជានៅលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ដោយសារការដំឡើងអត្រាការប្រាក់គោលនិងការបែងចែកភូមិសាស្ត្រនយោបាយ ដែលអាចដាក់សម្ពាធលើលំហូរទុនមកកម្ពុជា និងការកើនឡើងនៃឧក្រិដ្ឋកម្មសាយប័រ ដែលអាចប៉ះពាល់ដល់ជំនឿទុកចិត្តរបស់សាធារណជនមកលើសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឌីជីថល។ ចំពោះហានិភ័យខាងក្នុង សេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ កម្រិតខ្ពស់នៃបំណុលក្នុងវិស័យឯកជន និងការងាយរងគ្រោះនឹងអាកាសធាតុនៃវិស័យកសិកម្ម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

**ទេសាភិបាល**

**ជា សិរី**

# អក្សរកាត់

| | | |
|---|---|---|
| ក.ប.ស.ហ. | ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | Inter-Ministerial Technical Working Group on Anti-Money Laundering and Terrorist Financing |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.វ.ហ | អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | National Risk Assessment Sub-Committee for Combating Money Laundering and Countering Financing Terrorism and Financing of Proliferation |
| ABC | សមាគមធនាគារនៅកម្ពុជា | The Association of Banks in Cambodia |
| ACGM | កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Central Bank Governor' Meeting |
| ADA | អង្គការទ្រទ្រង់ការអភិវឌ្ឍន៍ស្វ័យភាព | Appui au Développement Autonome |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFI | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| AFMGM | កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Finance Ministers' and Central Bank Governors' Meeting |
| AFTN | បណ្តាញអ្នកវិភាគហិរញ្ញវត្ថុអាស៊ាន+៣ | ASEAN+3 Finance Think-tank Network |
| AI | បញ្ញាសិប្បនិម្មិត | Artificial Intelligence |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | The ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |

| | | |
|---|---|---|
| Bakong LVPS | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |
| BIN | លេខអត្តសញ្ញាណធនាគារ | Bank Identification Number |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| SEACEN - BOG | ក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន | SEACEN Board of Governors |
| BOK-KPP | កម្មវិធីស្រាវជ្រាវរួមគ្នាជាមួយធនាគារកណ្ដាលកូរ៉េ | Bank of Korea-Knowledge Partnership Program |
| CBS | មណ្ឌលសិក្សាបច្ចេកទេសធនាគារ | Center for Banking Studies |
| CGAP | ក្រុមប្រឹក្សាយោបល់សម្រាប់ជួយដល់ជនក្រីក្រ | Consultative Group to Assist the Poor |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា | Cambodia Microfinance Association |
| CMIM | ពហុនីយកម្មគំនិតផ្ដួចផ្ដើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CSS | ប្រព័ន្ធខេមបូឌានស៊ែស្វីច | Cambodian Shared Switch |
| CUFA | អង្គការសហជីពឥណទានមូលនិធិអូស្ត្រាលី | Credit Union Foundation Australia |
| CWPD | នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ | Cambodian Women for Peace and Development |
| DAP | ក្រុមអ្នកផ្ដល់ជំនួយបច្ចេកទេស | Donor and Providers Group |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social, and Governance |
| ENEER | អត្រាប្ដូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្ដូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |
| EXCO | គណៈកម្មាធិការប្រតិបត្តិ | Executive Committee |
| FAST | ប្រព័ន្ធសេវាទូទាត់រហ័ស | Fast System |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |

| | | |
|---|---|---|
| FICG | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| FTC | កូរីដ័រតម្លាភាពហិរញ្ញវត្ថុ | Financial Transparency Corridor |
| Full KYC | អត្តសញ្ញាណពេញលេញ | Full Know Your Customer |
| FUR | របាយការណ៍វឌ្ឍនភាព | Follow-Up Reports |
| IADI | សមាគមអន្តរជាតិសម្រាប់ធានាប្រាក់បញ្ញើ | International Association of Deposit Insurers |
| IBF | វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ | Institute of Banking and Finance |
| ICRG-JG | ក្រុមការងារត្រួតពិនិត្យរួមគ្នានៃប្រទេសអាស៊ី-ប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ | International Cooperation Review Group- Joint Group |
| ICOM | គណៈកម្មាធិការសារមន្ទីររូបិយវត្ថុ របស់ក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ | International Council of Museums |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| IGFWG | ក្រុមការងារបរិយាបន្នហិរញ្ញវត្ថុបៃតង | Inclusive Green Finance Working Group |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| KDIC | សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ | Korea Deposit Insurance Corporation |
| LDCs | ប្រទេសអភិវឌ្ឍន៍តិចតួច | Least Developed Countries |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |

| | | |
|---|---|---|
| MEC | គណៈកម្មការវាយតម្លៃអញ្ញមញ្ញ | Mutual Evaluation Committee |
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| NBCP | ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NCS | ប្រព័ន្ធផាត់ទាត់ជាតិ | National Clearing System |
| NGFS | បណ្តាញធនាគារកណ្តាលនិងអាជ្ញាធរត្រួតពិនិត្យសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង | Network of Central Banks and Supervisors for Greening the Financial System |
| NPCI | សាជីវកម្មទូទាត់ជាតិនៃប្រទេសឥណ្ឌា | National Payments Corporation of India |
| NRA | ការវាយតម្លៃហានិភ័យថ្នាក់ជាតិ | National Risk Assessment |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| OD | ឥណទានវិបារូបន៍ | Overdraft |
| PAGE | ភាពជាដៃគូសម្រាប់សកម្មភាពសេដ្ឋកិច្ចបៃតងរបស់អង្គការសហប្រជាជាតិ | UN Partnership for Action on Green Economy |
| PETs | បច្ចេកវិទ្យាការពារការសម្ងាត់នៃព័ត៌មានឯកជន | Privacy Enhancing Technologies |
| POS | ម៉ាស៊ីនឆូតកាត | Point of Sale |
| RCEP | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ | Regional Comprehensive Economic Partnership |
| RKH | មជ្ឈមណ្ឌលចំណេះដឹងក្នុងតំបន់ | Regional Knowledge Hub |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SCCB | គណៈកម្មាធិការកសាងសមត្ថភាពអាស៊ាន | Steering Committee for Capacity Building |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| SEAVG | ក្រុមការងារមណ្ឌលបោះឆ្នោតប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃមូលនិធិរូបិយវត្ថុអន្តរជាតិ | Southeast Asia Voting Group |

| | | |
|---|---|---|
| SLC | គណៈកម្មាធិការជាន់ខ្ពស់ | Senior-Level Committee |
| SMEs | សហគ្រាសធុនតូច និងមធ្យម | Small and Medium Enterprises |
| UNCDF | មូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ | United Nations Capital Development Fund |
| UNCTAD | សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ | United Nations Conference on Trade and Development |
| UNDP | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ | United Nations Development Programme |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក | United Nations Economic and Social Commission for Asia and the Pacific |
| UNEP | កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ | United Nations Environment Programme |
| UPI | ក្រុមហ៊ុន យូញៀនផេ អន្តរជាតិ | Union Pay International |
| WB | ធនាគារពិភពលោក | World Bank |

# ខ្លឹមសារសង្ខេប

សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើង ប៉ុន្តែក្នុងល្បឿនយឺតជាងឆ្នាំមុន ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការរឹតបន្តឹងនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ចម្បងៗ និងការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយនៅមជ្ឈិមបូព៌ា។ តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៣ អាចសម្រេចបានក្នុងអត្រា ៣% ធៀបនឹង ៣,៥% នៅឆ្នាំមុន ដែលក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើន ១,៥% ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើន ៤% និងសេដ្ឋកិច្ចតំបន់អាស៊ានកើន ៤,៤%។ ទន្ទឹមនេះ អតិផរណាពិភពលោកបានថយចុះពី ៨,៣% នៅឆ្នាំ២០២២ មកត្រឹម ៦,៥% ប៉ុន្តែបន្តមានអត្រាខ្ពស់ជាងកម្រិតគោលដៅ ដែលធ្វើឱ្យធនាគារកណ្តាលអាចបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតបន្តឹងបន្ថែមទៀត។

ចំពោះកម្ពុជា សេដ្ឋកិច្ចត្រូវបានរំពឹងថាមានកំណើន ៥,៥% ដែលគាំទ្រដោយការកើនឡើងខ្ពស់នៃវិស័យទេសចរណ៍ និងកំណើនផលិតផលកម្មន្តសាលមិនមែនកាត់ដេរ។ វិស័យទេសចរណ៍មានកំណើនល្អប្រសើរក្នុងអត្រា ១៩,៨% ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើងដល់ ៥,៥ លាននាក់។ វិស័យកម្មន្តសាលបានកើនឡើងក្នុងអត្រា ៧,៩% ដោយផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញកើន ៩,៣% ជាពិសេសផលិតផលមិនមែនកាត់ដេរ ដូចជា បរិក្ខារអេឡិចត្រូនិកកើន ១,៣ដង និងយានយន្តនិងគ្រឿងបន្លាស់សម្រាប់យានយន្តកើន ៣,២ដង ខណៈផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ -៧%។ វិស័យកសិកម្មបានកើនឡើង ១,១% ដែលគាំទ្រដោយកំណើនបរិមាណផលស្រូវ ដំរកៅស៊ូ និងអនុវិស័យជលផល។ ចំណែកឯវិស័យសំណង់និងអចលនទ្រព្យបន្តមានកំណើនយឺតក្នុងអត្រា ១,១% និង ០,៥% រៀងគ្នា។ សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៦,១ លានដុល្លារអាមេរិក ដែលគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលសមតុល្យគណនីចរន្តនិងដើមទុនបានប្តូរពីឱនភាពមកជាអតិរេក។ អតិរេកនេះបានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

អតិផរណាបានថយចុះមក ២,១% ធៀបនឹង ៥,៤% នៅឆ្នាំ២០២២ ដែលជាចម្បងដោយសារការធ្លាក់ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងកម្រិតទាបនៃអតិផរណាម្ហូបអាហារ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងកម្រិតជាមធ្យម ៤.១១០ រៀល ដោយប្រាក់រៀលបានថយថ្លៃ ០,២% ធៀបនឹងឆ្នាំមុន (៤.១០២ រៀល)។ ស្ថិរភាពនេះសម្រេចបានដោយសារការធ្វើអន្តរាគមន៍ទីផ្សារប្តូរប្រាក់ ដោយលក់ប្រាក់ដុល្លារអាមេរិកសរុបចំនួន ១៣៩,១ លានដុល្លារអាមេរិក គួបផ្សំនឹងការអនុវត្តឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗទៀត ដែលបានជួយកាត់បន្ថយសម្ពាធថយថ្លៃនៃប្រាក់រៀល។ ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) បានកើនឡើងក្នុងកម្រិតសមស្របក្នុងអត្រា ១២,៥% ដែលគាំទ្រដោយកំណើននៃប្រាក់បញ្ញើទាំងជារៀល (១៤,១%) និងជារូបិយប័ណ្ណ (១៣%) និងការបន្តកើនឡើងនៃរូបិយវត្ថុក្នុងចរាចរណ៍ (៥,៩%)។

ទន្ទឹមនេះ ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ និងមានវឌ្ឍនភាពជាលំដាប់ ដែលធានាដល់ការរក្សាចីរភាពហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុចាំបាច់នានា ក្នុងការរួមចំណែកគាំទ្រសកម្មភាព

សេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ៨,៦% ដល់ ៣៩៦,៧ ទ្រីលានរៀល (៩៤,៣ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះវិស័យធនាគារមានសមាមាត្រ ៩១,៨% វិស័យមីក្រូហិរញ្ញវត្ថុ ៧,៦% និងវិស័យភតិសន្យាហិរញ្ញវត្ថុ ០,៦%។ ឥណទានទៅកាន់វិស័យចម្បងៗ មានកំណើន ៤,៨% ដល់ ២៣៧,២ ទ្រីលានរៀល (៥៧,៦ ប៊ីលានដុល្លារអាមេរិក) និងប្រាក់បញ្ញើអតិថិជនកើនឡើង ១៣,១% ដល់ ១៩៧,២ ទ្រីលានរៀល (៤៧,៩ ប៊ីលានដុល្លារអាមេរិក)។ ស្ថានភាពដើមទុនរបស់ប្រព័ន្ធធនាគារបន្តរក្សាបានភាពរឹងមាំ ដោយអនុបាតសាធនភាពមានកម្រិតខ្ពស់ដល់ ២២,៧% សម្រាប់វិស័យធនាគារ និង ២៥,៤% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១៥%) ស្របពេលដែលទ្រនាប់ដើមទុនត្រូវបានបន្តអនុវត្តឡើងវិញក្នុងកម្រិត ១,២៥% នៃទ្រព្យសកម្មថ្លឹងតាមទម្ងន់ហានិភ័យ។ ជាមួយគ្នានេះ សន្ទនីយភាពបន្តមានកម្រិតខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដោយអនុបាតគ្របខ័ណ្ឌសន្ទនីយភាពមានអត្រា ១៦៧,៦% សម្រាប់គ្រឹះស្ថានធនាគារពាណិជ្ជ និង ៣៣៣,៣% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ អនុបាតឥណទានមិនដំណើរការបានបន្តកើនឡើងដល់ ៥,៤% សម្រាប់វិស័យធនាគារ និង ៦,៧% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ដោយសារការបញ្ចប់វិធានការរៀបចំឥណទានឡើងវិញ និងការថមថយកំណើនឥណទាន។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ១៨,៩ លានគណនី និងគណនីឥណទានអតិថិជនដល់ ៣,៩ លានគណនី។ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានបន្តពង្រឹងជាប្រចាំ តាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ជាមួយនឹងការធ្វើស្ត្រេសតេស្ត ដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធធនាគារនិងរក្សាស្ថិរភាពហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ប្រព័ន្ធធនាគារបានរួមចំណែកក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីចូលរួមថែរក្សាបរិស្ថាននិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ព្រមទាំងកាត់បន្ថយហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មជាបន្តបន្ទាប់ ដែលធ្វើឱ្យការទូទាត់កាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងតម្លៃសមរម្យ។ ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ដែលបានរួមចំណែកសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន តាមរយៈការប្រើប្រាស់ប័ណ្ណឥណពន្ធបានលើគ្រប់ម៉ាស៊ីន ATM និង POS របស់គ្រឹះស្ថានសមាជិក។ សេវាទូទាត់ឌីជីថលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយចំនួនគណនីអ៊ីវ៉ាឡេតសរុបមាន ១៩,៧ លានគណនី និងទំហំប្រតិបត្តិការសេវាទូទាត់បានកើនឡើង ១៨% ដល់ប្រមាណ ៣១១,៥ ទ្រីលានរៀល (៧៥,៨ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ២,៨ដង នៃផ.ស.ស. ដែលមានចំនួនប្រតិបត្តិការ ៦០១,៣ លានប្រតិបត្តិការ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ហេដ្ឋារចនា-សម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់ថែមទៀត ដែលបច្ចុប្បន្ន រួមមាន ប្រទេសថៃ ឡាវ និងវៀតណាម ព្រមទាំងកំពុងពង្រីកការទូទាត់ឆ្លងដែនជាមួយប្រទេសដៃគូ និងស្ថាប័នផ្សេងៗទៀត ដូចជា ប្រទេសចិន ជប៉ុន សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងក្រុមហ៊ុន Alipay ផងដែរ។

ស្របពេលដែលនិន្នាការនៃការទូទាត់តាមប្រព័ន្ធឌីជីថលមានការកើនឡើង ការគ្រប់គ្រងចរាចរសាច់ប្រាក់ត្រូវបានយកចិត្តទុកដាក់អនុវត្តជាប្រចាំ ដែលបានបំពេញតម្រូវការសាធារណជននៅទូទាំងប្រទេស ជាមួយនឹងការលើកកម្ពស់សោភ័ណភាពនិងគុណភាពក្រដាសប្រាក់រៀល ដើម្បី

ពង្រឹងសុវត្ថិភាពនិងជំនឿទុកចិត្តលើរូបិយវត្ថុជាតិ។ ជាមួយគ្នានេះ កម្មវិធីផ្សព្វផ្សាយស្តីពី ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ក៏ត្រូវបានរៀបចំឡើងនៅតាមរាជធានី-ខេត្ត ដែលបាន បញ្ជ្រាបចំណេះដឹងដល់សាធារណជនអំពីអត្ថប្រយោជន៍នៃរូបិយវត្ថុជាតិ និងការរីកចម្រើននៃប្រព័ន្ធ រូបិយវត្ថុនិងសេវាហិរញ្ញវត្ថុនានា ព្រមទាំងបំផុសស្មារតីយុវជនឱ្យស្រឡាញ់និងប្រើប្រាស់ប្រាក់រៀល ឱ្យបានទូលំទូលាយ។ សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន ក៏បានរួមចំណែកយ៉ាង សំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិរឿងរ៉ាវនៃសេដ្ឋកិច្ចនិងរូបិយវត្ថុខ្មែរគ្រប់សម័យកាល ដែលចំនួនភ្ញៀវចូលទស្សនាសរុបបានកើនឡើង ១៨៥% ដល់ប្រមាណ ៣៩,៣ ពាន់នាក់។

ការពង្រឹងអភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ជាការងារអាទិភាពសម្រាប់ការរីកចម្រើន របស់ធនាគារជាតិនៃកម្ពុជា។ ក្នុងន័យនេះ ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចត្រូវបានបន្តពង្រឹង ជាប្រចាំ ដោយបានលើកកម្ពស់ការប្រតិបត្តិតាមបទប្បញ្ញត្តិ សេចក្តីណែនាំ និងនីតិវិធីការងារ ជាពិសេសបានរួមចំណែកពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងហានិភ័យនានា ស្របពេលដែល សមត្ថភាពប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្ត ត្រូវបានពង្រឹងឱ្យកាន់តែមានគុណភាព និង ប្រសិទ្ធភាព ដើម្បីផ្តល់សេវាធនាគារកណ្តាលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួង មន្ទីរ និង អង្គភាពរបស់រាជរដ្ឋាភិបាល និងផ្តល់សេវាប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក ជូនសាធារណជន ផងដែរ។ បច្ចុប្បន្ន មន្ត្រី-បុគ្គលិកសរុបរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន ១.៩៣២ រូប ដែលក្នុងនោះ សមាមាត្រមន្ត្រី-បុគ្គលិកជាស្ត្រីមានចំនួន ៤៩,២%។ សមត្ថភាពធនធានមនុស្សត្រូវបានអភិវឌ្ឍ ជាលំដាប់ តាមរយៈសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលក្នុងប្រទេស (មានសិក្ខាកាមចូលរួមសរុបចំនួន ៧៥០ រូប) វគ្គសិក្សារយៈពេលខ្លីនិងវែងនៅក្រៅប្រទេស (មានសិក្ខាកាមចូលរួមសរុបចំនួន ៨២៣ រូប) និងការសិក្សាតាមប្រព័ន្ធអនឡាញ (មានសិក្ខាកាមចូលរួមសរុបចំនួន ៥៨៥ រូប) ដែលបានលើកកម្ពស់ គុណវុឌ្ឍិរបស់មន្ត្រីបុគ្គលិក និងពង្រឹងរចនាសម្ព័ន្ធការងារប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកផ្តល់ការបណ្តុះបណ្តាលផ្នែកធនាគារនិងហិរញ្ញវត្ថុ តាមរយៈ ការពង្រឹងគុណភាពសិក្សានៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ ដែលមាននិស្សិតកំពុងសិក្សា សរុបចំនួន ២៨០ រូប។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានដើរតួនាទីយ៉ាងសំខាន់ លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយបានរៀបចំទទួលការចុះមក ត្រួតពិនិត្យដល់ទីកន្លែងនៅកម្ពុជារបស់ក្រុមការងារត្រួតពិនិត្យរួមនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) និងបំពេញតាមលក្ខខណ្ឌចាំបាច់នានារហូតសម្រេចបាន ជោគជ័យក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។ ស.ហ.ក. បាន និងកំពុងពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការវិភាគ និងបញ្ជូនរបាយការណ៍ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងការបណ្តុះបណ្តាលដល់ភាគី ពាក់ព័ន្ធ ព្រមទាំងបានដឹកនាំអនុគណៈកម្មការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពី ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ផងដែរ។

# ផ្នែកទី១- របាយការណ៍ប្រចាំឆ្នាំ២០២៣

## I- ស្ថានភាពសេដ្ឋកិច្ចពិភពលោក

នៅឆ្នាំ២០២៣នេះ សេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងបញ្ហានៃការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការរឹតបន្តឹងនយោបាយរូបិយវត្ថុ ស្របពេលដែលភាពតានតឹងភូមិសាស្ត្រនយោបាយនៅមជ្ឈិមបូព៌ាបានកើនឡើង។ ទន្ទឹមនេះ ការថយចុះល្បឿនកំណើនសេដ្ឋកិច្ចប្រទេសចិនក៏រួមចំណែកបង្អាក់ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកផងដែរ។

**ក្រាហ្វ ១ ៖ ចំណែកផ.ស.ស.ពិភពលោក**
(ឆ្នាំ២០២២)




ប្រភព៖ ធនាគារពិភពលោក

ទោះយ៉ាងណា វិស័យសេវាកម្មជាពិសេសទេសចរណ៍មានការកើនឡើងវិញយ៉ាងឆាប់រហ័ស ខណៈដែលកំណើនពាណិជ្ជកម្មពិភពលោក[១] បានថយចុះពី ៣% នៅឆ្នាំ២០២២ មក ០,៨% នៅឆ្នាំ២០២៣ ដោយសារការថមថយកំណើនក្នុងវិស័យកម្មន្តសាលជាសកល។

**ក្រាហ្វ ២ ៖ កំណើនពាណិជ្ជកម្មពិភពលោក**
(ឆ្នាំ២០២១ - ឆ្នាំ២០២៤ព)




ប្រភព៖ របាយការណ៍របស់ World Trade Organization ចុះផ្សាយខែតុលា ឆ្នាំ២០២៣, ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

**ក្រាហ្វ ៣ ៖ កំណើនទេសចរអន្តរជាតិ**
(ឆ្នាំគោល ២០១៩, ឆ្នាំ២០២១ - ខែកញ្ញា ឆ្នាំ២០២៣)




ប្រភព៖ UN Word Tourism Organization (UNWTO)

---

[១] របាយការណ៍របស់ WTO ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣។

មូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ស្មានថា កំណើនសេដ្ឋកិច្ចពិភពលោកអាចកើនក្នុងអត្រា ៣% នៅឆ្នាំ២០២៣ គឺទាបជាងឆ្នាំ២០២២ ដែលមានអត្រា ៣,៥%។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើន ១,៥% (ថយពី ២,៦%) ដែលគាំទ្រជារួមដោយកំណើនខ្ពស់ជាងការរំពឹងទុករបស់សហរដ្ឋអាមេរិក (២,១%) ប៉ុន្តែផាត់ទាត់ដោយកំណើនទាបរបស់តំបន់អឺរ៉ូ (០,៧%)។ ការវិនិយោគនិងតម្រូវការអ្នកប្រើប្រាស់ក្នុងសហរដ្ឋអាមេរិកមានការកើនឡើងគួរឱ្យកត់សម្គាល់ ស្របពេលដែលលំហសារពើពន្ធបានកើនឡើង។



ក្រាហ្វ ៤៖ កំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់

ប្រភព៖ របាយការណ៍ WEO របស់ IMF និង របាយការណ៍ AREO របស់ AMRO, ប=ប៉ាន់ស្មាន

ចំណែកឯ កំណើនសេដ្ឋកិច្ចរបស់ប្រទេសធំៗក្នុងតំបន់អឺរ៉ូមានកំណើនទាប ជាក់ស្តែង ប្រទេសបារាំងកើន ១% អង់គ្លេស ០,៥% និងអ៊ីតាលី ០,៧% ខណៈដែលអាល្លឺម៉ង់មានកំណើនអវិជ្ជមាន -០,៥%។ សេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍កើន ៤% (ថយពី ៤,១%) ដែលគាំទ្រដោយកំណើនល្អរបស់ប្រទេសឥណ្ឌា (៦,៣%) និងប្រេស៊ីល (៣,១%) ដោយសារការរីកលូតលាស់នៃវិស័យកសិកម្មនិងសេវាកម្ម ព្រមទាំងកំណើននៃតម្រូវការក្នុងស្រុក ខណៈប្រទេសចិនមានកំណើនទាបជាងការរំពឹងទុក (៥%) ដែលបណ្តាលមកពីវិបត្តិវិស័យអចលនទ្រព្យ ភាពទន់ខ្សោយនៃការវិនិយោគនិងការប្រើប្រាស់។ ចំណែកឯ តំបន់អាស៊ានមានកំណើន ៤,៤% (ថយពី ៥,៦%) ដែលគាំទ្រជាចម្បងដោយកំណើនតម្រូវការក្នុងស្រុកនិងកំណើននៃវិស័យទេសចរណ៍ ក្នុងនោះ ប្រទេសហ្វីលីពីនកើន ៥,៩% ឥណ្ឌូណេស៊ី ៥% ម៉ាឡេស៊ី ៤,២% ថៃ ៣,៥% និងសិង្ហបុរី ១%។

ក្រោយពីការរឹតបន្តឹងនយោបាយរូបិយវត្ថុជាបន្តបន្ទាប់នៅតាមបណ្តាប្រទេសជាច្រើន អតិផរណាពិភពលោកបានថយចុះពី ៨,៣% នៅឆ្នាំ២០២២ មក ៦,៥%[២] នៅឆ្នាំ២០២៣ ដែលក្នុងនោះ អតិផរណានៅប្រទេសអភិវឌ្ឍន៍មានកម្រិត ៤,៦% (៧,៣% ឆ្នាំមុន) ស្របពេលដែលប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មានកម្រិត ៨,៥% (៩,៨% ឆ្នាំមុន)។ តម្លៃរូបិយវត្ថុនៅប្រទេសជាច្រើនបន្តថយថ្លៃ ដូចជា យ៉េនជប៉ុន



ក្រាហ្វ ៥៖ អត្រាអតិផរណាពិភពលោក

ប្រភព៖ IMF, *ប= ប៉ាន់ស្មាន

[២] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក របស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២៣។

យ៉ន់ចិន ផោនអង់គ្លេស រីងហ្គីតម៉ាឡេស៊ី បាតថៃ និងវ៉ុនកូរ៉េ ខណៈដែលរូបិយវត្ថុនៅប្រទេសមួយចំនួនបានបង្ហាញការឡើងថ្លៃមកវិញខ្លះដោយសារនយោបាយរឹតបន្តឹងរូបិយវត្ថុ បន្ទាប់ពីបានធ្លាក់ចុះខ្លាំងកាលពីឆ្នាំមុន ដូចជា ប្រាក់អឺរ៉ូ និងដុល្លារសិង្ហបុរី។

**ក្រាហ្វ ៦៖ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិក**

(មធ្យម, ឆ្នាំលើឆ្នាំ, ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទោះជាបានថយចុះខ្លះ អតិផរណានៅប្រទេសជាច្រើននៅមានអត្រាខ្ពស់ជាងកម្រិតគោលដៅ ដែលជាហេតុធ្វើឱ្យធនាគារកណ្តាលអាចបន្តដំឡើងអត្រាការប្រាក់គោលបន្ថែមបន្តិចទៀត ទោះបីជាបានកើនដល់កម្រិតខ្ពស់ហើយក៏ដោយ។ នៅឆ្នាំ២០២៣នេះ ធនាគារកណ្តាលសហរដ្ឋអាមេរិក[៣] បានដំឡើងអត្រាការប្រាក់គោល ៤លើក ពី ៤,៥% ដល់ ៥,៥% ធនាគារកណ្តាលអឺរ៉ុប[៤] ៦លើក ពី ២,៥% ដល់ ៤,៥% និងធនាគារកណ្តាលអង់គ្លេស[៥] ៥ លើក ពី ៣,៥% ដល់ ៥,២៥%។ ដោយឡែកធនាគារកណ្តាលជប៉ុនបានបន្តរក្សាអត្រាការប្រាក់គោលត្រឹម -០,១% ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ចំណែកឯធនាគារកណ្តាលចិន[៦] បានបន្តបន្ថយអត្រាការប្រាក់គោលបន្តិចពី ៣,៦៥% មក ៣,៤៥% ដើម្បីជំរុញកំណើនសេដ្ឋកិច្ចដែលកំពុងប្រឈមនឹងវិបត្តិអចលនទ្រព្យ។ ចំពោះតំបន់អាស៊ានធនាគារកណ្តាលភាគច្រើនបានដំឡើងអត្រាការប្រាក់គោល ដើម្បីឆ្លើយតបនឹងអតិផរណាដែល

[៣] ធនាគារកណ្តាលអាមេរិក៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី ៤,៥% ដល់ ៤,៧៥% ក្នុងខែកុម្ភៈ, ៥% ក្នុងខែមីនា, ៥,២៥% ក្នុងខែឧសភា និង ៥,៥% ក្នុងខែកក្កដា។
[៤] ធនាគារកណ្តាលអឺរ៉ុប៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី២,៥% ដល់ ៣% ក្នុងខែកុម្ភៈ, ៣,៥% ក្នុងខែមីនា, ៣,៧៥% ក្នុងខែឧសភា, ៤% ក្នុងខែមិថុនា, ៤,២៥% ក្នុងខែកក្កដា និង ៤,៥% ក្នុងខែកញ្ញា។
[៥] ធនាគារកណ្តាលអង់គ្លេស៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី៣,៥% ដល់ ៤% ក្នុងខែកុម្ភៈ, ៤,២៥% ក្នុងខែមីនា, ៤,៥% ក្នុងខែឧសភា, ៥% ក្នុងខែមិថុនា និង ៥,២៥% ក្នុងខែសីហា។
[៦] ធនាគារកណ្តាលចិន៖ កាត់បន្ថយពី ៣,៦៥% មក ៣,៥៥% ក្នុងខែមិថុនា និង ៣,៤៥% ក្នុងខែសីហា។

ក្នុងនោះធនាគារកណ្ដាលថៃ[៧] បានដំឡើងអត្រាការប្រាក់គោល ៤លើក ពី ១,៥% ដល់ ២,៥% ហ្វីលីពីន[៨] ៣លើក ពី ៥,៥% ដល់ ៦,៥% ឥណ្ឌូណេស៊ី[៩] ២លើក ពី ៥,៧៥% ដល់ ៦% ម៉ាឡេស៊ី ១លើក ពី ២,៧៥% ដល់ ៣% ខណៈដែលធនាគារកណ្ដាលវៀតណាម[១០] បានកាត់បន្ថយអត្រាការប្រាក់គោល ចំនួន ៣លើក ពី ៦% មក ៤,៥%។

**ក្រាហ្វ ៧៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២៣)




**ក្រាហ្វ ៨៖ អត្រាការប្រាក់គោលនៃប្រទេសក្នុងតំបន់អាស៊ី**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ Trading Economics

ជារួម សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២៣នេះ បន្តមានកំណើនទាបជាងឆ្នាំមុន ដែលបណ្ដាលមកពីការបែងចែកភូមិសាស្ត្រនយោបាយ កម្រិតខ្ពស់នៅឡើយនៃអត្រាអតិផរណា និងការរួមតូចនៃលំហសារពើពន្ធ។ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានគាំទ្រដោយការងើបឡើងនៃវិស័យសេវាកម្ម និងតម្រូវការក្នុងស្រុក។

---

[៧] ធនាគារកណ្ដាលថៃ៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី ១,៥% ដល់ ១,៧៥% ក្នុងខែមីនា, ២% ក្នុងខែមិថុនា, ២,២៥% ក្នុងខែកក្កដា និង ២,៥% ក្នុងខែកញ្ញា ឆ្នាំ២០២៣។
[៨] ធនាគារកណ្ដាលហ្វីលីពីន៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី ៦% ដល់ ៦,២៥% ក្នុងខែមីនា និង ៦,៥% ក្នុងខែតុលា ឆ្នាំ២០២៣។
[៩] ធនាគារកណ្ដាលឥណ្ឌូណេស៊ី៖ ក្នុងឆ្នាំ២០២៣ ដំឡើងពី ៥,២៥% ដល់ ៥,៧% ក្នុងខែមករា និង ៦%ក្នុងខែតុលា ឆ្នាំ២០២៣។
[១០] ធនាគារកណ្ដាលវៀតណាម៖ ក្នុងឆ្នាំ២០២៣ បន្ថយពី ៦% មក ៥,៥% ក្នុងខែមេសា, ៥% ក្នុងខែឧសភា និង ៤,៥% ក្នុងខែមិថុនា។

## II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ១- កំណើនសេដ្ឋកិច្ច

សកម្មភាពសេដ្ឋកិច្ចកម្ពុជាបានបន្តដើបឡើង ដែលគាំទ្រដោយកំណើននៃវិស័យសេវាកម្ម ជាពិសេសវិស័យទេសចរណ៍ និងការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលការនាំចេញវិស័យកាត់ដេរ វិស័យកសិកម្ម សំណង់ និងអចលនទ្រព្យ មានកំណើនទាប។

**ក្រាហ្វ ៩៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៤ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនិងការប៉ាន់ស្មានរបស់ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

**វិស័យកម្មន្តសាល៖** វិស័យកម្មន្តសាលបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ផលិតផលកម្មន្តសាលសរុបបានកើនឡើង ១,២%[១១]។ កំណើនទាបនេះមួយផ្នែកដោយសារកំណើនខ្ពស់ស្រាប់នៃផលិតផលកម្មន្តសាលកាលពីឆ្នាំ២០២២ ដែលមានកម្រិតខ្ពស់ដល់ ៨៣,១% និងមួយផ្នែកទៀតដោយសារការថមថយតម្រូវការខាងក្រៅ។ ផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញបានកើន ៤,៣% ដែលក្នុងនោះផលិតផលកាត់ដេរ[១២] មានកំណើន ៤% ស្របពេលដែលផលិតផលមិនមែនកាត់ដេរមានកំណើន ៤,៩% (បរិក្ខារអេឡិចត្រូនិកកើន ១,៣ដង និងយានយន្តនិងគ្រឿងបន្លាស់សម្រាប់យានយន្តកើន ៣,២ដង) ខណៈផលិតផល

**ក្រាហ្វ ១០៖ តម្លៃនិងកំណើនផលិតផលកម្មន្តសាលសរុប**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែកញ្ញា ឆ្នាំ២០២៣)

[១១] ទិន្នន័យប៉ាន់ស្មានចាប់ពីខែតុលា-ខែធ្នូ ឆ្នាំ២០២៣។

[១២] ផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ កាបូប ស្បែកជើង និងផលិតផលពីស្បែក។

កម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកថយចុះ -៧%។ គួររំលេចថា សមាមាត្រការនាំចេញផលិតផលកាត់ដេរបានថយចុះពី ៥៦% កាលពីឆ្នាំ២០២២ មក ៤៧,៨% នៅឆ្នាំ២០២៣ ស្របពេលដែលការវិនិយោគទៅលើវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដូចជាការផលិតផ្ទាំងសូឡានិងកម្មន្តសាលផ្សេងៗ បានកើនឡើងគួរឱ្យកត់សម្គាល់ ៤៧,៩% និង ៩៧,៣% រៀងគ្នា។ ចំនួនរោងចក្រ[១៣]នៅក្នុងវិស័យកម្មន្តសាលបានកើនឡើងដល់ ២.០៧១ រោងចក្រ ពី ១.៩៨២ រោងចក្រ នៅឆ្នាំមុន និងអាចផ្តល់ការងារដល់កម្មករប្រមាណ ១លាននាក់។



ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែតុលា ឆ្នាំ២០២៣)


រូបភាព៖ រោងចក្រដំឡើងយានយន្តនិងគ្រឿងបង្គុំនៅខេត្តកំពង់ស្ពឺ
ប្រភព៖ HMN page


រូបភាព៖ ផ្ទាំងសូឡានៅខេត្តកំពត, ប្រភព៖ Property & Construction

**វិស័យសេវាកម្ម៖** វិស័យទេសចរណ៍មានកំណើនល្អប្រសើរ ដោយសារការងើបឡើងវិញខ្ពស់ជាងការរំពឹងទុកនៃភ្ញៀវអន្តរជាតិ។ ភ្ញៀវអន្តរជាតិ[១៤] បានកើនឡើង ២,៤ដង ដល់ប្រមាណ ៥,៥ លាននាក់ (២,៣ លាននាក់ ឆ្នាំ២០២២)។ កំណើននេះត្រូវបានគាំទ្រដោយភាពប្រសើរឡើងនៃទេសចរណ៍ក្នុងតំបន់ ជោគជ័យនៃការធ្វើជាម្ចាស់ផ្ទះកីឡាស៊ីហ្គេម និង អាស៊ានប៉ារ៉ាហ្គេម គួបផ្សំនឹងការដាក់ឱ្យដំណើរការព្រលានយន្តហោះអន្តរជាតិសៀមរាបអង្គរថ្មី និងកំណើននៃការតភ្ជាប់ជើងហោះហើរត្រង់មកកម្ពុជាឡើងវិញ។ ទោះយ៉ាងណា ភ្ញៀវអន្តរជាតិនៅឆ្នាំ២០២៣នេះ មានចំនួនប្រមាណ ៨៣% នៃភ្ញៀវទេសចរអន្តរជាតិសរុបនៅគ្រាមុនវិបត្តិជំងឺកូវីដ-១៩ (៦,៦ លាននាក់ ក្នុងឆ្នាំ២០១៩)។



ប្រភព៖ ក្រសួងទេសចរណ៍

[១៣] រោងចក្រធុនធំ និងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
[១៤] ក្នុងឆ្នាំ២០២៣ ភ្ញៀវថៃឈរនៅលំដាប់ទី១ (សមាមាត្រ ៣៣,៤% នៃភ្ញៀវអន្តរជាតិសរុប) ភ្ញៀវវៀតណាមឈរលំដាប់ទី២ (១៨,៧%) និងភ្ញៀវចិនឈរលំដាប់ទី៣ (១០%)។

ជាមួយគ្នានេះ ទេសចរក្នុងស្រុកមានកំណើនខ្ពស់ជាងគ្រាមុនវិបត្តិ ដោយបានកើន ៣៩.៥% ដល់ ១៨,៧ លាននាក់ ដែលក្នុងនោះ តំបន់ឆ្នេរបានទទួលទេសចរច្រើនជាងគេក្នុងសមាមាត្រ ៤៩% នៃទេសចរក្នុងស្រុកសរុប បន្ទាប់មករាជធានីភ្នំពេញ (សមាមាត្រ ៣៥,១%) ខេត្តសៀមរាប (៩,២%) និងតំបន់អេកូទេសចរណ៍ (២,៩%)។



ប្រភព៖ ក្រសួងទេសចរណ៍



រូបភាព៖ អង្គរវត្តជាប់ជាកន្លែងមើលថ្ងៃរះស្អាតបំផុតលើពិភពលោកប្រចាំឆ្នាំ២០២៣, ប្រភព៖ Seasia stats


រូបភាព៖ ភ្ញៀវទេសចរដើរកម្សាន្តក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ, ប្រភព៖ រដ្ឋបាលរាជធានីភ្នំពេញ

**វិស័យកសិកម្ម៖** វិស័យកសិកម្មបន្តសម្រេចបានកំណើនទាបប៉ុន្តែខ្ពស់ជាងឆ្នាំមុនបន្តិច ដែលគាំទ្រដោយកំណើនផលិតកម្មស្រូវ ដំឡូងមី កៅស៊ូ និងអនុវិស័យជលផល។ ផលស្រូវបានកើនឡើង ៧,១% (ដល់ ១២,៥ លានតោន) ដែលក្នុងនោះ ផលស្រូវរដូវប្រាំងកើន ៨% (៣,២ លានតោន) ស្របពេលដែលផលស្រូវរដូវវស្សាកើន ៦,៨% (៩,៣ លានតោន) ដែលជាចម្បងដោយសារកត្តាអំណោយផលពីអាកាសធាតុ និងការគាំទ្រពីការនាំចេញទៅទីផ្សារក្រៅប្រទេស។



ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ផលកៅស៊ូមានកំណើនទាបត្រឹម ០,៤% (ដល់ ៣៨១ ពាន់តោន) ធៀបនឹងឆ្នាំមុន (២,៦%)។ ចំណែកឯតម្លៃជ័រកៅស៊ូជាមធ្យមបានធ្លាក់ចុះ-១០% (និន្នាការធ្លាក់ចុះតាំងពីដើមឆ្នាំ២០២២) ស្របពេលដែលការនាំចេញជ័រកៅស៊ូថយចុះ -៤,៥%។




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

អនុវិស័យជលផលបន្តមានកំណើនល្អ ដែលក្នុងនោះអាជីវកម្មនេសាទសមុទ្រនិងទឹកសាបមាននិន្នាការកើនឡើងប្រមាណ ៦,៣% និង ៥,៤% រៀងគ្នា ខណ:ដែលការចិញ្ចឹមត្រីបានថយចុះ -៥%។




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)



រូបភាព៖ ពានរង្វាន់អង្ករល្អជាងគេនៅឆ្នាំ២០១៨និង២០២២។ សម្រាប់ឆ្នាំ២០២៣ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ២ ដែលធ្វើឡើងនៅប្រទេសហ្វីលីពីន, ប្រភព៖ សហព័ន្ធស្រូវអង្ករកម្ពុជា



រូបភាព៖ ផលនេសាទត្រីទឹកសាប, ប្រភព៖ ក្រសួងព័ត៌មាន

**វិស័យសំណង់និងអចលនទ្រព្យ៖** វិស័យសំណង់មានកំណើនទាប ១,១% ធៀបនឹង ០,៥% នៅឆ្នាំមុន ដែលគាំទ្រដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ស្ពាន អាកាសយានដ្ឋាន និងផ្លូវល្បឿនលឿន ជាដើម។ ការនាំចូលសម្ភារនិងបរិក្ខារសំណង់បានកើន ៤,៧% (ឆ្នាំមុនថយ -២៥,៦%)។ ផ្ទៃក្រឡានិងតម្លៃគម្រោងសំណង់ ដែលទទួលបានការអនុម័តមានកំណើន ១ដង ជាពិសេសគម្រោងសំណង់លំនៅឋាននិងសំណង់សាធារណៈ ខណៈចំនួនគម្រោងសំណង់សរុបបានថយចុះ -២០,៥%។

**ក្រាហ្វ ១៧៖ ការនាំចូលសម្ភារនិងបរិក្ខារសំណង់**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា , *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

**ក្រាហ្វ ១៨៖ ចំនួននិងផ្ទៃក្រឡាគម្រោងសំណង់**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




**ក្រាហ្វ ១៩៖ តម្លៃនិងកំណើនគម្រោងសំណង់**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា , *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

វិស័យអចលនទ្រព្យបន្តកើនឡើងទាបត្រឹម ០,៥% ធៀបនឹង ០,២% នៅឆ្នាំ២០២២។ សកម្មភាពលក់លំនៅឋាន (ផ្ទះល្វែង វីឡាភ្លោះនិងទោល) បានថយចុះ -៤៩,៧% ខណៈដែលការលក់ខុនដូកើនឡើង ២%។ សន្ទស្សន៍ថ្លៃលំនៅឋាន (RPPI) បានថយចុះ -២,៤% ដែលក្នុងនោះនៅរាជធានីភ្នំពេញបានថយចុះ -៣,២% ខណៈនៅតាមបណ្តាខេត្តបានកើនឡើង ៣,២%។

**ក្រាហ្វ ២០៖ សន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា**
(បម្រែបម្រួលគិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែវិច្ឆិកា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា



រូបភាព៖ អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ, ប្រភព៖ Heerim



រូបភាព៖ ស្ពានអាកាសព្រះមុនីវង្ស,
ប្រភព៖ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ

## ២- ស្ថានភាពអតិផរណា

អតិផរណារួមនៅឆ្នាំ២០២៣ មានកម្រិត ២,១% ទាបជាងឆ្នាំមុន (៥,៤%) ដោយសារការថយចុះថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងការថមថយអតិផរណាម្ហូបអាហារ។

**ក្រាហ្វ ២១៖ អតិផរណាជាមធ្យមប្រចាំឆ្នាំ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆ្នាំ២០១៨ - ឆ្នាំ២០២៣)




**ក្រាហ្វ ២២៖ អតិផរណា និងការរួមចំណែកក្នុងអតិផរណា**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៣ ៖ អតិផរណារួម និងអតិផរណាក្រុមទាំងបី**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេង-ឥន្ធនៈបានថយចុះ -២,៧% បន្ទាប់ពីបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ១១,១% នៅឆ្នាំ២០២២ ដោយសារតម្លៃប្រេងនៅពិភពលោកបានថយចុះមកវិញ -២៨,១% ពីជាមធ្យម ១០០,៨ ដុល្លារអាមេរិកក្នុងមួយបារ៉ែលនៅឆ្នាំ២០២២ មក ៧៧,៧ ដុល្លារអាមេរិកក្នុងមួយបារ៉ែលនៅឆ្នាំ២០២៣។ នៅកម្ពុជា ថ្លៃសាំងបានធ្លាក់ចុះ -៥,៦% ធៀបនឹងកំណើន ២៤,៥% នៅឆ្នាំ២០២២, ថ្លៃឧស្ម័នធ្លាក់ចុះ -៤,៧% ធៀបនឹង ១៨,៣% ខណៈថ្លៃឥន្ធនៈរឹងកើន ១% ធៀបនឹង ៥,៤%។

**ក្រាហ្វ ២៤ ៖ ការរួមចំណែកក្នុងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

អតិផរណាម្ហូបអាហារ បានថមថយមក ៣,២% ធៀបនឹង ៥% នៅឆ្នាំ២០២២ ដោយសារការថយសម្ពាធពីចំណាយថ្លៃដើម ដូចជា ជីកសិកម្ម ប្រេងឥន្ធនៈ និងថ្លៃដឹកជញ្ជូន ស្របពេលដែលការផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងស្រុកបន្តកើនឡើង។ អតិផរណាម្ហូបអាហារសំខាន់ៗបានថយចុះ ដូចជា ថ្លៃអង្ករ ពី ២,៤% មក ១,៥%, ថ្លៃសាច់ ពី ៤,៣% មក ២,៥%, ថ្លៃត្រី ពី ៥% មក ៤,២%, ថ្លៃបន្លែ ពី ៧,៩% មក ៥,១% និងថ្លៃផ្លែឈើ ពី ៧,៧% មក ៤,២%។

**ក្រាហ្វ ២៥ ៖ ការរួមចំណែកក្នុងអតិផរណាម្ហូបអាហារ**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

អតិផរណាស្នូល បានថមថយមកកម្រិត ២% ធៀបនឹង ៤,៤% នៅឆ្នាំ២០២២ ដែលបណ្តាលមកពីឥទ្ធិពលនៃការថយថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងកម្រិតទាបនៃអតិផរណាម្ហូបអាហារ។ អតិផរណាទំនិញនិងសេវាស្នូលសំខាន់ៗបានថមថយ ដូចជា ក្រុមភោជនីយដ្ឋានថយពី ៦,៦% មក ២,១%, ថ្លៃក្រុមសម្លៀកបំពាក់និងស្បែកជើងថយពី ៧,៤% មក ៣,១%, ថ្លៃក្រុមកម្សាន្តនិងវប្បធម៌ថយពី ៥,៦% មក ៣,១% និងថ្លៃក្រុមដឹកជញ្ជូនមិនរាប់បញ្ចូលទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈថយពី ២,១% មក ១,១%។

**ក្រាហ្វ ២៦ ៖ ការរួមចំណែកក្នុងអតិផរណាស្នូល**

(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា,
*មិនរាប់បញ្ចូលក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ

## ៣- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនៅឆ្នាំ២០២៣ បន្តមានស្ថិរភាព ទោះបីមានកម្រិតខ្ពស់បន្តិចធៀបនឹងគ្រាមុនមានវិបត្តិកូវីដ-១៩ក៏ដោយ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានកម្រិតជាមធ្យម ៤.១១០ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃ ០,២% ធៀបនឹងឆ្នាំមុន (៤.១០២ រៀល) និង ១,៤% ធៀបនឹងគ្រាមុនវិបត្តិ ២០១៦-២០១៨ (៤.០៥២ រៀល)។ ចាប់ពីខែឧសភាមក អត្រាប្តូរប្រាក់បានកើនឡើងជាលំដាប់ និងកើនដល់ ៤.១៥៨ រៀលក្នុងមួយដុល្លារអាមេរិក នៅចុងខែសីហា ដែលជាចម្បងបណ្តាលមកពីការថយចុះចំណូលពន្ធ ការកើនឡើងចំណាយសាធារណៈ កម្រិតទាបនៃលំហូរចូលប្រាក់ដុល្លារអាមេរិក និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនៅលើទីផ្សារអន្តរជាតិ។ ដើម្បីកាត់បន្ថយសម្ពាធថយថ្លៃនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ និងប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗទៀត ដែលធ្វើឱ្យអត្រាប្តូរប្រាក់បានថយចុះមកវិញមកត្រឹម ៤.០៨១ រៀលក្នុងមួយដុល្លារអាមេរិក នៅចុងខែធ្នូ ឆ្នាំ២០២៣នេះ។ ចំណែករូបិយប័ណ្ណប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាមួយចំនួនបានថយថ្លៃគួរកត់សម្គាល់ធៀបនឹងដុល្លារអាមេរិក ដូចជាយ៉េនជប៉ុន (-៩%) យ៉ន់ចិន (-៦,៧%) បាតថៃ (-១,៤%) ដុងវៀតណាម (-២,៦%) និងផោនអង់គ្លេស (-១,៣%) ខណៈប្រាក់អឺរ៉ូកើនថ្លៃបន្តិច (០,៨%)។

**ក្រាហ្វ ២៧៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៨៖ សន្ទស្សន៍ប្រាក់ដុល្លារអាមេរិក**
(ឆ្នាំ២០២១ - ឆ្នាំ២០២៣)




**ក្រាហ្វ ២៩៖ អត្រាប្តូរប្រាក់ប្រទេសសំខាន់ៗ និងក្នុងតំបន់ធៀបនឹងដុល្លារអាមេរិក**
(មធ្យម, មករា ឆ្នាំ២០២២=១០០, ឆ្នាំ២០២២ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣០៖ ចំណូល-ចំណាយរបស់រដ្ឋាភិបាល**

(គិតជាទ្រីលានរៀល, ខែមករា - ខែតុលា ឆ្នាំ២០២៣)




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រអប់ទី ១៖ ប្រតិបត្តិការប្តូរប្រាក់នៅលើផ្លែតហ្វម NBCP

ផ្លែតហ្វម NBCP ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៨ ដែលមកដល់បច្ចុប្បន្នមានសមាជិកជួញដូរក្នុងប្រព័ន្ធចំនួន ៦៩ គ្រឹះស្ថាន រួមមាន៖ ធនាគារពាណិជ្ជ ៥០ ធនាគារឯកទេស ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ១០ និងអាជីវករប្តូរប្រាក់ចំនួន ៥។ ប្រតិបត្តិការជួញដូរប្រាក់ដុល្លារអាមេរិកក្នុងផ្លែតហ្វម NBCP បានកើនឡើងជាលំដាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ តែបានថយចុះ -៤% មកប្រមាណ ១,៨ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០២៣នេះ (បើទោះជាចំនួនប្រតិបត្តិការជួញដូរមាន ១.៤៨៣ ប្រតិបត្តិការ ប្រហាក់ប្រហែលនឹងឆ្នាំ២០២២)។ ការថយចុះនេះ បណ្តាលមកពីការថយចុះតម្រូវការទិញ-លក់ប្រាក់ដុល្លារអាមេរិក និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

**ក្រាហ្វ ៣១៖ ទំហំប្រតិបត្តិការប្តូរប្រាក់តាមផ្លែតហ្វម NBCP**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) មាននិន្នាការថយចុះ ដែលបានជួយបន្ទាបសម្ពាធអតិផរណាពីការនាំចូល។ IREER បានថយចុះ -៣,៨% ដោយសារអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល (INEER)[១៥] បានថយចុះ -៤,៦% បើទោះជាអតិផរណាប្រទេសដៃគូនាំចូលមានកម្រិតខ្ពស់ជាងអតិផរណារបស់កម្ពុជា។

**ក្រាហ្វ ៣២៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព**

(សន្ទស្សន៍ ២០១៥=១០០, ឆ្នាំ២០២០ - ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

---

[១៥] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) កើនឡើង ០,៧% ដែលបង្ហាញពីកំណើនឧត្តមភាពប្រកួតប្រជែងការនាំចេញរបស់កម្ពុជា។ កំណើននេះបណ្តាលមកពីអត្រាអតិផរណារបស់កម្ពុជាមានកម្រិតទាបជាងប្រទេសដៃគូនាំចេញ បើទោះជាអត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER)[១៦] ថយចុះ -១,៣%។

## ៤- ស្ថានភាពជញ្ជីងទូទាត់

សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាបន្តមានអតិរេក ២២៦,១ លានដុល្លារអាមេរិក ដែលទាបជាងអតិរេកឆ្នាំមុន (៣៩៥,៩ លានដុល្លារអាមេរិក)។ អតិរេកនេះត្រូវបានគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុស្របពេលដែលសមតុល្យគណនីចរន្តនិងដើមទុនបានប្តូរពីឱនភាពមកជាអតិរេក។

**ក្រាហ្វ ៣៣៖ ជញ្ជីងទូទាត់កម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា,*ប=ប៉ាន់ស្មាន

### - គណនីចរន្តនិងដើមទុន

សមតុល្យគណនីចរន្តនិងដើមទុន មានអតិរេក ២,៩% នៃផ.ស.ស. ធៀបនឹងឱនភាព ២៤,៩% នៃផ.ស.ស. នៅឆ្នាំមុន។ ការប្តូរពីឱនភាពមកជាអតិរេកនៃគណនីចរន្តនិងដើមទុននេះ ជាចម្បងបណ្តាលមកពី៖ i/- ការថយចុះឱនភាពពាណិជ្ជកម្មទំនិញ[១៧] ii/- ការកើនឡើងអតិរេកសេវា[១៨] និង iii/- ការថយចុះឱនភាពចំណូលបឋម[១៩] ខណៈដែលអតិរេកចំណូលបន្ទាប់បន្សំ[២០] បានថយចុះ។

**ក្រាហ្វ ៣៤៖ គណនីចរន្ត និងគណនីដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

---

[១៦] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្ស៊ិក បារាំង ហូឡង់ វៀតណាម ហុងកុង អ៊ីតាលី។

[១៧] ឱនភាពគណនីពាណិជ្ជកម្មទំនិញបានថយចុះ-៦ ប៊ីលានដុល្លារអាមេរិក (-៦៨,៥%) ធៀបនឹងឱនភាព ៨,៨ ប៊ីលានដុល្លារអាមេរិក ឆ្នាំមុន ក្នុងនោះ ការនាំចេញបានកើនឡើង ១,៧% ខណៈការនាំចូលបានថយចុះ -១៧,៧%។

[១៨] គណនីសេវាសុទ្ធបានប្តូរពីឱនភាព ៩៣៥,៧ លានដុល្លារអាមេរិក ឆ្នាំមុន មកជាអតិរេក ១,៣ ប៊ីលានដុល្លារអាមេរិក ជាចម្បងដោយសារការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ។

[១៩] ឱនភាពគណនីចំណូលបឋមបានថយចុះ -៦២៣,៧ លានដុល្លារអាមេរិក (-៤០,២%) ធៀបនឹងឱនភាព ១,៦ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។

[២០] អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -៥៣,២ លានដុល្លារអាមេរិក (-១,៦%) ធៀបនឹងអតិរេក ៣,២ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២២។

ឱនភាពពាណិជ្ជកម្មទំនិញបានធ្លាក់ចុះ -៦៨,៩% ស្មើនឹង ២,៨ ប៊ីលានដុល្លារអាមេរិក (ឆ្នាំមុន ៨,៨ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៨,៦% នៃផ.ស.ស. ដែលជាចម្បងដោយសារការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃការនាំចូល បើទោះបីជាការនាំចេញកើនឡើងទាបក៏ដោយ។ ការនាំចូលធ្លាក់ចុះ -១៧,៧% ដែលក្នុងនោះ ការនាំចូលយានយន្តថយ -៣៥,៩% ប្រេងឥន្ធនៈ -៥,៣% និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ -៧% ខណៈដែលការនាំចូលម្ហូបអាហារនិងភេសជ្ជៈកើន ១០,២% និងសម្ភារនិងបរិក្ខារសំណង់ ៤,៧%។ ការនាំចេញបានកើនឡើង ១,៧% ដែលក្នុងនោះ ការនាំចេញផលិតផលក្រៅពីកាត់ដេរ បានកើនឡើង ២០,៦% (ឆ្នាំមុនកើន ២៥,៣%) រួមមាន៖ គ្រឿងអេឡិចត្រូនិក កើន ៦៦,៣% កៅស៊ូ ២៩% អង្ករ ១២,៤% និងផ្សេងៗ ១៨,៧% ចំណែកឯការនាំចេញផលិតផលកាត់ដេរ[២១] ថយចុះ -១៣,២% និងទោចក្រយាន -៤៩,៣%។

ក្រៅពីការធ្លាក់ចុះនៃឱនភាពពាណិជ្ជកម្មទំនិញ គណនីសេវាសុទ្ធបានប្តូរពីឱនភាពទៅជាអតិរេក ដែលជាចម្បងបណ្តាលមកពីការងើបឡើងវិញនៃចំនួនទេសចរអន្តរជាតិ (ចំណូលពីសេវាធ្វើដំណើរកើនឡើង ១,២ដង) ស្របពេលដែលឱនភាពគណនីចំណូលបឋមបានថយចុះ -៤០,២% (ដោយសារការទូទាត់ចូលក្នុងប្រទេស[២២] កើន ៤៥,៩% ហើយការទូទាត់ទៅក្រៅប្រទេស[២៣] ថយ -២៤,៥%)

**ក្រាហ្វ ៣៥៖ ពាណិជ្ជកម្មទំនិញរបស់ប្រទេសកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២៣)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៦៖ ការនាំចូលទំនិញ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៧៖ ការនាំចេញទំនិញ**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងធនាគារជាតិនៃកម្ពុជា

[២១] ក្នុងនោះការនាំចេញសម្លៀកបំពាក់ថយចុះ -១២,៩% ស្បែកជើង -២១,៤% សម្ភារសម្រាប់ធ្វើដំណើរនិងផលិតផលវាយនភ័ណ្ឌផ្សេងទៀត -៧,៧%។

[២២] ក្នុងនោះ៖ ចំណូលពីការប្រាក់កើន ២៧,១%។

[២៣] ក្នុងនោះ៖ ការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់ថយចុះ -៣២,៤% ខណៈចំណាយការប្រាក់របស់រាជរដ្ឋាភិបាលកើន ១០,២%។

។ ទន្ទឹមនេះ អតិរេកគណនីចំណូលបន្ទាប់បន្សំបានថយចុះ -១,៦% ដែលក្នុងនោះ ជំនួយរបស់រាជរដ្ឋា-ភិបាលកើន ៤,២% ខណៈប្រាក់បង្វែរឯកជនចូលក្នុងប្រទេស[២៤] ថយ -២,៧%។

- **គណនីហិរញ្ញវត្ថុ**

សមតុល្យគណនីហិរញ្ញវត្ថុមានលំហូរចូលសុទ្ធ ៦៧១,២ លានដុល្លារអាមេរិក ដែលធ្លាក់ចុះ-៩០,១% បើធៀបនឹងឆ្នាំមុន។ វិនិយោគផ្ទាល់បរទេសបានកើនឡើង ១៤,៥% ដែលជាចម្បងដោយសារការកើនឡើងការវិនិយោគលើវិស័យមិនមែនហិរញ្ញវត្ថុ[២៥] ៣៤,៤% ខណៈការវិនិយោគលើវិស័យហិរញ្ញវត្ថុ ថយចុះ -២៨,៧%។

វិនិយោគផ្សេងទៀតមានលំហូរចេញសុទ្ធ ២,៩ ប៊ីលានដុល្លារអាមេរិក ដែលបានប្តូរពីលំហូរចូលសុទ្ធ ៣,៥ ប៊ីលានដុល្លារអាមេរិកក្នុងឆ្នាំមុន។ ការកើនឡើងលំហូរចេញសុទ្ធនេះជាចម្បងដោយសារ កំណើនបង្វែរទ្រព្យសកម្មហិរញ្ញវត្ថុនៃវិស័យធនាគារទៅក្រៅប្រទេស ស្របពេលដែលការខ្ចីរបស់រាជរដ្ឋាភិបាលសុទ្ធថយចុះ -៨,៤%។

**ក្រាហ្វ ៣៨៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

**ក្រាហ្វ ៣៩ ៖ ការចូលរួមចំណែកក្នុងកំណើនវិនិយោគផ្ទាល់បរទេស**

(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

---

[២៤] ក្នុងនោះ ប្រាក់បង្វែររបស់ពលករពីក្រៅប្រទេសថយ -១% ក្នុងនោះ ពីជប៉ុនកើន ២២% កូរ៉េ ៣% ខណៈប្រាក់បង្វែរពីប្រទេសម៉ាឡេស៊ីថយចុះ -១៣% ថៃ -៣%។

[២៥] ការវិនិយោគលើវិស័យកម្មន្តសាលកើន ៩៦,៧% (ក្នុងនោះ ការវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់កើន ៥៧,៥% ស្បែកជើង ១,៨ដង ផលិតផលធ្វើដំណើរ ៥៤,៩% វេចខ្ចប់ ២,៨ដង ផលិតផ្ទាំងសូឡា ២៦,៨% និងផ្សេងៗទៀត ៨៦,៩%) វិស័យសំណង់ ១៦,៨% វិស័យអាជីវកម្មរ៉ែ ២១,៩% វិស័យកសិកម្ម ២០,១% និងវិស័យសណ្ឋាគារនិងការកម្សាន្ត ១១,៤% ខណៈដែល វិស័យអចលនទ្រព្យ ថយចុះ -២០% វិស័យថាមពល -២៨,២% និងវិស័យផ្សេងទៀតថយចុះ -២១,៥%។

## ៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

ទុនបម្រុងអន្តរជាតិបានកើនដល់ ២០ ប៊ីលានដុល្លារអាមេរិក (១២,៣%) បន្ទាប់ពីបានធ្លាក់ចុះនៅឆ្នាំ២០២២។ ការកើនឡើងទុនបម្រុងអន្តរជាតិជាចម្បងបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការកើនឡើងតម្លៃទីផ្សារសំពៀត វិនិយោគ ការកើនឡើងប្រាក់បញ្ញើរាជរដ្ឋាភិបាល ការប្រែប្រួលថ្លៃមាសនិងអត្រាប្តូរប្រាក់ និងចំណូលពីការវិនិយោគទុនបម្រុងអន្តរជាតិ។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវានាគ្រាបន្ទាប់។

**ក្រាហ្វ ៤០៖ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ ២០១៦ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការវិនិយោគទុនបម្រុងអន្តរជាតិបានរងសម្ពាធពីការប្រែប្រួលស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងកំណើនយឺតនៃសេដ្ឋកិច្ចពិភពលោក។ ការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងមានភាពបត់បែនខ្ពស់។ ហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់ ដោយគោរពតាមសេចក្តីណែនាំការវិនិយោគ និងផ្អែកលើគោលការណ៍គ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងទទួលបានចំណូលសមស្រប។ សេចក្តីណែនាំការវិនិយោគត្រូវបានធ្វើបច្ចុប្បន្នកម្មចំនួន ២លើកនៅឆ្នាំ២០២៣ ដោយបានកែសម្រួលសមាសភាគនៃចំណែកទុនបម្រុងវិនិយោគនិងរូបិយប័ណ្ណ ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការសន្ទនីយភាព និងលទ្ធភាពខ្ពស់ក្នុងការចាប់យកឱកាសបង្កើនចំណូលពីការប្រែប្រួល នៃអត្រាការប្រាក់នៅលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។

ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការវិនិយោគលើសញ្ញាប័ណ្ណបៃតង (Green bonds) និងសញ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងនៅតំបន់អឺរ៉ុប ក្នុងគោលដៅរួមចំណែកលើកកម្ពស់ការអនុវត្តតាមគោលនយោបាយវិនិយោគប្រកបដោយការទទួលខុសត្រូវទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ រក្សាបានចីរភាព សុវត្ថិភាពនៃការវិនិយោគទុនបម្រុងអន្តរជាតិនិងស្របតាមនិន្នាការនៃការវិនិយោគសកល។

## ៦- សន្និដ្ឋាន

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២៣ បន្តមានស្ថិរភាពនិងមានតុល្យភាព ដែលឆ្លុះបញ្ចាំងតាមរយៈ ការសម្រេចបានអត្រាកំណើន ៥,៥% ជាមួយនឹងអតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន (២,១%) ហើយអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងកម្រិតមធ្យម ៤.១១០ រៀលក្នុងមួយដុល្លារអាមេរិក។ ទន្ទឹមនេះ ជញ្ជីងទូទាត់នៅមានអតិរេក ២២៦,១ លានដុល្លារអាមេរិក ដែលបានរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដល់ ២០ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

## III- ការគ្រប់គ្រងរូបិយវត្ថុ

### ១- ស្ថានភាពរូបិយវត្ថុ

ក្រាហ្វ ៤១៖ សមាសធាតុ និងកំណើនរូបិយវត្ថុទូទៅ
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ (M2) បានកើនឡើងមកវិញបន្តិចក្នុងអត្រា ១២,៥% បន្ទាប់ពីបានថមថយដល់កម្រិតទាបត្រឹម ៨,២% នាឆ្នាំមុន។ ការកើនឡើងនេះគឺដោយសារប្រាក់បញ្ញើជារៀលកើន ១៤,១% ប្រាក់បញ្ញើជារូបិយប័ណ្ណកើន ១៣% និងរូបិយវត្ថុក្នុងចរាចរណ៍កើន ៥,៩%។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាបន្តមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅស្មើនឹង ៨៣,៤% ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបមានកម្រិត ៩០,៣% និងឥណទានជារូបិយប័ណ្ណធៀបនឹងឥណទានសរុបមានកម្រិត ៨៩,៦%។

### ២- ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ចំនួន ១២ លើកដោយលក់ប្រាក់ដុល្លារអាមេរិកសរុបចំនួន ១៣៩,១ លានដុល្លារអាមេរិក[៦៦]ទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ធៀបនឹងការលក់ ៩ លានដុល្លារអាមេរិកកាលពីឆ្នាំមុន។ ការសម្រេចធ្វើអន្តរាគមន៍នេះគឺដើម្បីរក្សាស្ថិរភាពតម្លៃប្រាក់រៀល និងការពារអំណាចទិញនៃចំណូលរបស់ប្រជាជន បន្ទាប់ពីអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឡើងខ្ពស់ជាងនិន្នាការកន្លងមកគួរឱ្យកត់សម្គាល់។ គួរបញ្ជាក់ថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានពង្រឹងតួនាទីក្នុងទីផ្សារប្តូរប្រាក់ជាលំដាប់ធៀបនឹងអាជីវករប្តូរប្រាក់។ ជាក់ស្តែង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានដេញថ្លៃប្រាក់ដុល្លារអាមេរិកពីធនាគារជាតិនៃកម្ពុជាបានចំនួន ៧៣% នៃទំហំទឹកប្រាក់ដែលធនាគារជាតិនៃកម្ពុជាធ្វើអន្តរាគមន៍សរុប ធៀបនឹង ២៧% ដែលដេញថ្លៃបានដោយអាជីវករប្តូរប្រាក់។ និន្នាការនេះមានការប្រែប្រួលចាប់ពីឆ្នាំ២០១៦មក ដែលពីពេលមុន ភាគច្រើននៃទឹកប្រាក់ដេញថ្លៃបានទៅលើអាជីវករប្តូរប្រាក់។ ដោយឡែក ការទិញសុទ្ធជាមួយស្ថាប័នរដ្ឋមានចំនួន ១៥,១ លានដុល្លារអាមេរិក (ទិញ ៣០,៤ លានដុល្លារអាមេរិក) ធៀបនឹងការលក់សុទ្ធ ៣០,៩ លានដុល្លារអាមេរិក (ទិញ ២៣,១ លានដុល្លារអាមេរិក) កាលពីឆ្នាំ២០២២។

---

[៦៦] ក្នុងឆ្នាំ២០២៣នេះ មានការអន្តរាគមន៍ ១២ លើក (២ លើកក្នុង១សប្តាហ៍) ចាប់ផ្តើមពីខែកញ្ញា ដល់សប្តាហ៍ពាក់កណ្តាលខែតុលា ដោយនៅខែកញ្ញាមានការលក់ប្រាក់ដុល្លារអាមេរិក ៩៩,១ លានដុល្លារអាមេរិក និង ៤០ លានដុល្លារអាមេរិកនៅខែតុលា។

### ក្រាហ្វ ៤២៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ៤៣៖ ការទិញលក់ប្រាក់ដុល្លារអាមេរិកជាមួយស្ថាប័នរដ្ឋ

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ក្រាហ្វ ៤៤៖ អន្តរាគមន៍ទិញ-លក់ប្រាក់ដុល្លារអាមេរិក

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៤ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រូវបានដំឡើងពី ៧% ដល់ ៩% នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ហើយបានបន្ថយចុះមក ៧% នៅខែធ្នូ ឆ្នាំ២០២៣ ស្របតាមស្ថានភាពសេដ្ឋកិច្ច ជាពិសេស ដើម្បីរក្សាសន្ទនីយភាពខ្ពស់ដល់គ្រឹះស្ថានធនាគារសម្រាប់ទ្រទ្រង់កំណើន។ ចំណែកឯអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលត្រូវបានរក្សាក្នុងកម្រិត ៧% ចាប់តាំងពីខែមីនា ឆ្នាំ២០២០ មក។ បច្ចុប្បន្ន ប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិកមានចំនួន ៣,៩ ប៊ីលានដុល្លារអាមេរិក (១៥,៩ ទ្រីលានរៀល) និងជារៀលមានចំនួន ១,៥ ទ្រីលានរៀល (៣៧៣,២ លានដុល្លារអាមេរិក) ដោយមាននិន្នាការកើនឡើង ១៦% និង ១៧% រៀងគ្នាធៀបនឹងឆ្នាំ២០២២។

ក្រៅពីប្រាក់បម្រុងកាតព្វកិច្ច គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏មានសន្ទនីយភាពលើសនៅធនាគារជាតិនៃកម្ពុជាផងដែរ។ សន្ទនីយភាពលើសជាដុល្លារអាមេរិកមានចំនួន ៥,៦ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១៤៣% នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក។ សន្ទនីយភាពលើសជារៀលមានចំនួន ៥,១ ទ្រីលានរៀល ស្មើនឹង ៣,៤ ដង នៃប្រាក់បម្រុងកាតព្វកិច្ចជារៀល។ ភាពលើសនេះ បង្ហាញពីសមត្ថភាពបន្ថែមដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចផ្តល់ហិរញ្ញប្បទានដល់សេដ្ឋកិច្ចបាន។

**ក្រាហ្វ ៤៥៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**

(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៣ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៦៖ សន្ទនីយភាពលើសជារៀល និងដុល្លារអាមេរិក**

(គិតជាទ្រីលានរៀល ខែមករា ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៧៖ អនុបាតសន្ទនីយភាពលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងដុល្លារអាមេរិក**

(ខែមករា ឆ្នាំ២០២១ - ខែធ្នូ ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- មូលបត្រអាចជួញដូរបាន

មូលបត្រអាចជួញដូរបាន (NCD) ត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយរូបិយវត្ថុ ដើម្បីស្រូបយកសន្ទនីយភាពដែលលើសពីប្រព័ន្ធធនាគារ។ NCD ក៏អាចប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការខ្ចីប្រាក់ពីធនាគារជាតិនៃកម្ពុជា និងទីផ្សារអន្តរធនាគារផងដែរ។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០២៣ វិធីសាស្ត្រនៃការបោះផ្សាយ NCD ត្រូវបានផ្លាស់ប្តូរពីការបោះផ្សាយតាមតម្រូវការទៅជាការដេញថ្លៃ ដែលធនាគារជាតិនៃកម្ពុជាកំណត់ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ និងអត្រាការប្រាក់អតិបរមា។

ការចេញផ្សាយ NCD ជារៀល ត្រូវបានកាត់បន្ថយគួរកត់សម្គាល់ក្នុងអំឡុងដើមឆ្នាំ ដោយសារកំណើនតម្រូវការប្រាក់រៀលនៅលើទីផ្សារសម្រាប់ការបង់ពន្ធនិងការប្រមូលកសិផល។ ក៏ប៉ុន្តែ ចាប់ពីខែសីហាមក ធនាគារជាតិនៃកម្ពុជាបានបង្កើនការស្រូបយកប្រាក់រៀលពីប្រព័ន្ធធនាគារក្នុងរង្វង់ ១,៣-២,៦ ទ្រីលានរៀលក្នុង១ខែ ធៀបនឹង ៣០០-៥០០ ប៊ីលានរៀលប៉ុណ្ណោះក្នុង១ខែ នៅខែមីនា-កក្កដា ដើម្បីរួមចំណែកកាត់បន្ថយសម្ពាធថយថ្លៃនៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។ ស្របពេលជាមួយគ្នានេះ NCD ជារៀលដែលមិនទាន់ដល់ឥណប្រតិទានក៏មាននិន្នាការកើនឡើងគួរកត់សម្គាល់ដល់ប្រមាណ ២ ទ្រីលានរៀលនៅខែកញ្ញា មុននឹងថយចុះមកវិញបន្តិចត្រឹម ១,៣ ទ្រីលានរៀលនៅចុងឆ្នាំ២០២៣នេះ។ អត្រាការប្រាក់ NCD ជារៀលជាមធ្យមបានថយចុះពី ១,៣៥% នៅឆ្នាំមុន មក ០,៩៤% ក្នុងនោះមាន NCD ៧ថ្ងៃថយពី ០,៨៣% មក ០,៥៦% NCD ១៤ថ្ងៃថយពី ០,៩៣% មក ០,៦២% NCD ២៨ថ្ងៃថយពី ១,០២% មក ០,៨៦% NCD ៩១ថ្ងៃថយពី ១,៥៧% មក ១,៣៣% NCD ១៨២ថ្ងៃថយពី ១,៧៧% មក ១,០៣% និង NCD ៣៦៤ថ្ងៃថយពី ១,៩៧% មក ១,២៣%។

**ក្រាហ្វ ៤៨ ៖ ចំនួនទឹកប្រាក់ NCD ជារៀល ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(គិតជាទ្រីលានរៀល, ខែមករា - ខែធ្នូ ឆ្នាំ២០២៣)




**ក្រាហ្វ ៤៩ ៖ អត្រាការប្រាក់ NCD ជារៀល**
(គិតជាភាគរយ, ឆ្នាំ២០២២ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ចំណែកឯការបោះផ្សាយ NCD ជាដុល្លារអាមេរិកបានធ្លាក់ចុះពីជិត ៨០០ លានដុល្លារអាមេរិក នៅខែកុម្ភៈ ឆ្នាំ២០២៣ មកត្រឹមក្រោម ២០០ លានដុល្លារអាមេរិកចាប់ពីខែកញ្ញាមក។ ទន្ទឹមនេះ NCD ជាដុល្លារអាមេរិកដែលមិនទាន់ដល់ឥណប្រតិទានបានថយចុះជាលំដាប់ ពី ១,៦ ប៊ីលានដុល្លារអាមេរិក មកត្រឹម ៨០០ លានដុល្លារអាមេរិក។ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក បានថយចុះពី ១,៦៥% នៅឆ្នាំ២០២២ មក ១,០៧% ជាមធ្យម ដែលក្នុងនោះ NCD ៧ថ្ងៃថយពី ១,២៨% មកត្រឹម ០,៧៤% NCD ១៤ថ្ងៃថយពី ១,៣២% មក ០,៧៨% NCD ២៨ថ្ងៃថយពី ១,៤០% មក ០,៨៦% NCD ៩១ថ្ងៃ ថយពី ១,៦៧% មក ១,២៩% NCD ១៨២ថ្ងៃថយពី ១,៩៦% មក ១,៣៧% និង NCD ៣៦៤ថ្ងៃថយពី ២,២៧% មក ១,៣៩%។ ការថយចុះនេះបណ្តាលមកពីការកាត់បន្ថយចំនួនទឹកប្រាក់ជាដុល្លារអាមេរិក ដែលស្រូបដោយធនាគារជាតិនៃកម្ពុជា។

**ក្រាហ្វ ៥០ ៖ ចំនួនទឹកប្រាក់ NCD ជាដុល្លារអាមេរិក ដែលបានចេញផ្សាយ និងមិនទាន់ដល់ឥណប្រតិទាន**
(គិតជាលានដុល្លារអាមេរិក, ខែមករា-ធ្នូ ឆ្នាំ២០២៣)




**ក្រាហ្វ ៥១៖ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក**
(គិតជាភាគរយ, ឆ្នាំ២០២២ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- ការបោះផ្សាយមូលបត្ររដ្ឋ

នាឆ្នាំ២០២៣នេះ មូលបត្ររដ្ឋត្រូវបានបោះផ្សាយចំនួន ១២ លើក ដែលមានទឹកប្រាក់ចំនួន ២២៤ ប៊ីលានរៀល (៥៤,៥ លានដុល្លារអាមេរិក) ដែលទាបជាងការគ្រោងទុក (៨១៣ ប៊ីលានរៀល ឬ២០០ លានដុល្លារអាមេរិក) ដោយអត្រាគូប៉ុងជាមធ្យម ៣,៨៥% តាមរយៈការដេញថ្លៃនៅលើផ្លែតហ្វម NBCP។ មូលបត្ររដ្ឋដែលមានឥណប្រតិទាន ១ឆ្នាំមានអត្រាចំណូល ៣,៦% - ៣,៩% និងឥណប្រតិទាន ២ឆ្នាំមានអត្រាចំណូល ៤% - ៤,៦% ហើយឥណប្រតិទាន ៣ឆ្នាំមានអត្រាចំណូល ៤,៥% - ៥,២%។

**ក្រាហ្វ ៥២៖ មូលបត្ររដ្ឋដែលបានដេញថ្លៃ**
(ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការបោះផ្សាយមូលបត្ររដ្ឋ នឹងរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុក្នុងស្រុកបន្ថែមទៀត ក៏ដូចជាលើកកម្ពស់ការអនុវត្តនយោបាយរូបិយវត្ថុ ផ្អែកលើយន្តការទីផ្សារ និងជួយជំរុញការប្រើប្រាស់ប្រាក់រៀលនៅកម្ពុជា។

**តារាង ១ ៖ ការបោះផ្សាយមូលបត្ររដ្ឋ**

| លើកទី | កាលបរិច្ឆេទ | ទឹកប្រាក់សរុប (ប៊ីលានរៀល) | ឥណប្រតិទាន | អត្រាការប្រាក់មធ្យម |
|---|---|---|---|---|
| ១ | ២៥-មករា-២៣ | ២៤ | ១ឆ្នាំ | ៣,៦% |
| ២ | ២៤-កុម្ភៈ-២៣ | ៧២ | ២ឆ្នាំ | ៤,១% |
| ៣ | ២៤-មីនា-២៣ | ៤ | ៣ឆ្នាំ | ៤,៥% |
| ៤ | ២១-មេសា-២៣ | ៤ | ១ឆ្នាំ | ៣,៦% |
| ៥ | ២៦-ឧសភា-២៣ | ៤ | ២ឆ្នាំ | ៤% |
| ៦ | ១៦-មិថុនា-២៣ | ៤ | ៣ឆ្នាំ | ៥% |
| ៧ | ២១-កក្កដា-២៣ | ២៨ | ១ឆ្នាំ | ៣,៧% |
| ៨ | ១៨-សីហា-២៣ | ២៨ | ២ឆ្នាំ | ៤,២៨% |
| ៩ | ២២-កញ្ញា-២៣ | ៨ | ៣ឆ្នាំ | ៥,២% |
| ១០ | ២០-តុលា-២៣ | ២០ | ១ឆ្នាំ | ៣,៨៥% |
| ១១ | ២៤-វិច្ឆិកា-២៣ | ២៨ | ២ឆ្នាំ | ៤,៤៩% |
| ១២ | ២២-ធ្នូ-២៣ | ៦ | ៣ឆ្នាំ | ៤,៦៧% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៦- ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា

ធនាគារជាតិនៃកម្ពុជាបានផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) សរុបចំនួន ២,៥ ទ្រីលានរៀល (ប្រមាណ ៦០៥,១ លានដុល្លារអាមេរិក)។ នាឆ្នាំ២០២៣នេះ ចំនួនទឹកប្រាក់ដេញថ្លៃឈ្នះបានកើនឡើងពីខែមករាដល់ខែមេសា ប៉ុន្តែបានថយចុះចាប់ពីខែឧសភាមក ដោយសារការបន្ថយទឹកប្រាក់ដេញថ្លៃរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីរួមចំណែកគ្រប់គ្រងសម្ពាធធ្លាក់ថ្លៃនៃប្រាក់រៀល។ LPCO

**ក្រាហ្វ ៥៣៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

៧ថ្ងៃ[២៧] បានចាប់ផ្តើមដាក់ឱ្យដេញថ្លៃកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ ដើម្បីផ្តល់សន្ទនីយភាពជារៀលជាមួយឥណប្រតិទានកាន់តែខ្លី សម្រាប់បំពេញសេចក្តីត្រូវការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ចំនួនទឹកប្រាក់ដែលផ្តល់ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលចូលរួមដេញថ្លៃក្នុងប្រតិបត្តិការ LPCO មាន៖ LPCO ៧ថ្ងៃមាន ៦៤ ប៊ីលានរៀល, LPCO ៩១ថ្ងៃមាន ៧៣០,៩ ប៊ីលានរៀល, LPCO ១៨២ថ្ងៃមានចំនួន ១,៥ ទ្រីលានរៀល និង LPCO ៣៦៤ថ្ងៃមានចំនួន ២០៧ ប៊ីលានរៀល។

អត្រាការប្រាក់ជាមធ្យមសម្រាប់ LPCO ៧ថ្ងៃមានកម្រិត ៣% LPCO ៩១ថ្ងៃមានកម្រិត ៤,៩% (ថយចុះពី ៥,៥% កាលពីឆ្នាំ២០២២) LPCO ១៨២ថ្ងៃមានកម្រិត ៥,៣% (ថយចុះពី ៥,៨%) និង LPCO ៣៦៤ថ្ងៃមានកម្រិត ៤% (ថយចុះពី ៦%)។ ការថយចុះអត្រាការប្រាក់ LPCO បណ្តាលមកពីការថយចុះនៃតម្រូវការខ្ចីប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធៀបនឹងឆ្នាំមុន។

**ក្រាហ្វ ៥៤ ៖ ការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO ប្រចាំឆ្នាំ**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៨ - ២០២៣)




**ក្រាហ្វ ៥៥ ៖ អត្រាការប្រាក់ដេញថ្លៃឈ្នះប្រតិបត្តិការ LPCO ប្រចាំខែ**
(គិតជាភាគរយ, ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៧- ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី

ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី គឺជាឧបករណ៍បម្រុងសម្រាប់ផ្តល់សន្ទនីយភាពជាប្រាក់រៀលពីធនាគារជាតិនៃកម្ពុជា ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅគ្រប់ពេលដែលមានតម្រូវការរយៈពេលខ្លី ដោយត្រូវមានវត្ថុធានា។ កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានដំឡើងអត្រាការប្រាក់សម្រាប់ MLF ពី ៤% ដល់ ៦% ស្មើនឹងអត្រាឥណទានវិបារូបន៍ (OD) ហើយបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តឥណប្រតិទានប្រតិបត្តិការ MLF ដោយមិនកំណត់ចំនួននិងពេលវេលា។

[២៧] LPCO ៧ថ្ងៃ សំដៅដល់ LPCO ដែលមានឥណប្រតិទាន ៧ថ្ងៃ

## ៨- សន្និដ្ឋាន

ក្នុងឆ្នាំ២០២៣នេះ រូបិយវត្ថុទូទៅបានងើបឡើងវិញបន្តិច ស្របតាមកំណើនសេដ្ឋកិច្ច ដែលគាំទ្រដោយកំណើនប្រាក់បញ្ញើជាប្រាក់រៀលនិងដុល្លារអាមេរិក។ ធនាគារជាតិនៃកម្ពុជាបន្តរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ តាមរយៈការធ្វើអន្តរាគមន៍ លើទីផ្សារប្តូរប្រាក់ ការបង្កើនការស្រូបយកសន្ទនីយភាពជារៀលដោយដាក់ឱ្យដេញថ្លៃ NCD និង បន្ថយការបញ្ចេញសន្ទនីយភាពជារៀលតាមរយៈ LPCO។

## IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជ ៥៨ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៣ គ្រឹះស្ថានឥណទានជនបទ ១១៤ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៦ អ្នកដំណើរការតតិយភាគី ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣៣ គ្រឹះស្ថានផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៥ និងអាជីវកម្មប្តូរប្រាក់ ២.៩១៥។

ក្រាហ្វ ៥៦៖ ទ្រព្យសកម្មប្រព័ន្ធធនាគារ
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ក្រាហ្វ ៥៧៖ ចំណែកទ្រព្យសកម្មប្រព័ន្ធធនាគារ
(គិតជាភាគរយ, ឆ្នាំ២០១៧ - ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ៨,៦% ដល់ ៣៤៦,៧ ទ្រីលានរៀល (៨៤,៣ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះវិស័យធនាគារមានសមាមាត្រ ៩១,៨% វិស័យមីក្រូហិរញ្ញវត្ថុ ៧,៦% និងវិស័យភតិសន្យាហិរញ្ញវត្ថុ ០,៦%។ ឥណទានអតិថិជនកើនឡើង ៤,៨% ដល់ ២៣៧,២ ទ្រីលានរៀល (៥៧,៦ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៣,១% ដល់ ១៩៧,២ ទ្រីលានរៀល (៤៧,៩ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ១០,៦% ដល់ ៣៨ ទ្រីលានរៀល (៩,២ ប៊ីលានដុល្លារអាមេរិក)។

ក្រាហ្វ ៥៨៖ ឥណទានប្រព័ន្ធធនាគារ
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ក្រាហ្វ ៥៩៖ ប្រាក់បញ្ញើប្រព័ន្ធធនាគារ
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ទោះបីជាទទួលរងសម្ពាធពីស្ថានភាពនៃការរឹតត្បិតហិរញ្ញវត្ថុខាងក្រៅ ភាពមិនច្បាស់លាស់ដោយសារភាពតានតឹងភូមិសាស្ត្រនយោបាយ និងការកើនឡើងឥណទានមិនដំណើរការ ប្រព័ន្ធធនាគារបន្តរក្សាបានស្ថិរភាព និងភាពធន់ ដែលឆ្លុះបញ្ចាំងតាមរយៈភាពរឹងមាំនៃសូចនាករហិរញ្ញវត្ថុសំខាន់ៗដូចខាងក្រោម៖



**ក្រាហ្វ ៦០៖ អនុបាតសាធនភាព**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=បឋមស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

i/-ស្ថានភាពដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តមានភាពគ្រប់គ្រាន់ អនុលោមតាមបទប្បញ្ញត្តិ (១៥%) ដោយអនុបាតសាធនភាពវិស័យធនាគារមានកម្រិតជាមធ្យម ២២,៧% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ២៥,៤%។ លើសពីនេះ ទ្រនាប់ដើមទុនត្រូវបានអនុវត្តឡើងវិញនៅកម្រិត ១,២៥% នៃទ្រព្យសកម្មថ្លឹងតាមទម្ងន់ហានិភ័យ ចាប់តាំងពីខែមិថុនា ឆ្នាំ២០២៣ ដើម្បីពង្រឹងភាពធន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការទប់ទល់នឹងវិបត្តិ។

ii/-សន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្តមានកម្រិតខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដោយគ្រឹះស្ថានធនាគារពាណិជ្ជនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានអនុបាតជាមធ្យមក្នុងកម្រិត ១៦៧,៦% និង ៣៣៣,៣% រៀងគ្នា ដែលបង្ហាញពីសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបនឹងតម្រូវការឥណទាន និងតម្រូវការដកប្រាក់បញ្ញើរបស់អតិថិជន។

iii/-អនុបាតឥណទានមិនដំណើរការបន្តកើនឡើង ទន្ទឹមនឹងការថមថយកំណើនឥណទាន ប៉ុន្តែអនុបាតនេះបន្តស្ថិតនៅកម្រិតអាចគ្រប់គ្រងបាន ក្នុងនោះវិស័យធនាគារមានកម្រិត ៥,៤% និងវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ៦,៧%។



**ក្រាហ្វ ៦១៖ អនុបាតគ្របខណ្ឌសន្ទនីយភាព**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)



**ក្រាហ្វ ៦២៖ អនុបាតឥណទានមិនដំណើរការ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)

ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=បឋមស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

iv/-ប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានថយចុះបន្តិច ដោយអនុបាតប្រាក់ចំណេញធៀបទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិក (ROE) របស់វិស័យធនាគារមានកម្រិត ០,៧% និង ៣,៨% រៀងគ្នា ថយចុះពី ១,៤% និង ៧% នៅឆ្នាំ២០២២ ខណៈវិស័យមីក្រូហិរញ្ញវត្ថុមានកម្រិត ១,៥% និង ៦% រៀងគ្នា ថយចុះពី ៣% និង ១៣,៦%។ ការថយចុះនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ គឺបណ្តាលមកពីកំណើនចំណាយសំវិធានធនសម្រាប់ឥណទានមិនដំណើរការ។

**ក្រាហ្វ ៦៣៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




**ក្រាហ្វ ៦៤៖ អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

## ២- វិស័យធនាគារ

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារបានកើនឡើង ១៦,៨% ធៀបនឹងឆ្នាំមុន (១១,៦%) ដល់ ៣១៨,៥ ទ្រីលានរៀល (៧៧,៤ ប៊ីលានដុល្លារអាមេរិក) ដោយឥណទានអតិថិជនកើនឡើង ១៤,៨% ធៀបនឹងឆ្នាំមុន (១៨,២%) ដល់ ២១៣,១ ទ្រីលានរៀល (៥១,៨ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ២,២ លានគណនី។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច ដូចជា៖ ការជួញដូររាយមានចំណែក ១៧,៦% (មានកំណើន ២២,៣%) ការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១៣,៥% (៦,៤%) ការជួញដូរអចលនទ្រព្យ ៩,៨% (១៦,៩%) ការឱ្យខ្ចីជាបុគ្គល ៩,៨% (២៨%) សំណង់ ៩,៥% (១៣,៩%) ការជួញដូរដុំ ៩% (៤,៨%) កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩% (២៣,៧%) កម្មន្តសាល ៤,៤% (១៧,៦%) សណ្ឋាគារនិងភោជនីយដ្ឋាន ៤% (០,៦%) និងផ្សេងៗ ១៣,៤% (១៧,៩%)។ ប្រាក់បញ្ញើបានកើនឡើង ២១,៣% ដល់ ១៨៨,១ ទ្រីលានរៀល (៤៥,៧ ប៊ីលានដុល្លារអាមេរិក) និងមានចំនួន ១៦,៧ លានគណនី។

**ក្រាហ្វ ៦៥៖ ឥណទានគ្រឹះស្ថានធនាគារតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(គិតជាភាគរយ, ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៦៖ ការរួមចំណែកតាមវិស័យក្នុងកំណើនឥណទានគ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




**ក្រាហ្វ ៦៧៖ កំណើនឥណទានគ្រឹះស្ថានធនាគារតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០២២ និងឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

អត្រាការប្រាក់បញ្ញើក្នុងវិស័យធនាគារបានកើនឡើង ដោយប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិក ត្រូវបានប៉ាន់ស្មានថាមានអត្រា ៧,៧% និង ៦,៤៧% រៀងគ្នា ខ្ពស់ជាងអត្រាក្នុងឆ្នាំ២០២២ (៦,៨៨% និង ៥,៣៦% រៀងគ្នា)។ ដោយឡែក អត្រាការប្រាក់ឥណទានជារៀល និងជាដុល្លារអាមេរិកបានថយចុះមកវិញបន្តិច ដោយមានអត្រា ១៣,៣៩% និង ១១,០៨% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ (១៣,៥១% និង ១១,២៤% រៀងគ្នា)។

**ក្រាហ្វ ៦៨៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៥ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះ -៤០,៩%[២៨] ធៀបនឹងឆ្នាំមុន (១៩,៨%) ដល់ ២៦,២ ទ្រីលានរៀល (៦,៤ ប៊ីលានដុល្លារអាមេរិក) ដែលក្នុងនោះឥណទានអតិថិជនបានធ្លាក់ចុះ -៤២,៦% ធៀបនឹងឆ្នាំមុន (២២,៧%) ដល់ ២២,៤ ទ្រីលានរៀល (៥,៤ ប៊ីលានដុល្លារអាមេរិក) ដោយមាន ១,៦ លានគណនី។ ឥណទានទាំងនេះត្រូវបានផ្ដល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចរួមមាន៖ ក្រុមគ្រួសារមានចំណែក ៣០,៨% (ថយ -៤៩,២%) កសិកម្ម ២២,២% (-៣២%) ពាណិជ្ជ-

**ក្រាហ្វ ៦៩៖ ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**
(គិតជាភាគរយ, ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្ដែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

[២៨] បម្រែបម្រួលអវិជ្ជមាននេះ បណ្ដាលមកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រាសាក់ ម.ក "ប្រាសាក់ អិមអេហ្វអាយ ម.ក" បានកម្លាយខ្លួនជាធនាគារពាណិជ្ជ បន្ទាប់ពីបានរួមបញ្ចូលគ្នាជាមួយធនាគារ គូកមីន កម្ពុជា ភីអិលស៊ី និងមានឈ្មោះថ្មីជា "ធនាគារ ខេប៊ីប្រាសាក់ ម.ក"។

កម្មនិងជំនួញ ២០,៣% (-៥២,៤%) សេវាកម្ម ១១,៥% (-៥៤,២%) សំណង់ ៧,១% (-១៣,៤%) ដឹកជញ្ជូន ២,៩% (-៦៤,៦%) កម្មន្តសាល ២,៩% (-១៣,៤%) និងផ្សេងៗ ២,៣% (កើន ៣,៧%)។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុបានទទួលប្រាក់បញ្ញើ ៩,២ ទ្រីលានរៀល (២,២ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ១,៩ លានគណនី។

**ក្រាហ្វ ៧០៖ ការរួមចំណែកតាមវិស័យក្នុងកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៧ - ឆ្នាំ២០២៣ប)




**ក្រាហ្វ ៧១៖ កំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០២២ និងឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ជារួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនមានភាពរឹងមាំ និងអាចធន់នឹងហានិភ័យនានា ដោយគ្រឹះស្ថានបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន អនុលោមតាមច្បាប់និងបទប្បញ្ញត្តិប្រុងប្រយ័ត្ន សេចក្តីណែនាំ និងវិធានការនានាដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ ទោះយ៉ាងណា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនដែលមានទំហំប្រតិបត្តិការតូចៗនៅតែមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងការអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូចនិងមធ្យមជាដើម។ ការខ្វះខាតទាំងនេះ ត្រូវបានត្រួតពិនិត្យជាប្រចាំ ដោយមានការតាមដាននិងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាសនីមួយៗ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការផ្នែករដ្ឋបាល ក៏ដូចជាការពិន័យដល់គ្រឹះស្ថានដែលអនុវត្តមិនស្របតាមបទប្បញ្ញត្តិជាធរមានផងដែរ។

អត្រាការប្រាក់បញ្ញើរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជារៀល និងជាដុល្លារអាមេរិកជាមធ្យម បានកើនឡើងដល់ ៨,៣៩% និង ៨,២៥% រៀងគ្នា ធៀបនឹងឆ្នាំ២០២២ (៧,៤២% និង ៧,៣៨% រៀងគ្នា)។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជាមធ្យមជារៀលនិងជាដុល្លារអាមេរិកក៏បានកើនឡើងផងដែរ ដល់ ១៧,៤៤% និង ១៦,២% រៀងគ្នា ពី ១៦,៨% និង ១៥,០៥% នៅឆ្នាំ២០២២។

**ក្រាហ្វ ៧២៖ អត្រាការប្រាក់ជាមធ្យមរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(គិតជាភាគរយ, ឆ្នាំ២០១៥ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

## ៤- គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានធ្លាក់ចុះ-១,៦%ដល់ ២ទ្រីលានរៀល (៤៨៥,១ លានដុល្លារអាមេរិក)។ ឥណទានភតិសន្យាហិរញ្ញវត្ថុបានធ្លាក់ចុះ -៣,៤% ដល់ ១,៧ ទ្រីលានរៀល(៤២១,៥ លានដុល្លារអាមេរិក) ដោយមាន ៩៣.៣១៨ គណនី ហើយត្រូវបានផ្តល់ទៅវិស័យផ្សេងៗ រួមមាន៖ កសិកម្មមានចំណែក ២៥,៦% ក្រុមគ្រួសារ ២២,៤% សេវាកម្ម ១៩,៧% ដឹកជញ្ជូន ៤,៦% សំណង់ ៤% ពាណិជ្ជកម្មនិងជំនួញ ៣,៥% និងវិស័យផ្សេងៗ ២០,២%។ ប្រភពទុនចម្បងនៃភតិសន្យាហិរញ្ញវត្ថុបានមកពីមូលនិធិភាគទុនិកដែលបានកើនឡើង ៣,៦% ដល់ ៦៦៥,២ ប៊ីលានរៀល (១៦១,៦ លានដុល្លារអាមេរិក)។

ក្រាហ្វ ៧៣៖ ទ្រព្យសកម្មនិងឥណទានវិស័យភតិសន្យាហិរញ្ញវត្ថុ
(គិតជាភាគរយ, ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ជារួម ទោះបីភតិសន្យាហិរញ្ញវត្ថុបានធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំកន្លងមក គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមានភាពធន់នៃដើមទុន កំណើនប្រាក់ចំណេញ ព្រមទាំងបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួនអនុលោមតាមច្បាប់និងបទប្បញ្ញត្តិប្រុងប្រយ័ត្ន សេចក្តីណែនាំ និងវិធានការនានាដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមួយចំនួនដែលមានទំហំប្រតិបត្តិការតូចៗ នៅតែមានចំណុចខ្វះខាត ដែលតម្រូវឱ្យបន្តពង្រឹងបន្ថែមដូចជា ការត្រួតពិនិត្យផ្ទៃក្នុង អភិបាលកិច្ចល្អ និងការអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម ជាដើម។ ការខ្វះខាតទាំងនេះត្រូវបានធ្វើការតាមដានតាមរយៈការត្រួតពិនិត្យជាប្រចាំលើឯកសារ ការពិភាក្សាស្វែងយល់ពីស្ថានភាពនិងក្រើនរំឭក មុនឈានដល់ការពិន័យចំពោះគ្រឹះស្ថានដែលមិនអនុលោមតាមបទប្បញ្ញត្តិ។

## ៥- គ្រឹះស្ថានឥណទានជនបទ

នៅឆ្នាំ២០២៣ គ្រឹះស្ថានឥណទានជនបទចំនួន ១១៤ ទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា ក្នុងការធ្វើប្រតិបត្តិការផ្តល់ឥណទានខ្នាតតូច ដែលឆ្លើយតបទៅនឹងតម្រូវការឥណទានរបស់ប្រជាជននៅតាមតំបន់មូលដ្ឋាន និងទីប្រជុំជននានា។

គ្រឹះស្ថានឥណទានជនបទមានទ្រព្យសកម្មសរុប ២៤៨,៨ ប៊ីលានរៀល (៥៩,៨ លានដុល្លារអាមេរិក) និងបានផ្តល់ឥណទានសរុប ២១៣,២ ប៊ីលានរៀល (៥១,៣ លានដុល្លារអាមេរិក)

ក្រាហ្វ ៧៤៖ ទ្រព្យសកម្មនិងឥណទានគ្រឹះស្ថានឥណទានជនបទ
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

ទៅដល់ ១១៦.០៥៤ គណនីអតិថិជន។ ឥណទានត្រូវបានផ្តល់ទៅកាន់វិស័យនានា រួមមាន៖ កសិកម្មមានចំណែក ៣៥,១% គ្រួសារ ២៨,៣% ពាណិជ្ជកម្ម ១៥,៩% សេវាកម្ម ៦% សំណង់ ៥,៧% ដឹកជញ្ជូន ១,១% និងផ្សេងៗ ៧,៩%។ ការណ៍នេះឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃវិស័យឥណទានជនបទ ដែលជាផ្នែកសំខាន់មួយក្នុងការលើកកម្ពស់ជីវភាពប្រជាជននៅកម្ពុជា ជាពិសេសនៅតាមតំបន់ជនបទ តាមរយៈការផ្តល់លទ្ធភាពបន្ថែមក្នុងការទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ ដែលមានការការពារផ្នែកច្បាប់ និងប្រកបដោយបរិយាបន្ន។

ទន្ទឹមនេះ ការបន្តពង្រឹងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ គឺជាកត្តាចម្បងក្នុងការពង្រឹងគុណភាពនិងសុខុមាលភាពរបស់គ្រឹះស្ថានឥណទានជនបទ ជាពិសេសអាជីវកម្មមានប្រតិបត្តិការជាប្រក្រតី។ ការផ្តល់ប្រាក់កម្ចីសម្រាប់ឥណទានខ្នាតតូចនៅតាមតំបន់ជនបទ និងទីប្រជុំជនមួយចំនួនបានផ្តល់សារៈសំខាន់ក្នុងការផ្គត់ផ្គង់តម្រូវការឥណទាន និងជៀសវាងការប្រើប្រាស់ឥណទានក្រៅប្រព័ន្ធដែលមានអត្រាការប្រាក់ខ្ពស់ និងមិនមានការគាំពារផ្នែកច្បាប់។

ទោះយ៉ាងណា គ្រឹះស្ថានឥណទានជនបទប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ធនធានមនុស្សនៅមានកម្រិត លទ្ធភាពនៃការស្វែងរកប្រភពទុនថ្មី ការប្រកួតប្រជែង និងការចំណាយខ្ពស់លើការរៀបចំហេដ្ឋារចនាសម្ព័ន្ធរបស់គ្រឹះស្ថាន។ ធនាគារជាតិនៃកម្ពុជាបន្តតាមដានកង្វះខាតទាំងនេះយ៉ាងម៉ឺងម៉ាត់ តាមរយៈការត្រួតពិនិត្យជាប្រចាំគ្រា ការប្រឹក្សាផ្តល់យោបល់ ការចេញលិខិតក្រើនរំឭក ព្រមទាំងបានធ្វើការពិន័យ ក៏ដូចជាបានលុបឈ្មោះគ្រឹះស្ថានដែលអនុវត្តមិនស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ចេញពីបញ្ជីរបស់ធនាគារជាតិនៃកម្ពុជា។

## ៦- អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន

បច្ចុប្បន្ន ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី គឺជាអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលមានទ្រព្យសកម្មសរុបប្រមាណ ៨៦,១ ប៊ីលានរៀល (២០,៩ លានដុល្លារអាមេរិក) និងមានគ្រឹះស្ថានជាសមាជិកចំនួន ១៩៤ គ្រឹះស្ថាន។ គិតត្រឹមឆ្នាំ២០២៣ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានចំនួន ៩,៣ លានគណនី (ប្រមាណ ២៣២,៥ ទ្រីលានរៀល ស្មើនឹង ៥៦,៥ ប៊ីលានដុល្លារអាមេរិក) កើន ១២៦.៥១៤ គណនី បើធៀបនឹងឆ្នាំ២០២២ ក្នុងនោះ ១/-ឯកត្តបុគ្គលមានចំនួន ៩,៣ លានគណនី ជាមួយអតិថិជនសរុបចំនួន ៥ លាននាក់ ដោយស្ត្រីមានចំនួន ២,៦ លាននាក់ (៥២,៧%) និង ២/-ក្រុមហ៊ុនមាន ៥.៧២០ គណនី ជាមួយនឹងចំនួនអតិថិជន ១.៦៧៥ ក្រុមហ៊ុន។ ទន្ទឹមនេះ គ្រឹះស្ថានជាសមាជិកបានបញ្ចូលទិន្នន័យមូលប្បទានប័ត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីសរុបមានចំនួន ៧១០ ប្រតិបត្តិការ (៤២៥ គណនី) ប្រមាណ ១៥៥,២ ប៊ីលានរៀល (៣៧,៧ លានដុល្លារអាមេរិក)។

គួរបញ្ជាក់ថា គ្រឹះស្ថានជាសមាជិករបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដែលជាអ្នកផ្តល់ទិន្នន័យ មានកាតព្វកិច្ចត្រូវចូលរួមផ្តល់រាល់ព័ត៌មានឥណទានទាំងវិជ្ជមាននិងអវិជ្ជមាន ព្រមទាំងមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនី ឱ្យបានគ្រប់ជ្រុងជ្រោយនិងត្រឹមត្រូវពេញលេញនិងដែលបានធ្វើបច្ចុប្បន្នកម្ម ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន យ៉ាងតិច ១ ខែម្តង។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យ ក៏មានកាតព្វកិច្ចក្នុងការធានាគុណភាពទិន្នន័យ សុវត្ថិភាពទិន្នន័យ និងសិទ្ធិអតិថិជន ដូចមានចែងនៅក្នុងប្រកាសស្តីពី ការចែករំលែកព័ត៌មានឥណទាន ដែលត្រូវបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា កាលពីឆ្នាំ២០២០។

**ក្រាហ្វ ៧៥៖ ការពិនិត្យរបាយការណ៍ឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

(គិតជាចំនួនពាន់ប្រតិបត្តិការ, ឆ្នាំ២០១៨ - ខែវិច្ឆិកា ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន

បន្ទាប់ពីទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាឱ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ចុះអនុស្សរណៈយោគយល់ជាមួយក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (សិង្ហបុរី) ភីធីអ៊ី អិលធីឌី លើកិច្ចសហការសេវាចែករំលែករបាយការណ៍ឥណទានទ្វេភាគីរវាងកម្ពុជានិងសិង្ហបុរីរួចមក ភាគីទាំងពីរបានឯកភាពលើការកំណត់កម្រៃសេវាចែករំលែករបាយការណ៍ព័ត៌មានឥណទានឆ្លងប្រទេសសម្រាប់ឯកត្តជន។ កិច្ចសហប្រតិបត្តិការក្នុងការចែករំលែករបាយការណ៍ព័ត៌មានឥណទានឆ្លងប្រទេសជាមួយបណ្ដាប្រទេសផ្សេងៗទៀតក្នុងតំបន់នឹងធ្វើឡើងនៅជំហានបន្តបន្ទាប់ទៀត សំដៅសម្រួលដល់ការធ្វើពាណិជ្ជកម្មនិងវិនិយោគ។ ប្រភពទិន្នន័យសំខាន់ៗផ្សេងទៀត ក៏នឹងត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន តាមរយៈកិច្ចសហការជាមួយក្រុមហ៊ុនផ្ដល់សេវាទឹក-ភ្លើង ក្រុមហ៊ុនទូរគមនាគមន៍ គ្រឹះស្ថានផ្ដល់សេវាទូទាត់ និងវិស័យមិនមែនធនាគារ ជាដើម។

លើសពីនេះ ក្រោមកិច្ចសម្របសម្រួលរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ធនាគារជាតិនៃកម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការទទួលស្វាគមន៍គណៈប្រតិភូមកពីធនាគារកណ្ដាលនៃប្រទេសប៉ាពួអាស៊ីនូវែលហ្គីណេ កោះសូឡូម៉ូន និងប្រទេសវ៉ានូអាទូ ដែលបានមកបំពេញទស្សនកិច្ចផ្លូវការកាលពីដើមខែតុលា ឆ្នាំ២០២៣ ក្នុងគោលបំណងស្វែងយល់ និងសិក្សារៀនសូត្រអំពីបទ-ពិសោធន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការបង្កើត ការដាក់ឱ្យដំណើរការ និងការត្រួតពិនិត្យគ្រឹះស្ថានផ្ដល់សេវាប្រព័ន្ធចែករំលែកឥណទាន។

ធនាគារជាតិនៃកម្ពុជាបន្តតាមដាន និងត្រួតពិនិត្យលើប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ព្រមទាំងទិន្នន័យរបស់គ្រឹះស្ថានជាសមាជិក (អ្នកផ្ដល់ទិន្នន័យ) ដែលរាយការណ៍ប្រចាំគ្រាដោយគ្រឹះស្ថានផ្ដល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានពាក់ព័ន្ធនឹងការអនុវត្តស្របតាមខ្លឹមសារបទប្បញ្ញត្តិជាធរមាន ដើម្បីធានាគុណភាពទិន្នន័យ និងនិរន្តរភាពនៃដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាននៅកម្ពុជា។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតឱ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ផ្ទៀងផ្ទាត់ទិន្នន័យគណនីឥណទានអតិថិជនដែលគ្រឹះស្ថានបានធ្វើការឆ្លើយតបចំពោះគណនីអតិថិជនដែលមិនបានប្រើប្រាស់របាយការណ៍ឥណទាន (Non-enquiry Loan Account) ជាប្រចាំខែ ដើម្បីធានាសុក្រឹតភាពទិន្នន័យ បន្ថែមពីលើការឆ្លើយតបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាអ្នកផ្ដល់ទិន្នន័យមកធនាគារជាតិនៃកម្ពុជា។

## ៧- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការតាមដានជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុ ភាពធន់ និងស្ថិរភាពនៃប្រព័ន្ធទាំងមូល ជាពិសេសការអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជារបស់សភាពការណ៍ពិភពលោកនាពេលបច្ចុប្បន្ន។ ការត្រួតពិនិត្យត្រូវបានអនុវត្តតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត ដើម្បីបង្កើនប្រសិទ្ធភាពត្រួតពិនិត្យបន្ថែមទៀតតាមរយៈលទ្ធភាពកំណត់ជាមុននូវហានិភ័យនានាគួបផ្សំនឹងទស្សនៈអនាគត ដើម្បីអាចចាត់វិធានការត្រួតពិនិត្យនិងកែតម្រូវបានទាន់ពេលវេលា។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់វិធីសាស្ត្រស្រប ដើម្បីធ្វើការវិភាគទាំងផ្នែកបរិមាណនិងគុណភាព និងវិនិច្ឆ័យដោយហ្មត់ចត់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីដាក់ចេញអនុសាសន៍ និងកំណត់ជាក់លាក់អំពីតម្រូវការដើមទុន សន្ទនីយភាព និងការកំណត់មុខសញ្ញាសម្រាប់រៀបចំផែនការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បន្ថែមពីនេះ ការត្រួតពិនិត្យក៏រួមបញ្ចូលការធ្វើស្ត្រេសតេស្ត និងស្ត្រេសតេស្តត្រឡប់លើអនុបាតសាធនភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាព ឥណទានរៀបចំឡើងវិញជាដើម ដើម្បីវាយតម្លៃលើស្ថានភាពដើមទុននិងភាពធន់របស់គ្រឹះស្ថាននីមួយៗ។

នៅឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារពាណិជ្ជចំនួន ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ២ គ្រឹះស្ថានឥណទានជនបទចំនួន ២ និងអាជីវកម្មប្តូរប្រាក់ចំនួន ៤ ដោយផ្តោតលើអភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុង គុណភាពទ្រព្យសកម្ម ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងសន្ទនីយភាព និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើន នៅតែរក្សាបានភាពធន់នៃសន្ទនីយភាពនិងដើមទុនមានអភិបាលកិច្ចល្អ ការគ្រប់គ្រងហានិភ័យឥណទានប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ និងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិ។ ទោះយ៉ាងណា គ្រឹះស្ថានមួយចំនួនតូចនៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងអភិបាលកិច្ច ការត្រួតពិនិត្យផ្ទៃក្នុងនិងការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានជារូបិយវត្ថុជាតិ និងការមិនអនុវត្តបានពេញលេញតាមអនុសាសន៍ដែលដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ កង្វះខាតទាំងនេះត្រូវបានត្រួតពិនិត្យជាប្រចាំ ដោយការតាមដាននិងវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាសនីមួយៗ និងការពិភាក្សាស្វែងយល់ពីស្ថានភាពមុនអនុវត្តវិធានការរដ្ឋបាល ចំពោះគ្រឹះស្ថាននានាដែលមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិផងដែរ។

## ៨- ការរៀបចំបទប្បញ្ញត្តិ

ដើម្បីពង្រឹងភាពធន់និងធានាវឌ្ឍនភាពនៅក្នុងប្រព័ន្ធធនាគារ ក្នុងឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាស និងបទប្បញ្ញត្តិមួយចំនួន ដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ដូចជា៖ i/-ប្រកាសស្តីពី ប្រាក់បម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ii/-លិខិតជូនដំណឹងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ស្តីពី ការអនុវត្តឡើងវិញនូវអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ iii/-លិខិតជូនដំណឹងទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្តីពី ការហាមឃាត់ទទួលយកអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅសម្រាប់ការធានាលើការផ្តល់ឥណទាន។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសនិងសេចក្តីណែនាំ ទាក់ទងនឹងក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ចំនួន ៣ រួមមាន៖ i/-ប្រកាសស្តីពី ដើមទុនបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ii/-ប្រកាសស្តីពី ហានិភ័យឥណទានសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង iii/-សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ដើមទុនបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ដោយពិនិត្យឃើញពីស្ថានភាពអូសបន្លាយនៃផលប៉ះពាល់អវិជ្ជមាននៃវិបត្តិជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាស្ថានភាពចំណូលនៃអតិថិជនប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានសម្រេចដាក់ចេញនូវការអនុគ្រោះផ្នែកបទប្បញ្ញត្តិមួយចំនួនបន្ថែមទៀត សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត រួមមាន៖ i/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិនត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ iii/-អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើសំវិធានធនបន្ថែម រយៈពេល ១២ខែ និង iv/-លើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ចំពោះវិស័យអចលនទ្រព្យ ជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយត្រូវគោរពតាមបទប្បញ្ញត្តិដែលមានជាធរមាន។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញប្រកាសនិងសេចក្តីណែនាំពាក់ព័ន្ធនឹងក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ចំនួន ៤ បន្ថែមទៀត រួមមាន៖ i/-ប្រកាសស្តីពី ហានិភ័យប្រតិបត្តិការសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ii/-ប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ iii/-ប្រកាសស្តីពី អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង iv/-សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំប្រកាសមួយចំនួនបន្ថែមទៀត រួមមាន៖ i/-ប្រកាសស្តីពី ក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ii/-ប្រកាស ស្តីពី នីតិវិធីជាបទដ្ឋានសម្រាប់សកម្មភាពកែតម្រូវបន្ទាន់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ប្រកាស ស្តីពី អនុបាតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ iv/-ប្រកាសស្តីពី ការកំណត់ពិដានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង v/-ប្រកាសស្តីពី ការគូប សរុបផ្នែកបទប្បញ្ញត្តិ ព្រមទាំងសេចក្តីណែនាំ ស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃ លើអ៊ីមភែរមិន។

## ៩- ការរួមចំណែករបស់ប្រព័ន្ធធនាគារក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយចីរភាព

ធនាគារជាតិនៃកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំគំនិតផ្តួចផ្តើម និងដាក់ចេញ យុទ្ធសាស្ត្រមួយចំនួន ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព ស្របតាមទិសដៅអភិវឌ្ឍន៍របស់ រាជរដ្ឋាភិបាល ដែលបានកំណត់យកបញ្ហាថាមពល អាកាសធាតុ និងបរិស្ថាន ជារបៀបវារៈគោល- នយោបាយអាទិភាពមួយ ដូចដែលបានឆ្លុះបញ្ចាំងក្នុង "ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ កម្ពុជា ២០១៤-២០២៣", "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" និង "យុទ្ធសាស្ត្រចក្រាវិស័យ បរិស្ថាន ២០២៣-២០២៨"។ គំនិតផ្តួចផ្តើម និងការដាក់ចេញយុទ្ធសាស្ត្រទាំងនោះ រួមមាន៖ i/-ការគាំទ្រ ការដាក់ចេញគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់សមាគមធនាគារនៅកម្ពុជា ដើម្បីឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ចូលរួមអនុវត្ត ii/-ការរៀបចំក្របខ័ណ្ឌសហប្រតិបត្តិការរវាង ធនាគារជាតិនៃកម្ពុជា ក្រសួងបរិស្ថាន និងសមាគមធនាគារនៅកម្ពុជា ដើម្បីចែករំលែកព័ត៌មាន និង បង្កើតឱ្យមានគំនិតផ្តួចផ្តើមនានា សម្រាប់សកម្មភាពទប់ទល់ការប្រែប្រួលអាកាសធាតុ iii/-ការលើក ទឹកចិត្តផ្នែកបទប្បញ្ញត្តិចំពោះគម្រោងផ្តល់ឥណទានបៃតង និង iv/-ការបណ្តុះបណ្តាលនិងកសាង សមត្ថភាពទៅលើហិរញ្ញវត្ថុប្រកបដោយចីរភាព និងការការពារហានិភ័យបណ្តាលមកពីការប្រែប្រួល អាកាសធាតុ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិតាមរយៈគំនិតផ្តួចផ្តើម និងកិច្ចពិភាក្សា ជាមួយស្ថាប័នមួយចំនួន ដូចជា បណ្តាញធនាគារកណ្តាលនិងអាជ្ញាធរត្រួតពិនិត្យ សម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង (NGFS) ក្រុមការងារបរិយាបន្នហិរញ្ញវត្ថុបៃតង (IGFWG) គម្រោង ភាពជាដៃគូសម្រាប់សកម្មភាពសេដ្ឋកិច្ចបៃតងរបស់អង្គការសហប្រជាជាតិ (UN PAGE) និងក្រុម ការងារអាស៊ានលើកិច្ចការបណ្តាញធនាគារនិងហិរញ្ញវត្ថុប្រកបដោយចីរភាព (ASEAN Taskforce on Sustainable Finance and Sustainable Banking Network)។ ធនាគារជាតិនៃកម្ពុជាក៏បានសហការ ជាមួយអង្គការជាច្រើន ដូចជា គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ (UNESCAP), សម្ព័ន្ធសម្រាប់បរិយាបន្នហិរញ្ញវត្ថុ (AFI) សាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងកិច្ចការពង្រឹងការចូលរួមផ្តល់ហិរញ្ញប្បទានបៃតង ព្រមទាំងបានវិនិយោគ ទុនបម្រុងអន្តរជាតិមួយផ្នែកលើសញ្ញាបណ្ណបៃតង និងបានក្លាយជាសមាជិកនៃគណៈកម្មការពិគ្រោះ យោបល់សម្រាប់មូលនិធិបៃតងក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០២២ ផងដែរ។

ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗបន្ថែមទៀតក្នុងគោលដៅបង្កើត ឱ្យមានយន្តការគាំទ្រ និងប្រព័ន្ធអេកូឡូស៊ីចាំបាច់ ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព និង

សកម្មភាពជាសារវន្តក្នុងការការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ កិច្ចការទាំងនោះរួមមាន៖ i/-ការបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាព (Sustainable Finance Roadmaps) ii/-ការបង្កើតប្រព័ន្ធវគ្គករសាស្ត្រសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាព (Sustainable Finance Taxonomy) iii/-ការរៀបចំយន្តការរាយការណ៍ស្តីពីហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីតម្លាភាព និងការទទួលខុសត្រូវ (Reporting and Disclosure Framework) iv/-ការកសាងសមត្ថភាព និងចំណេះដឹង ដល់វិស័យធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ (Capacity Building and Awareness Raising) និង v/-ការពង្រឹងក្របខ័ណ្ឌវាយតម្លៃ និងវិភាគហានិភ័យ បណ្តាលមកពីការប្រែប្រួលអាកាសធាតុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (Climate Risks Assessment and Analysis) ជាដើម។

គួររំលេចថា នាខែធ្នូ ឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយ UNESCAP ដើម្បីសហការរៀបចំបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់កម្ពុជា (Sustainable Finance Roadmaps) ក្នុងគោលដៅដាក់ចេញនូវទស្សនវិស័យ និងគំនិតផ្តួចផ្តើមចាំបាច់ ក្នុងការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា និងពង្រឹងបន្ថែមទៀតនូវការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុជាតិ ឱ្យកាន់តែមានភាពធន់ ស្ថិរភាព និងអាចចូលរួមក្នុងការកៀរគរហិរញ្ញប្បទានសម្រាប់សកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនេះ សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី១០ ស្តីពី "ហានិភ័យអាកាសធាតុ និងអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង" ត្រូវបានសហការរៀបចំជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ប្រចាំកម្ពុជា ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងការពិភាក្សាលើប្រធានបទខាងលើ សំដៅផ្តល់ជាធាតុចូលដល់ការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព។

## ១០- ការខារបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

បរិយាបន្នហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុផ្លូវការដល់ប្រជាជន និងអាជីវកម្ម ព្រមទាំងបានរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេស។ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមបន្ថែមនូវសកម្មភាពនិងយុទ្ធនាការនានា និងអនុវត្តការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ដូចជាកិច្ចការពារអតិថិជន ព្រមទាំងបានសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នជាតិនិងអន្តរជាតិពាក់ព័ន្ធ ដើម្បីលើកកម្ពស់កម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ស្របតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។



ប្រភព៖ ធនាគារជាតិនៃកម្ពុជា, *ប=ប៉ាន់ស្មាន
(ទិន្នន័យជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣)

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ១៨,៩ លានគណនី និងគណនីឥណទាន

អតិថិជនដល់ ៣,៩ លានគណនី។ ទីស្នាក់ការកណ្តាល និងសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៧៣៨ ទីតាំង និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៥.៥០៤ ម៉ាស៊ីន។ បើគិតតាមវិស័យនីមួយៗ ទីស្នាក់ការកណ្តាលនិងសាខារបស់គ្រឹះស្ថានធនាគារមាន ១.៧៦២ ទីតាំង និងម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ(ATM) មាន ៥.២៨៤ ហើយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានបណ្តាញប្រតិបត្តិការគ្របដណ្តប់ទូទាំងប្រទេស ដោយមានការិយាល័យចំនួន ៩១២ ទីតាំង និងបានធ្វើទំនើបកម្មលើសេវាកម្ម ដូចជា ឥណទានប្រាក់បញ្ញើ ការផ្ទេរប្រាក់ ធនាគារចល័ត និងការដកនិងដាក់ប្រាក់តាមម៉ាស៊ីន ATM ជាដើម ដែលធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបានកាន់តែច្រើន។ ជាមួយគ្នានេះ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមានទីស្នាក់ការកណ្តាល និងសាខា ចំនួន ៦៤ ទីតាំង។

### ១១- កិច្ចសហការបញ្ជូនព័ត៌មាន

ក្នុងការចូលរួមចំណែកបំពេញការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ ការប្រមូលពន្ធជូនរដ្ឋ និងដោះស្រាយបណ្តឹងផ្សេងៗ ធនាគារជាតិនៃកម្ពុជាបានទទួលការស្នើសុំកិច្ចសហការសម្របសម្រួលក្នុងការស្រាវជ្រាវ ការបង្កក និងការលើកលែងការបង្កក។ នៅឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានទទួលសំណើសុំសរុបចំនួន ៣៩០ ករណី ក្នុងនោះ សាលាដំបូងរាជធានី-ខេត្ត ១៤៨ ករណី អគ្គនាយកដ្ឋានពន្ធដារ ១៨៤ ករណី ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ៥៤ ករណី និងស្ថាប័នផ្សេងៗ ៤ ករណី។ ធនាគារជាតិនៃកម្ពុជាបានចេញដីកាបញ្ជូនចំនួន ១៥៧ និងលិខិតឆ្លើយតបទៅនឹងសំណើសុំចំនួន ៣៨៥។ ទន្ទឹមនេះ សំណើសុំមួយចំនួនទៀតរបស់ស្ថាប័នតុលាការ និងអគ្គស្នងការដ្ឋានបានស្នើសុំដោយផ្ទាល់ទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានចំនួន ៥៧៩ ករណី។

### ១២- សន្និដ្ឋាន

ប្រព័ន្ធធនាគារកម្ពុជាបានបន្តរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈកំណើនទ្រព្យសកម្ម និងប្រាក់បញ្ញើអតិថិជន បើទោះបីជាកំណើនឥណទានបានថយចុះគួរឱ្យកត់សម្គាល់ ដោយសារការងើបឡើងទន់ខ្សោយនៃវិស័យមួយចំនួនក៏ដោយ។ កម្រិតខ្ពស់នៃអនុបាតសាធនភាព និងអនុបាតក្របខ័ណ្ឌសន្ទនីយភាពក៏បានបង្ហាញពីស្ថិរភាពនិងភាពរឹងមាំនៃប្រព័ន្ធធនាគារកម្ពុជា ដែលផ្តល់លទ្ធភាពដល់ការអនុគ្រោះផ្នែកបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួន សំដៅជំរុញការងើបឡើងនៃវិស័យ ដែលនៅទទួលរងផលប៉ះពាល់ពីឥទ្ធិពលដក់សល់នៃវិបត្តិកូវីដ-១៩។ ទោះយ៉ាងណា ក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ការត្រួតពិនិត្យប្រព័ន្ធធនាគារត្រូវបានបន្តពង្រឹងស្របពេលដែលកិច្ចការពារអតិថិជននិងចំណេះដឹងហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាប់ជាប្រចាំផងដែរ។

## V- ការផ្គត់ផ្គង់សេវាធនាគារកណ្ដាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

#### ក. ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់សងប្រាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍ និងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ជាបន្តបន្ទាប់។ ជាក់ស្តែង ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រព័ន្ធនេះបានរួមចំណែកសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន តាមរយៈការប្រើប្រាស់ប័ណ្ណឥណពន្ធបានលើគ្រប់ម៉ាស៊ីន ATM/POS របស់គ្រឹះស្ថានសមាជិក ប្រកបដោយសុវត្ថិភាព និងភាពងាយស្រួលសម្រាប់សាធារណជន។ ជាមួយគ្នានេះ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើប្រតិបត្តិការតាមប័ណ្ណឥណពន្ធលើម៉ាស៊ីន ATM/POS ទូទាំងប្រទេសកម្ពុជា គ្រឹះស្ថានសមាជិកប្រព័ន្ធ CSS ត្រូវបានជំរុញឱ្យអនុវត្ត i/- ស្តង់ដារលេខអត្តសញ្ញាណ (BIN) និងស្តង់ដារ Chip EMV សម្រាប់ការចេញផ្សាយប័ណ្ណឥណពន្ធក្នុងស្រុក និង ii/- គោលការណ៍សុវត្ថិភាពលើម៉ាស៊ីន ATM/POS ដើម្បីលើកកម្ពស់សុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ ស្របតាមឧត្តមានុវត្តអន្តរជាតិ និងការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់ បន្ថែមលើការតភ្ជាប់មធ្យោបាយទូទាត់សងប្រាក់ដែលបានអនុវត្តកន្លងមក។ ទន្ទឹមនេះ មុខងារ Contactless លើប្រព័ន្ធ CSS ដែលមានស្រាប់ក៏ត្រូវបាននិងកំពុងអភិវឌ្ឍស្របជាមួយនឹងការចេញផ្សាយនូវសេចក្តីជូនដំណឹងស្តីពី ការអភិវឌ្ឍបន្ថែមមុខងារ Contactless លើប្រព័ន្ធ CSS ដែលមានស្រាប់ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ កន្លងទៅ សំដៅឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យា និងលើកកម្ពស់ភាពងាយស្រួលក្នុងការប្រើប្រាស់ប័ណ្ណទូទាត់ CSS។ បច្ចុប្បន្នក៏មានការរៀបចំអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួម ដែលគ្របដណ្តប់លើហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ដែលបានដាក់ឱ្យដំណើរការកន្លងមក ដើម្បីសម្រួលប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថានឱ្យកាន់តែមានភាពងាយស្រួល និងទទួលបានប្រសិទ្ធភាពខ្ពស់។ គណៈកម្មការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់រួមត្រូវបានបង្កើត និងបានកំពុងរៀបចំឯកសារព្រាងស្តីពី វិធាន និងនីតិវិធីនៃប្រព័ន្ធទូទាត់សងប្រាក់រួមនេះ។



## ខ. វឌ្ឍនភាពប្រព័ន្ធទូទាត់បាគង

ដើម្បីគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមលើកកម្ពស់ការទូទាត់ឌីជីថលជាមួយវិស័យសាធារណៈ តាមរយៈការពង្រីកមុខងារប្រព័ន្ធបាគងសម្រាប់គាំទ្រដល់ការទូទាត់សេវាសាធារណៈជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយបានអភិវឌ្ឍមុខងារសម្រាប់ទូទាត់បង់ពន្ធដារ បើកប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ ច្រកទូទាត់ក្នុងផ្សារពាណិជ្ជកម្មអេឡិចត្រូនិក និងច្រកសម្រាប់ផ្តល់មូលនិធិគាំទ្រដល់ជនក្រីក្រ កុមារកំព្រា និងទ្រទ្រង់គ្រោះមហន្តរាយផ្សេងៗ ជាដើម។ ទន្ទឹមនេះ មុខងារថ្មីមួយទៀតដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែកុម្ភៈ ឆ្នាំ២០២៣ គឺអតិថិជនដែលបានចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគងដោយមានអត្តសញ្ញាណពេញលេញ (Full KYC) អាចស្វែងរកព័ត៌មានអំពីការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួនបានយ៉ាងងាយស្រួលនៅក្នុងកម្មវិធីទូទាត់បាគង ទោះបីជាពុំបានយកប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ មកតាមខ្លួនក៏ដោយ។ ទន្ទឹមនឹងនោះ កម្មវិធីទូទាត់បាគងបានដាក់ឱ្យដំណើរការមុខងារប្តូរប្រាក់រវាងគណនីប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិករបស់អតិថិជនផ្ទាល់ ដែលជាអត្រាប្តូរប្រាក់របស់គ្រឹះស្ថាន និងមានលក្ខណៈប្រសើរជាង បើធៀបនឹងអត្រាប្តូរប្រាក់ពាណិជ្ជករ។

 

## គ. ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

ក្នុងគោលបំណងពង្រឹងកិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមកិច្ចសហការទ្វេភាគីជាមួយបណ្តាធនាគារកណ្តាលក្នុងតំបន់ និងដៃគូពាក់ព័ន្ធ ដើម្បីរៀបចំ និងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឆ្លងដែនប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងតម្លៃសមរម្យ។ កិច្ចសហប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការសម្រាប់ការទូទាត់តាម QR Code ទៅវិញទៅមករវាងប្រទេសទាំងពីរ កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ កន្លងទៅ។ ចំពោះគម្រោងទូទាត់ឆ្លងដែនតាម QR Code ជាមួយប្រទេសឡាវ ត្រូវបានដាក់ឱ្យដំណើរការដំណាក់កាលទី១ (ផ្តល់លទ្ធភាពឱ្យអតិថិជនពីប្រទេសកម្ពុជាអាចស្កេនទូទាត់នៅប្រទេសឡាវ) កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ ហើយសម្រាប់ដំណាក់កាលទី២ (ផ្តល់លទ្ធភាពឱ្យអតិថិជនពីប្រទេសឡាវ មកស្កេនទូទាត់នៅប្រទេសកម្ពុជា) គ្រោងនឹងបញ្ចប់ក្នុងដើមឆ្នាំ២០២៤។ ចំណែកឯ គម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសវៀតណាម

ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣។ លើសពីនេះ គម្រោងទូទាត់ជាមួយក្រុមហ៊ុន Union Pay International (UPI) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣ ដែលផ្តល់លទ្ធភាពឱ្យទេសចរនិងអតិថិជនរបស់ UPI ពីប្រទេសចិននិងប្រទេសជាដៃគូធ្វើការទូទាត់ជាមួយពាណិជ្ជករដែលមានគណនីជាប្រាក់រៀល ហើយអតិថិជនកម្ពុជាអាចធ្វើការទូទាត់តាមប្រព័ន្ធបាគងពីគណនីប្រាក់រៀលជាមួយពាណិជ្ជករនៅប្រទេសចិននិងប្រទេសជាដៃគូរបស់ក្រុមហ៊ុន UPI ដែលគ្រោងនឹងដាក់ឱ្យដំណើរការក្នុងដើមឆ្នាំ២០២៤។ ក្រៅពីកិច្ចសហប្រតិបត្តិការខាងលើ ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ ជាមួយដៃគូពាក់ព័ន្ធបន្ថែមទៀត ដូចជា ប្រទេសឥណ្ឌា (ក្រុមហ៊ុន NPCI) ប្រទេសចិន ក្រុមហ៊ុន Alipay ប្រទេសជប៉ុន ប្រទេសសិង្ហបុរី ប្រទេសហ្វីជី កោះសូឡូម៉ុន និងប្រទេសរ៉ាន់ដា ជាដើម។ ជាមួយគ្នានោះ ធនាគារជាតិនៃកម្ពុជាក៏បានពិនិត្យលទ្ធភាពពង្រីកកិច្ចសហការក្នុងគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសដៃគូ និងស្ថាប័នផ្សេងទៀតដូចជា ប្រទេសក្នុងតំបន់និងសកលលោកផងដែរ។ លើសពីនេះ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ស្តីពី ការអភិវឌ្ឍគម្រោង Financial Transparency Corridor (FTC) ក្នុងគោលបំណងបង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែនសម្រាប់សហគ្រាសធុនតូច និងមធ្យមរវាងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។

### ឃ. សេវាទូទាត់សងប្រាក់

សេវាទូទាត់ឌីជីថលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដូច្នេះហើយ ផលិតផល ឬសេវាបែបច្នៃប្រឌិតថ្មីៗយ៉ាងសម្បូរបែបត្រូវបានដាក់ចេញ ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់អ្នកប្រើប្រាស់។ ការរីកចម្រើនទាំងនេះអាចសម្រេចទៅបានដោយសារការដាក់ចេញនូវបទប្បញ្ញត្តិ ដែលមានភាពអំណោយផលដល់ការប្រកួតប្រជែងរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងយន្តការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់របស់ធនាគារជាតិនៃកម្ពុជាកន្លងមក។ គិតត្រឹមឆ្នាំ២០២៣ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់សរុបមានចំនួន ៣៣ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដែលមានអតិថិជនចុះឈ្មោះបង្កើតគណនីអ៊ីវ៉ាឡេតសរុបប្រមាណ ១៩,៧ លានគណនី។ ប្រតិបត្តិការសេវាទូទាត់សងប្រាក់បានកើនឡើង ២៨,៧% ធៀបនឹងឆ្នាំ២០២២ ដល់ ៦០១,៣ លានប្រតិបត្តិការ និងមានទំហំទឹកប្រាក់កើនឡើង ១៨% ដល់ ៧៥,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹងប្រមាណជិត ២,៤ដងនៃផ.ស.ស។

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលត្រូវបានអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជាចែកជា ២ប្រភេទ គឺ ប្រព័ន្ធទូទាត់តម្លៃធំ និងប្រព័ន្ធទូទាត់រាយ៖

#### ក- ប្រព័ន្ធទូទាត់តម្លៃធំ

- **ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS)៖** សមាជិករបស់ប្រព័ន្ធ OBS មានចំនួន ៨២ ក្នុងនោះ មានធនាគារពាណិជ្ជ ៥៦ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ១ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៧ និងស្ថាប័នរដ្ឋ ១ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS សរុបមានចំនួន ៦៧.៩៩៩ ប្រតិបត្តិការ

ដែលក្នុងនោះការផ្ទេរប្រាក់រៀល មានចំនួន ៨៣.៩២៤ ប្រតិបត្តិការ (១២២ ទ្រីលានរៀល) និងការផ្ទេរប្រាក់ដុល្លារអាមេរិកមានចំនួន ២៤.០៧៥ ប្រតិបត្តិការ (៦៥ ប៊ីលានដុល្លារអាមេរិក)។ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្ដាលមានចំនួន ៦៧.០៩៧ ប្រតិបត្តិការ (កើន ១,៩ដង) និងការផ្ទេរប្រាក់ចេញពីគណនីនៅស្នាក់ការកណ្ដាលទៅគណនីនៅសាខារាជធានី-ខេត្តមានចំនួន ៨០០ ប្រតិបត្តិ-ការ (ថយ -២៦,៤%) និងពីគណនីនៅសាខារាជធានី-ខេត្ត មកគណនីនៅស្នាក់ការកណ្ដាលមានចំនួន ១៥២ ប្រតិបត្តិការ (កើន ១០០%) បើធៀបនឹងឆ្នាំ២០២២។

**ក្រាហ្វ ៧៧៖ ការផ្ទេរប្រាក់រៀលតាមរយៈ OBS**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




**ក្រាហ្វ ៧៨៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមរយៈ OBS**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**-ប្រព័ន្ធទូទាត់តម្លៃធំបាគង (Bakong LV)៖** ប្រព័ន្ធនេះកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍ ដើម្បីសម្រួលការទូទាត់ ចំពោះប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ ប្រតិបត្តិការទូទាត់សមតុល្យសុទ្ធរបស់ប្រព័ន្ធទូទាត់រាយ និងប្រតិបត្តិការទូទាត់ក្នុងទីផ្សារហិរញ្ញវត្ថុ។

**ខ- ប្រព័ន្ធទូទាត់រាយ** រួមមាន៖ i/-ប្រព័ន្ធផាត់ទាត់ជាតិ (NCS) ii/-ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0) iii/-ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS) iv/-ប្រព័ន្ធរីថែលផេ (Retail Pay) និង v/-ប្រព័ន្ធបាគង។

**១. ប្រព័ន្ធផាត់ទាត់ជាតិ (NCS)** ជាប្រព័ន្ធបម្រើដល់ប្រតិបត្តិការទូទាត់មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន។ នៅស្នាក់ការកណ្ដាលធនាគារជាតិនៃកម្ពុជា ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកផ្ទាល់ ៤៣ និងសមាជិកមិនផ្ទាល់ ១៨ ព្រមទាំងមានសមាជិកចូលរួមតាមមណ្ឌលដោះដូរមូលប្បទានប័ត្រជារូបវន្តនៅតាមខេត្តទាំង ៧ គឺ ខេត្តសៀមរាប មានសមាជិក (៣១) កំពង់ចាម (២១) ព្រះសីហនុ (២៣) បាត់ដំបង (២២) បន្ទាយមានជ័យ (១១) ស្វាយរៀង (៩) និងកំពង់ធំ (៩)។

**-សេវាទូទាត់មូលប្បទានប័ត្រ៖** ការទូទាត់មូលប្បទានប័ត្រចារឹកជារៀលមានចំនួន ៣៩.១០៩ សន្លឹក (កើន ១,៥%) និងទំហំទឹកប្រាក់ទូទាត់មាន ២២.០០២,៧ ប៊ីលានរៀល (កើន ១០,៩%)។ ចំណែកឯ ការទូទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមាន ១.០៤១.៧១០ សន្លឹក (ថយ -៥,៨%) និងទំហំទឹកប្រាក់ទូទាត់ ៨៤.៨៣៣,២ លានដុល្លារអាមេរិក (ថយ -១៧,៥%)។

**ក្រាហ្វ ៧៩៖ ចំនួនមូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




**ក្រាហ្វ ៨០៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់រៀល និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨១៖ ចំនួនមូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




**ក្រាហ្វ ៨២៖ ទំហំទឹកប្រាក់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**- សេវាទូទាត់បញ្ជាផ្ទេរឥណទាន៖** បញ្ជាផ្ទេរឥណទានដែលជាឧបករណ៍ទូទាត់សងប្រាក់អេឡិចត្រូនិកមានការកើនឡើង ក្នុងនោះជាប្រាក់រៀលមាន ២៨.៣៣៤ ប្រតិបត្តិការ (កើន ២៥,៧%) និងទំហំទឹកប្រាក់ផ្ទេរមានចំនួន ៤.៨៧៦,៩ ប៊ីលានរៀល (កើន ៦,៩%) ស្របពេលដែលប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៦៣២.០០៩ ប្រតិបត្តិការ (ថយ -៦,៤%) ប៉ុន្តែទំហំទឹកប្រាក់ផ្ទេរ ១៣.១១៨ លានដុល្លារអាមេរិក (កើន ៦,៥%)។

**ក្រាហ្វ ៨៣៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




**ក្រាហ្វ ៨៤ ៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់រៀល និង បម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៥៖ ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




**ក្រាហ្វ ៨៦៖ ទំហំទឹកប្រាក់បញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក និងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៧ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**២. ប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី (FAST 2.0)៖** ប្រព័ន្ធសេវាទូទាត់រហ័សបានដំណើរការទូទាត់លើប្រតិបត្តិការផ្ទេរមូលនិធិជាប្រាក់រៀលតម្លៃតូចដែលមានទំហំទឹកប្រាក់អតិបរមា ៤០ លានរៀលក្នុងមួយប្រតិបត្តិការ។ ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុប ៥៧ ក្នុងនោះមាន ៣៥ ដែលកំពុងដំណើរការជាផ្លូវការ។ ប្រព័ន្ធសេវាទូទាត់រហ័សបានទូទាត់ប្រតិបត្តិការផ្ទេរមូលនិធិ ២០.០៩១ ប្រតិបត្តិការ (ថយ -១១,៦%) និងទំហំទឹកប្រាក់ទូទាត់ ៨៣,២ ប៊ីលានរៀល (កើន ១៦%)។

**ក្រាហ្វ ៨៧៖ ចំនួនប្រតិបត្តិការសេវាទូទាត់រហ័សជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣)




**ក្រាហ្វ ៨៨៖ ទំហំទឹកប្រាក់សេវាទូទាត់រហ័សជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៨ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច (CSS)៖** ប្រព័ន្ធនេះមានសមាជិកចំនួន ៦០ ក្នុងនោះសមាជិកផ្ទាល់ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៤ និងសមាជិកមិនផ្ទាល់ជា ធនាគារពាណិជ្ជចំនួន ៤ ហើយបច្ចុប្បន្ន សមាជិកកំពុងដំណើរការចំនួន ៤២។ ប្រព័ន្ធ CSS បានបម្រើលើប្រតិបត្តិការសរុបជាប្រាក់រៀលចំនួន ២៨០.៨១៨ ប្រតិបត្តិការ (ថយ -៣៣,៥%) និងទំហំទឹកប្រាក់សរុប ៦២,៨ ប៊ីលានរៀល (ថយ -២៧,១%)។ ទន្ទឹមនេះ ប្រតិបត្តិការទូទាត់ជាប្រាក់ដុល្លារអាមេរិកមាន ៥៥.២៧០ ប្រតិបត្តិការ (ថយ -៣៤,៨%) និងទំហំទឹកប្រាក់ទូទាត់ ៧,៦ លានដុល្លារអាមេរិក (ថយ -៣៦,១%)។

**ក្រាហ្វ ៨៩៖ ចំនួនប្រតិបត្តិការប្រព័ន្ធខេមមូខានស៊ែស្វីច ជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




**ក្រាហ្វ ៩០៖ ទំហំទឹកប្រាក់ប្រព័ន្ធខេមមូខានស៊ែស្វីចជារៀលនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩១៖ ចំនួនប្រតិបត្តិការប្រព័ន្ធខេមមូខានស៊ែស្វីច ជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




**ក្រាហ្វ ៩២៖ ទំហំទឹកប្រាក់ប្រព័ន្ធខេមមូខានស៊ែស្វីច**
(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៤. ប្រព័ន្ធរីថែលផេ (Retail Pay)៖** ប្រព័ន្ធរីថែលផេ មានសមាជិកសរុបចំនួន ២៦ ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងនោះមានសមាជិក ១៦ កំពុងដំណើរការជាផ្លូវការ។ ប្រតិបត្តិការទូទាត់តាមប្រព័ន្ធរីថែលផេ បានដំណើរការទូទាត់ចំនួន ២៥០ថ្ងៃ ជាប្រាក់រៀលមាន ១៦.៥៦៦ ប្រតិបត្តិការ (ថយ -៣៧,៧%) ទំហំទឹកប្រាក់ទូទាត់ ៤៣៩ ប៊ីលានរៀល (ថយ -៥,៤%)។ ទន្ទឹមនេះ ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមាន ៤៥.៩៨៦ ប្រតិបត្តិការ (ថយ -១%) ទំហំទឹកប្រាក់ទូទាត់ ២១២ លានដុល្លារអាមេរិក (ថយ -១១,១%)។

**ក្រាហ្វ ៩៣៖ ចំនួនប្រតិបត្តិការប្រព័ន្ធរីធែលផេជារៀលនិងបម្រែបម្រួលជាភាគរយ**

(ឆ្នាំ២០២០ - ឆ្នាំ២០២៣)




**ក្រាហ្វ ៩៤៖ ទំហំទឹកប្រាក់ប្រព័ន្ធរីធែលផេជារៀលនិងបម្រែបម្រួលជាភាគរយ**

(ឆ្នាំ២០២០ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩៥៖ ចំនួនប្រតិបត្តិការប្រព័ន្ធរីធែលផេជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**

(ឆ្នាំ២០២០ - ឆ្នាំ២០២៣)




**ក្រាហ្វ ៩៦៖ ទំហំទឹកប្រាក់ប្រព័ន្ធរីធែលផេជាដុល្លារអាមេរិកនិងបម្រែបម្រួលជាភាគរយ**

(ឆ្នាំ២០២០ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**៥. ប្រព័ន្ធបាគង (Bakong)៖** ប្រព័ន្ធបាគងជាប្រព័ន្ធទូទាត់កន្លោង ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដែលមានសមាជិកសរុបចំនួន ៧៤ គ្រឹះស្ថាន ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ៥៨ បានដាក់ឱ្យដំណើរការជាផ្លូវការ (កើន ១២ គ្រឹះស្ថាន) និងគ្រឹះស្ថានចំនួន ១៦ ទៀតបាននិងកំពុងបន្តធ្វើសន្ធានកម្មប្រព័ន្ធ។ ទន្ទឹមនឹងនេះ អតិថិជនចុះឈ្មោះប្រើប្រាស់តាមរយៈកម្មវិធីបាគងមានចំនួនសរុប ០,៦ លានគណនី (កើនប្រមាណ ៧៨ ពាន់) ធៀបនឹងឆ្នាំ២០២២។ ប្រព័ន្ធនេះបានជួយសម្រួលដល់ការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថាន

**ក្រាហ្វ ៩៧៖ ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់តាមរយៈកម្មវិធីបាគង និងបម្រែបម្រួលជាភាគរយ**

(ឆ្នាំ២០២០ - ឆ្នាំ២០២៣)




ប្រភព៖ របាយការណ៍ BI, ទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុដល់អតិថិជន ចំនួន ១៩,៥ លានគណនី។ បន្ថែមពីនេះ ប្រព័ន្ធបាគង បានផ្ដល់ជាអត្ថប្រយោជន៍បន្ថែមដល់សាធារណៈជន អាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់តាមខេអេចឃ្យូអរកូត និងទូទាត់ឆ្លងដែន ដោយចំណាយប្រតិបត្តិការទាប ប្រសិទ្ធភាព និងមានសុវត្ថិភាព។

**ក្រាហ្វ ៩៨៖ ចំនួនប្រតិបត្តិការប្រព័ន្ធបាគងជាប្រាក់រៀល និងដុល្លារអាមេរិក**
(គិតជាលានប្រតិបត្តិការ, ឆ្នាំ២០២០ - ឆ្នាំ២០២៣)




ប្រភព៖ របាយការណ៍ BI, ទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

គិតត្រឹមដំណាច់ឆ្នាំ២០២៣ ប្រតិបត្តិការតាមរយៈប្រព័ន្ធបាគងមានចំនួន ២០០,៩៣ លានប្រតិបត្តិការ (កើនជាង ៥ ដង ធៀបនឹងឆ្នាំ២០២២) ក្នុងនោះ ៦៨,៧៩ លានប្រតិបត្តិការជាប្រាក់រៀល និង ១៣២,១៤ លានប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក។ ចំណែកឯ ទំហំប្រាក់ទូទាត់ជាប្រាក់រៀលប្រមាណ ៨១,០៥ ទ្រីលានរៀល (កើន ៣,៤ ដង) និងជាប្រាក់ដុល្លារអាមេរិកប្រមាណ ៥៣,៧៦ ប៊ីលានដុល្លារអាមេរិក (កើនជិត ២,៤ ដង) ធៀបនឹងឆ្នាំ ២០២២។

**ក្រាហ្វ ៩៩៖ ទំហំទឹកប្រាក់ប្រព័ន្ធបាគងជាប្រាក់រៀល**
(គិតជាទ្រីលានរៀល, ឆ្នាំ២០២០ - ឆ្នាំ២០២៣)




**ក្រាហ្វ ១០០៖ ទំហំទឹកប្រាក់ប្រព័ន្ធបាគងជាប្រាក់ដុល្លារអាមេរិក**
(គិតជាប៊ីលានដុល្លារអាមេរិក, ឆ្នាំ២០២០ - ឆ្នាំ២០២៣)




ប្រភព៖ របាយការណ៍ BI, ទិន្នន័យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

ប្រព័ន្ធបាគង បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ជាប្រព័ន្ធទូទាត់ជាតិ (National Payment Hub) សម្រាប់តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីផ្តល់ជាមធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់ និងទូទាត់ទំនិញ ដែលមានកម្រៃទាបសម្រាប់ពលករចំណាកស្រុក ភ្ញៀវទេសចរនិងអ្នកធុរកិច្ច។ ប្រព័ន្ធបាគង ក៏កំពុងបន្តនវានុវត្តន៍ លើមុខងារថ្មីៗបន្ថែមទៀត តួយ៉ាងដូចជា៖ Open API, Link Account, e-KYC with CamDX, Cross Border ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាហិរញ្ញវត្ថុ។




## ២- សេវាគ្រប់គ្រងគណនី

### ក. ចំនួនគណនី

ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងគណនីសរុបចំនួន ២.៨២៤ (នៅស្នាក់ការកណ្តាល ២.១២១[២៩] និងតាមបណ្តាសាខារាជធានី-ខេត្ត ចំនួន ៧០៣[៣០]) បានថយចុះ ១០គណនី ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន ដោយសារគណនីបើកសរុបមានចំនួន១៤០គណនី រីឯគណនីបិទសរុបមានចំនួន ១៥០[៣១]គណនី។




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[២៩] គណនីរបស់ស្ថាប័នរដ្ឋ ៩២៨ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ១.១៥៣ និងអង្គភាពផ្សេងៗ ៤០។

[៣០] គណនីរបស់ស្ថាប័នរដ្ឋ ១១២ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥៧៥ និងអង្គភាពផ្សេងៗ ១៦។

[៣១] គណនីបិទសរុប ១៥០ ក្នុងនោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបិទគណនីសរុបចំនួន ១១៥គណនី ដែលរួមមាន៦៥គណនី ជាគណនីរបស់គម្រោងផ្សេងៗ ត្រូវបានសុំបិទ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងគណនីក្នុងគោលបំណងពង្រឹងនីតិវិធីក្នុងការគ្រប់គ្រងចំណូល និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុក្នុងការទទួលថវិកាផ្ទាល់ពីអគ្គនាយកដ្ឋានរតនាគារជាតិ ។

## ២. សេវាទទួលប្រាក់បញ្ញើ

ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថាប័នរដ្ឋ និងអង្គភាពផ្សេងៗនៅធនាគារជាតិនៃកម្ពុជាមានការប្រែប្រួលធៀបនឹងឆ្នាំ២០២២ ក្នុងនោះប្រាក់បញ្ញើជាប្រាក់រៀលបានថយចុះចំនួន ១,០២ ទ្រីលានរៀល (ថយ -៩,១%) ចំណែកឯប្រាក់ដុល្លារអាមេរិកមានការកើនឡើងចំនួន ១.០៥២,៤ លានដុល្លារអាមេរិក (កើន ៩,៥%)។

**ក្រាហ្វ ១០២៖ ប្រាក់បញ្ញើជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា**
(លានដុល្លារអាមេរិក, ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




**ក្រាហ្វ ១០៣៖ ប្រាក់បញ្ញើជារៀលនៅធនាគារជាតិនៃកម្ពុជា**
(ប៊ីលានរៀល, ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៣- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

### ក- ប្រតិបត្តិការសាច់ប្រាក់របស់បេឡា

ការទទួល និងការបើកប្រាក់រៀលមានចំនួន ១៦,៨ ទ្រីលានរៀល (កើន ១៤,១%) និង ១៧,៩ ទ្រីលានរៀល (កើន ២៥,១%) រៀងគ្នា។ ចំណែកឯការទទួល និងការបើកប្រាក់ដុល្លារអាមេរិកមានចំនួន ១៤,៤ ប៊ីលានដុល្លារអាមេរិក (ថយ -៨,៧%) និង ៦,១ ប៊ីលានដុល្លារអាមេរិក (ថយ -០,៩%) រៀងគ្នា។

**ក្រាហ្វ ១០៤៖ ការទទួលនិងការបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៩-ឆ្នាំ២០២៣)




**ក្រាហ្វ ១០៥៖ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៩-ឆ្នាំ២០២៣)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

## ខ- ការងារគ្រប់គ្រងសាច់ប្រាក់

ការផ្គត់ផ្គង់ក្រដាសប្រាក់ថ្មីគ្រប់ប្រភេទនិងការប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែក ត្រូវបាន អនុវត្តជាប្រចាំ ដើម្បីបំពេញតម្រូវការសាធារណជន ស្របពេលដែលការពង្រឹងសោភ័ណភាពនិង គុណភាពក្រដាសប្រាក់ត្រូវបានបន្តយកចិត្តទុកដាក់ដើម្បីទប់ស្កាត់ការក្លែងបន្លំក្រដាសប្រាក់ និង លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងការដឹកជញ្ជូន ប្រាក់រៀលចាស់និងលើសពីតម្រូវការមកស្នាក់ការកណ្តាលវិញបានកើនឡើង ២៨,៧% និង ២៣,៥% រៀងគ្នា។ ចំណែកឯការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្តាលវិញបានកើនឡើង ៣,៥% និង ៧៣,១% រៀងគ្នា ធៀបនឹងឆ្នាំ២០២២។

**ក្រាហ្វ ១០៦៖ ប្រាក់រៀលដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល, ឆ្នាំ២០១៩-២០២៣)




**ក្រាហ្វ ១០៧៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មកសាខាធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៩-២០២៣)




ប្រភព៖ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២វគ្គ ស្តីពី "ការពិនិត្យវិនិច្ឆ័យលើ ក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ" ដោយបានសហការរៀបចំជាមួយក្រុមហ៊ុនដឹកជញ្ជូន សាច់ប្រាក់ Travelex និងជាមួយធនាគារ Moneycorp ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រី ធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការពិនិត្យក្រដាសប្រាក់ដុល្លារអាមេរិក ក្លែងក្លាយ និងចៀសវាងបាននូវការខាតបង់ជាយថាហេតុ។

## ៤- សន្និដ្ឋាន

ធនាគារជាតិនៃកម្ពុជា បានពង្រឹងប្រសិទ្ធភាពសេវាធនាគារកណ្តាល ដែលគាំទ្រដល់អន្តរ-ការីយកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងសាច់ប្រាក់របស់រាជរដ្ឋាភិបាល ព្រមទាំង បានសម្រួលដល់ការទូទាត់ទំនិញនិងសេវាកម្មនៅក្នុងសេដ្ឋកិច្ច។ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានបន្ត ធ្វើទំនើបកម្ម និងពង្រីកការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ជាបន្តបន្ទាប់ ដែលបានសម្រួលដល់ការ ទូទាត់ទាំងក្នុងនិងក្រៅប្រទេស ដល់ប្រជាជនកម្ពុជានិងទេសចរអន្តរជាតិ។ ទន្ទឹមនេះ ការគ្រប់គ្រង ចរាចរសាច់ប្រាក់ក៏ត្រូវបានធ្វើឡើងដោយពិលាស ដើម្បីបំពេញតម្រូវការឱ្យបានទាន់ពេលវេលា និង គាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចនៅតាមតំបន់នៅទូទាំងប្រទេស។

## VI- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

សម្រាប់ឆ្នាំ២០២៣ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តដើរតួនាទីយ៉ាងសំខាន់ប្រកបដោយភាពម្ចាស់ការ និងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាពិសេសការរៀបចំទទួលការចុះមកត្រួតពិនិត្យដល់ទីកន្លែងនៅកម្ពុជា របស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (ICRG-JG) និងការការពាររបាយការណ៍រហូតសម្រេចបានលទ្ធផលគួរជាទីមោទនៈនៃការដកចេញកម្ពុជាពី ″**បញ្ជីប្រផេះ**″ របស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force - FATF) កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣។ សមិទ្ធផលដ៏ធំធេងនេះទទួលបានការកោតសរសើរពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ ស.ហ.ក. ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងវិស័យឯកជនដោយមានការគាំទ្រដ៏ពេញទំហឹងពីថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាល។







ទន្ទឹមនេះ ស.ហ.ក. បាននិងកំពុងបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការវិភាគរបាយកាណ៍ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ បណ្តុះបណ្តាល និងការដឹកនាំអនុគណៈកម្មការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ផងដែរ។

## ១- ការពង្រឹងក្របខ័ណ្ឌនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ស.ហ.ក. បាននិងកំពុងបន្តពង្រឹងការត្រួតពិនិត្យលើបុគ្គលរាយការណ៍អំពីការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការប្រើប្រាស់វិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ (Risk Based Supervision)។ ស.ហ.ក. បានត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជ ចំនួន៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចំនួន៤ និងកាស៊ីណូ ចំនួន១៩ ដោយបានផ្តល់អនុសាសន៍កែតម្រូវ ចំពោះចំណុចខ្វះខាតផងដែរ។

ទន្ទឹមនេះ ស.ហ.ក. បានអនុវត្តការងារត្រួតពិនិត្យលើឯកសារជាប្រចាំចំពោះបុគ្គលរាយការណ៍ ដោយពិនិត្យ និងតាមដានលទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង វឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែងរបស់ ស.ហ.ក. និងការវាយតម្លៃគុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិ។ បច្ចុប្បន្ននេះ ស.ហ.ក. បានទទួលស្គាល់មន្ត្រីប្រតិបត្តិរបស់បុគ្គលរាយការណ៍សរុបចំនួន ៣១៣រូប មកពីធនាគារពាណិជ្ជ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនទ្រព្យ កាស៊ីណូ និងក្រុមហ៊ុនបរធនបាលកិច្ច។





## ២- ការងារវិភាគនិងបញ្ជូនរបាយការណ៍

ស.ហ.ក. បានបន្តតាមដានជាប្រចាំនូវការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ស្របតាមមាត្រា ១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ថយចុះ ២២,៩% ហើយការរាយការណ៍ប្រតិបត្តិការសង្ស័យបានកើនឡើង ២០,២% ធៀបនឹងឆ្នាំមុន។ ទន្ទឹមនេះ ស.ហ.ក. បានភ្ជាប់ប្រព័ន្ធរាយការណ៍ជូនគ្រឹះស្ថានចំនួន ១០២ និងបានណែនាំគ្រឹះស្ថានទាំងនោះ ពង្រឹងការយកចិត្តទុកដាក់អនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ពិសេសការរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់។

## ៣- កិច្ចសហប្រតិបត្តិការ

### ក- កិច្ចសហប្រតិបត្តិការក្នុងស្រុក

ស.ហ.ក. បានដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ចំនួន ៣លើក ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម តាមម៉ូឌុលនីមួយៗ និងមានសមាសភាពមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ២២។ ជាលទ្ធផល ក្រសួង-ស្ថាប័ន បានបញ្ចប់ការបណ្តុះបណ្តាលជំហានទី១ និងចាប់ផ្តើមប្រមូលទិន្នន័យបឋម ដើម្បីត្រៀមវិភាគកម្រិតហានិភ័យ ភាពងាយរងគ្រោះ និងការគំរាមកំហែងតាមវិស័យពាក់ព័ន្ធ និងបន្តពិភាក្សាជាមួយជំនាញការធនាគារពិភពលោកក្នុងដំណាក់កាលបន្ទាប់។

ទន្ទឹមនេះ ស.ហ.ក. បានដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ក.ប.ស.ហ.) ចំនួន ៣លើក៖ ១/-ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃមហាសន្និបាតរបស់ FATF ២/-ដើម្បីពិភាក្សារបាយការណ៍វឌ្ឍនភាពលើកទី៦ របស់ប្រទេសកម្ពុជា និង ៣/-ដើម្បីការពាររបាយការណ៍វឌ្ឍនភាពលើកទី៦ ក្នុងកិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation Committee - MEC)។





### ខ- កិច្ចសហប្រតិបត្តិការអន្តរជាតិ

**ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (Asia/Pacific Group on Money Laundering - APG)៖** ស.ហ.ក. បានបន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការស្នើសុំដំឡើងចំណាត់ថ្នាក់អនុសាសន៍ តាមរយៈរបាយការណ៍វឌ្ឍនភាពលើកទី៦ (Follow-Up Report - FUR)។ គណៈកម្មការវាយតម្លៃអញ្ញមញ្ញបានអនុម័តដំឡើងអនុសាសន៍ចំនួន ១ គឺអនុសាសន៍ទី៧ (R.7) នៅឆ្នាំ២០២៣នេះ។ ជារួម តាមរយៈរបាយការណ៍វឌ្ឍនភាពទាំង៦លើក កម្ពុជាសម្រេចបានអនុសាសន៍ចំនួន ៣៣ នូវចំណាត់ថ្នាក់អនុលោមតាមភាគច្រើន (Largely Compliant) និងអនុលោមតាម (Compliant) ក្នុងចំណោមអនុសាសន៍សរុប ៤០ របស់ FATF។ ដូច្នេះកម្ពុជា ត្រូវបានដកចេញពីបញ្ជីនៃប្រទេសដែលស្ថិតនៅក្នុងដំណាក់កាលពង្រឹងការរាយការណ៍ (Enhanced Follow-Up) មកស្ថិតនៅក្នុងដំណាក់កាលរាយការណ៍ធម្មតា (Regular Follow-Up) ដែលមិនតម្រូវឱ្យរៀបចំរបាយការណ៍វឌ្ឍនភាព

ស្នើសុំដំឡើងចំណាត់ថ្នាក់ជាប្រចាំឆ្នាំទៀតទេ ពោលគឺកម្ពុជាគ្រាន់តែត្រូវរាយការណ៍អំពីវឌ្ឍនភាពរៀងរាល់ពីរឆ្នាំម្តង។

ស.ហ.ក. ក៏បានចូលរួមកិច្ចប្រជុំមហាសន្និបាត APG ប្រចាំឆ្នាំនៅខែកក្កដា ឆ្នាំ២០២៣ នៅទីក្រុង VANCOUVER ប្រទេសកាណាដា និងបានពង្រឹងកិច្ចសហការជាមួយប្រទេសឡាវ ប្រទេសព្រុយណេ និងប្រទេសថៃ តាមរយៈផ្តល់ការគាំទ្រក្នុងការសុំដំឡើងចំណាត់ថ្នាក់។ ក្នុងឱកាសចូលរួមមហាសន្និបាតនេះ ស.ហ.ក. ក៏បានជួបប្រជុំជាមួយក្រុមអ្នកផ្តល់ជំនួយបច្ចេកទេស (Donor and Providers Group - DAP) ដើម្បីស្នើសុំជំនួយបច្ចេកទេសមួយចំនួន និងជាពិសេសជំនួយបច្ចេកទេស លើការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ ពីធនាគារពិភពលោក។

ស.ហ.ក. បានចូលរួមកិច្ចប្រជុំនានាជាមួយ APG និង FATF រួមមាន ១/- កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ ២/-កិច្ចប្រជុំគណៈកម្មការអភិបាល (Governance Committee) ៣/-កិច្ចប្រជុំគណៈកម្មការប្រតិបត្តិការ (Operational Committee Meeting) ៤/-កិច្ចប្រជុំក្រុមការងារទំនាក់ទំនងផ្នែកទ្រព្យសកម្មនិម្មិត និងអ្នកផ្តល់សេវាទ្រព្យសកម្មនិម្មិត (APG VA/VASP Network Meeting) និង ៥/-ចូលរួមសិក្ខាសាលាស្តីពីគំរូសិក្សារបស់ APG និងសិក្ខាសាលាស្តីពីការវិភាគទិន្នន័យ។

**ក្រុមអ៊ិកម៉ុង (The EGMONT Group)៖** ក្នុងនាមជាសមាជិករបស់ក្រុមអ៊ិកម៉ុង ស.ហ.ក. បានចូលរួមប្រជុំពិភាក្សាពីវឌ្ឍនភាពគម្រោងសិក្សា រួមមាន ១/-ក្រុមការងារផ្លាស់ប្តូរព័ត៌មាន ២/-ក្រុមការងារជំនួយបច្ចេកទេសនិងបណ្តុះបណ្តាល ៣/-ក្រុមការងារសមាជិកភាពការគាំទ្រ និងអនុលោមភាព និង ៤/-ក្រុមការងារគោលនយោបាយនិងនីតិវិធី ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣០ ខែមករា ដល់ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៣ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់។

ទន្ទឹមនេះ ស.ហ.ក. បានចូលរួមមហាសន្និបាតប្រចាំឆ្នាំលើកទី២៩ របស់ក្រុមអ៊ិកម៉ុង ក្រោមប្រធានបទស្តីពី "ការប្រើប្រាស់បច្ចេកវិទ្យាទំនើបដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដើម្បីពង្រឹងប្រតិបត្តិការ" ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី៣-៧ ខែកក្កដា ឆ្នាំ២០២៣ នៅទីក្រុងអាប៊ុយដាប៊ី ប្រទេសអេមីរ៉ាតអារ៉ាប់រួម។ មហាសន្និបាតបានចែករំលែកបទពិសោធន៍អំពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជា៖ ១/-បច្ចេកវិទ្យាការពារការសម្ងាត់នៃព័ត៌មានឯកជន (Privacy Enhancing Technologies - PETs) ២/-បច្ចេកវិទ្យា Artificial Intelligence (AI) និង ៣/-បច្ចេកវិទ្យា Blockchain ដែលបទពិសោធន៍ទាំងនេះបានជួយពង្រឹងការងារវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ និងប្រសិទ្ធភាព និងសុវត្ថិភាពនៃការផ្លាស់ប្តូរព័ត៌មានរវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។

ក្រៅពីនេះ ស.ហ.ក. ក៏បានចូលរួមកិច្ចប្រជុំក្រុមការងារតំបន់អាស៊ីប៉ាស៊ីហ្វិករបស់ក្រុមអ៊ិកម៉ុង តាមប្រព័ន្ធអនឡាញ ព្រមទាំងបានសិក្សា និងចូលរួមផ្តល់ធាតុចូលក្នុងកម្រងសំណួរ ដើម្បីរៀបចំសេចក្តីព្រាងផែនការអាជីវកម្ម ឆ្នាំ២០២៣-២០២៤ សម្រាប់ក្រុមការងារផ្លាស់ប្តូរព័ត៌មាន របស់ក្រុមអ៊ិកម៉ុង។

តាមរយៈក្រុមអ៊ិកម៉ុង ស.ហ.ក. ក៏បានចូលរួមផ្តល់ធាតុចូលក្នុងការវាយតម្លៃប្រសិទ្ធភាព ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការស្ទង់មតិអំពីគុណភាពនៃរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុឥណ្ឌូណេស៊ី ផងដែរ។

**ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group – FICG)៖** ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ កាលពីថ្ងៃទី១៤-១៦ ខែកុម្ភៈ ឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។ កិច្ចប្រជុំនេះ បានចែករំលែកអំពីវឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់ប្រទេសជាសមាជិកអាស៊ានបូកអូស្រ្តាលី និងនូវែលសេឡង់ ព្រមទាំងបានអនុម័តលើបច្ចុប្បន្នភាពការងាររបស់គម្រោងសិក្សានានា ដែលរៀបចំដោយ FICG និងតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុរបស់ប្រទេសជាសមាជិកផងដែរ។







## ៤- ការបណ្តុះបណ្តាលនិងនីតិកម្ម

### ក. ការបង្កើនសមត្ថភាព និងការផ្សព្វផ្សាយ

ស.ហ.ក. បានបន្តពង្រឹងសមត្ថភាពមន្រ្តី-បុគ្គលិកជាបន្តបន្ទាប់ លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានការរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងអំពីច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអនុសាសន៍របស់ FATF ចំនួន ២លើក ការទទួលការបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេសចំនួន ១៧លើក និងបរទេស ចំនួន ១១លើក ព្រមទាំងការបណ្តុះបណ្តាលនានាតាមរយៈប្រព័ន្ធអនឡាញ ដែលមានដូចជា ១/-កម្មវិធី ECOFEL ២/-កម្មវិធី FATF e-Learning ៣/-កម្មវិធី UNODC e-Learning ៤/-កម្មវិធី i-Spring របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុរុស្ស៊ី និង ៥/-កម្មវិធី Cyber Safety Asia របស់ប៉ូលីសសហព័ន្ធអូស្រ្តាលី។ តាមរយៈ ស.ហ.ក. នគរបាលសហព័ន្ធអូស្រ្តាលី បានអនុញ្ញាតឱ្យមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជាបានរៀនពីកម្មវិធី Cyber Safety Asia ផងដែរ។

 

ស.ហ.ក. បានរៀបចំសិក្ខាសាលាសម្រាប់បុគ្គលរាយការណ៍ក្នុងវិស័យធនាគារចំនួន ៣លើក និងគ្រឹះស្ថានសិក្សាចំនួន ១លើក ព្រមទាំងបានចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងក្នុងកម្មវិធីបណ្តុះបណ្តាល និងបង្កើនការយល់ដឹងលើប្រធានបទពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជូនមន្ត្រីនៃក្រសួង-ស្ថាប័នត្រួតពិនិត្យ និងអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ និងសាធារណជនចំនួន ១៩លើក។

**ខ. ការងារនីតិកម្ម**

ស.ហ.ក. បាននិងកំពុងសិក្សារៀបចំសេចក្តីព្រាងសេចក្តីណែនាំបន្ថែម ដើម្បីឱ្យបុគ្គលរាយការណ៍អនុវត្ត ស្របតាមការតម្រូវនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលជាចលករធ្វើឱ្យប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម កាន់តែរឹងមាំ និងមានប្រសិទ្ធភាព។

## ៥- សន្និដ្ឋាន

ជារួម ស.ហ.ក. បានអនុវត្តការងារស្នូលបានខ្ជាប់ខ្ជួន និងប្រកបដោយការទទួលខុសត្រូវក្នុងការពង្រឹង ១/-ការត្រួតពិនិត្យបុគ្គលរាយការណ៍ ២/-ការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យ ៣/-កិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ និង៤/-ការងារនីតិកម្មនិងការបណ្តុះបណ្តាល។ ស.ហ.ក. ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ បាននិងកំពុងវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ តាមសមត្ថកិច្ចរៀងៗខ្លួន។ ដោយឡែក សមិទ្ធផលដ៏ធំធេងមួយនាឆ្នាំនេះ គឺកិច្ចខិតខំប្រឹងប្រែងរបស់ ស.ហ.ក. និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) កាលពីខែកុម្ភៈ ឆ្នាំ២០២៣។

## VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ១- កិច្ចសហប្រតិបត្តិការពហុភាគី

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្ដាអង្គការ-ស្ថាប័នអន្តរជាតិនានា ដើម្បីលើកកម្ពស់ទំនាក់ទំនងល្អ ផ្លាស់ប្ដូរបទពិសោធន៍ និងពង្រឹងសមត្ថភាព។

- **កិច្ចសហប្រតិបត្តិការអាស៊ាន៖** ក្រោយពីបានដើរតួនាទីជាប្រធានអាស៊ានក្នុងវិស័យធនាគារដោយជោគជ័យកាលពីឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានចូលរួមពង្រឹងសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន តាមរយៈការចូលរួមពិភាក្សាក្នុងកិច្ចប្រជុំសំខាន់ៗរបស់អាស៊ាន រួមមាន៖ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្ដាលអាស៊ាន (AFMGM) លើកទី៩ និងលើកទី១០ នៅកោះបាលី និងទីក្រុងចាកាតានៃប្រទេសឥណ្ឌូណេស៊ី កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្ដាលអាស៊ាន(ACGM) លើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធនានា។ សមិទ្ធផលសំខាន់ៗក្រោមកិច្ចសហប្រតិបត្តិការអាស៊ាន មានដូចជា ៖ i/-ការកំណត់មូលបទនិងការងារអាទិភាពក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុសម្រាប់អាស៊ាន ii/-ការលើកកម្ពស់សមាហរណកម្មហិរញ្ញវត្ថុ iii/-ជំរុញសេរីភាវូបនីយកម្មគណនីមូលធន iv/-ពង្រីកការតភ្ជាប់ប្រព័ន្ធទូទាត់ដោយប្រើប្រាស់រូបិយវត្ថុក្នុងតំបន់ v/-លើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព vi/-ជំរុញបរិយាបន្នហិរញ្ញវត្ថុ vii/-ពង្រីកទំនាក់ទំនងជាមួយធុរកិច្ចអាស៊ាន អឺរ៉ុប និងសហរដ្ឋ-អាមេរិក viii/-រៀបចំកិច្ចព្រមព្រៀងអាស៊ានស្វប់ឡើងវិញ ix/-ពង្រឹងការកសាងសមត្ថភាពមន្ត្រីជំនាញ និង x/-ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ប្រធានសវនកម្មផ្ទៃក្នុងនៃធនាគារកណ្ដាលអាស៊ានលើកទី៨។






**ប្រអប់ ២ ៖ កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន**

វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអាស៊ាន រួមមាន៖ i/-ការកំណត់យកមូលបទ "អាស៊ានសំខាន់ជាស្នូលនៃកំណើន" និងបានគាំទ្រយុទ្ធសាស្ត្រចំនួន ៣ សម្រាប់សសរស្តម្ភសេដ្ឋកិច្ចអាស៊ាន ដើម្បីជំរុញការងើបឡើងនិងការកសាងឡើងវិញ (Recovery-Rebuilding) សេដ្ឋកិច្ចឌីជីថល (Digital Economy) និង ចីរភាព (Sustainability) ii/-ការកំណត់ការងារអាទិភាព៤ របស់ធនាគារកណ្ដាល ដូចជា ការអនុវត្តនយោបាយចម្រុះ (Policy Mix) ដើម្បីពង្រឹងការស្តារឡើងវិញនៃសេដ្ឋកិច្ច ការលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថិរភាពហិរញ្ញវត្ថុនិងម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ ការពន្លឿនការតភ្ជាប់ប្រព័ន្ធទូទាត់ និងការដាក់ចេញនូវវិធានការរួមគ្នាដើម្បីជំរុញសេដ្ឋកិច្ចឌីជីថល iii/-ការលើកកម្ពស់សេរីភាវូបនីយកម្មនិងសមាហរណកម្មហិរញ្ញវត្ថុប្រកបដោយភាពធន់ តាមរយៈ

ការរៀបចំក្របខ័ណ្ឌសមាហរណកម្មធនាគារអាស៊ាន និងការពង្រឹងថ្នាលចែករំលែកបច្ចេកវិទ្យាព័ត៌មាន iv/-ការជំរុញពាណិជ្ជកម្មនិងការវិនិយោគ តាមរយៈការធ្វើសេរីភាវូបនីយកម្មគណនីមូលធន និងការបង្កើនការប្រើប្រាស់រូបិយវត្ថុក្នុងតំបន់ v/-ការពង្រឹងការតភ្ជាប់ហិរញ្ញប្បទាន ការទូទាត់ទំនិញ និងសេវា តាមរយៈការអង្កេតលើការតភ្ជាប់ប្រព័ន្ធទូទាត់ពហុភាគី និងការធ្វើទំនើបកម្មការតភ្ជាប់ជាលក្ខណៈទ្វេភាគី vi/-ការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយការបំពុលបរិស្ថាន vii/-ការជំរុញបរិយាបន្នហិរញ្ញវត្ថុតាមរយៈការសម្រួលដល់អាជីវកម្មខ្នាតតូច ឱ្យមានលទ្ធភាពទទួលបានប្រភពមូលធន ការចែករំលែកព័ត៌មាន ឧត្តមានុវត្តន៍ និងបទពិសោធន៍ចំពោះការពង្រឹងចំណេះដឹងនិងសេវាហិរញ្ញវត្ថុឌីជីថល viii/-ការពង្រីកការផ្តល់ហិរញ្ញប្បទានសម្រាប់គ្រោះមហន្តរាយធម្មជាតិ ដើម្បីភាពធន់នៃសេដ្ឋកិច្ចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និង ix/-ការពង្រឹងទំនាក់ទំនងជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ាន, នាយកប្រតិបត្តិគ្រឹះស្ថានហិរញ្ញវត្ថុអាស៊ាន, ក្រុមប្រឹក្សាធុរកិច្ចអឺរ៉ុប-អាស៊ាន និងក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាមេរិក-អាស៊ាន។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមក្នុងការអនុម័តគោលការណ៍ដើម្បីបន្តរៀបចំកិច្ចព្រមព្រៀងអាស៊ានស្វប់ឡើងវិញ ព្រមទាំងបានសហការជាមួយសហប្រធាននៃគណៈកម្មាធិការកសាងសមត្ថភាពអាស៊ាន (SCCB) ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលរបស់អាស៊ានចំនួន ៥ ជូនមន្ត្រីជំនាញធនាគារជាតិនៃកម្ពុជា ក៏ដូចជាមន្ត្រីជំនាញមកពីធនាគារកណ្តាលអាស៊ានផ្សេងទៀត ព្រមទាំងចូលរួមអនុម័តផែនការនិងកម្មវិធីបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០២៤។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំថ្នាក់ប្រធានសវនកម្មផ្ទៃក្នុងនៃធនាគារកណ្តាលអាស៊ានលើកទី៨ លើប្រធានបទ "ការលើកកម្ពស់អភិបាលកិច្ចក្នុងបរិយាកាសនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស" ដែលកិច្ចប្រជុំនេះ មានគោលបំណងលើកកម្ពស់គុណភាពសវនកម្មផ្ទៃក្នុងប្រកបដោយស្តង់ដារវិជ្ជាជីវៈ សំដៅពង្រឹងអភិបាលកិច្ច ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃធនាគារកណ្តាល ក៏ដូចជាផ្តល់ឱកាសដល់មន្ត្រីសវនកម្មផ្ទៃក្នុងនៃធនាគារកណ្តាលអាស៊ានផ្លាស់ប្តូរបទពិសោធន៍និងពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត។

- **កិច្ចសហប្រតិបត្តិការអាស៊ាន+៣៖** កាលពីឆ្នាំ២០២២ ធនាគារជាតិនៃកម្ពុជាបានធ្វើជាសហប្រធានអាស៊ាន+៣ លើវិស័យធនាគារនិងហិរញ្ញវត្ថុ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ក្រសួងហិរញ្ញវត្ថុចិន និងធនាគារកណ្តាលចិន។ ឆ្នាំ២០២៣នេះ ក្រោមការដឹកនាំរបស់ប្រទេសឥណ្ឌូណេស៊ី និងជប៉ុន ដែលជាសហប្រធានប្តូរវេន ធនាគារជាតិនៃកម្ពុជាបន្តចូលរួមគាំទ្រនិងពង្រឹងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន+៣ ក្នុងគោលបំណងពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់ លើកកម្ពស់ការអនុវត្តយន្តការនៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ការពង្រីកប្រសិទ្ធភាពរបស់អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ និងការជំរុញគំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ី។






### ប្រអប់ ៣៖ កិច្ចសហប្រតិបត្តិការជាមួយអាស៊ាន+៣

លទ្ធផលការងារសំខាន់ៗនៃកិច្ចសហប្រតិបត្តិការអាស៊ាន+៣ រួមមាន៖ i/-ការកំណត់ទិសដៅអនាគតសម្រាប់ការរៀបចំហិរញ្ញប្បទានត្រៀមក្នុងតំបន់អាស៊ាន+៣ តាមរយៈការបង្កើតនូវឧបករណ៍ហិរញ្ញប្បទានថ្មី ការពិនិត្យមើលលើរចនាសម្ព័ន្ធនៃការរៀបចំហិរញ្ញប្បទាន ii/-ការធ្វើឱ្យប្រសើរឡើងនូវយន្តការហិរញ្ញប្បទាននៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) តាមរយៈការពិភាក្សាលើការកំណត់អត្រាការប្រាក់ និងការចូលរួមនិងសម្រេចបាននូវដំណើរការសាកល្បងលើកទី១៤ នៃយន្តការ CMIM iii/-ការអភិវឌ្ឍអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដូចជាការអនុម័តទិសដៅយុទ្ធសាស្ត្រឆ្នាំ២០៣០ ការធ្វើបច្ចុប្បន្នកម្មផែនការការងាររយៈពេលមធ្យម ការជំរុញការប្រែក្លាយទៅជាមជ្ឈមណ្ឌលចំណេះដឹងក្នុងតំបន់ (RKH) ការបង្កើតបណ្តាញអ្នកវិភាគហិរញ្ញវត្ថុអាស៊ាន+៣ (AFTN) និងការពង្រឹងអភិបាលកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់របស់អង្គភាព AMRO iv/-ការរៀបចំហិរញ្ញប្បទានត្រៀមសម្រាប់ហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិ v/-ការសិក្សាលើការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកនៅក្នុងប្រតិបត្តិការទូទាត់ឆ្លងដែនក្នុងតំបន់អាស៊ាន+៣ និងស្ថានភាពបំណុលសាជីវកម្មនិងសហគ្រាសធុនតូចនិងមធ្យមនៅក្នុងតំបន់ ការពង្រឹងតួនាទីនៃវិស័យហិរញ្ញវត្ថុក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង vi/-ការពង្រឹងគំនិតផ្តួចផ្តើមទីផ្សារសញ្ញាបណ្ណអាស៊ីតាមរយៈការអនុម័តលើផែនទីបង្ហាញផ្លូវរយៈពេលមធ្យមរបស់ ABMI ថ្មី ឆ្នាំ២០២៣-២០២៦ សំដៅអភិវឌ្ឍទីផ្សារមូលបត្របំណុលជារូបិយវត្ថុក្នុងស្រុក។

- **មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)៖** មូលនិធិរូបិយវត្ថុអន្តរជាតិបន្តជួយតាមដាន វាយតម្លៃ និងផ្តល់អនុសាសន៍គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដល់កម្ពុជា ព្រមទាំងផ្តល់ជំនួយបច្ចេកទេសនិងការកសាងសមត្ថភាពដល់ធនាគារជាតិនៃកម្ពុជា។ ក្នុងឆ្នាំ២០២៣នេះ ក្រុមការងារមន្ត្រីជំនាញរបស់ IMF បានបំពេញបេសកកម្មចំនួន២លើកគឺ៖ i/-បេសកកម្មពិគ្រោះយោបល់ (Staff Visit) នៅខែឧសភា និង ii/-បេសកកម្មពិគ្រោះយោបល់មាត្រាទី៤ (Article IV) នៅក្នុងខែតុលា។ បេសកកម្មទាំងពីរនេះធ្វើឡើងក្នុងគោលបំណងបន្តចូលរួមតាមដាន វាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុនិងធនាគារនៅកម្ពុជា តាមរយៈការផ្តល់ជូននូវអនុសាសន៍លើគោលនយោបាយសេដ្ឋកិច្ចចម្បងៗសម្រាប់ធនាគារជាតិនៃកម្ពុជាក៏ដូចជារាជរដ្ឋាភិបាល។ ជាមួយគ្នានេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានបន្តផ្តល់ជំនួយបច្ចេកទេស លើផ្នែកត្រួតពិនិត្យធនាគារ ផ្នែកស្ថិរភាពហិរញ្ញវត្ថុ ផ្នែកប្រតិបត្តិការរូបិយវត្ថុនិងទីផ្សារប្តូរប្រាក់ ផ្នែកស្ថិតិ និងផ្នែកតាមដាននិងវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានបន្តផ្តល់ការបណ្តុះបណ្តាលជូនមន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជាតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា។ លើសពីនេះ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំប្រចាំនិទាឃរដូវឆ្នាំ២០២៣ នៅរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក និងមហាសន្និបាតប្រចាំឆ្នាំ២០២៣ នៅទីក្រុងម៉ារ៉ាខេក ប្រទេសម៉ារ៉ុក និងកម្មវិធីសន្និសីទ ស្តីពី "រូបិយប័ណ្ណឌីជីថល" នៅទីក្រុងសេអ៊ូល សាធារណៈរដ្ឋកូរ៉េ ជាដើម។



- **ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)៖** ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសលើការធ្វើបច្ចុប្បន្នកម្មលើឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥" ទៅជា "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០២១-២០៣០"។ ទន្ទឹមនេះ ក្រុមជំនាញការគ្រោងនឹងបំពេញបេសកកម្មនៅកម្ពុជាក្នុងអំឡុងដើមឆ្នាំ២០២៤ ដើម្បីជួបប្រជុំពិភាក្សាដោយផ្ទាល់សម្រាប់ការធ្វើបច្ចុប្បន្នកម្មលើឯកសារខាងលើជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា។

- **ធនាគារពិភពលោក (WB)៖** គណៈប្រតិភូទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការជំនួយប្រឹក្សាផ្នែកគ្រប់គ្រងការវិនិយោគ (RAMP Program) របស់ធនាគារពិភពលោក បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការ ជាពិសេសជួយលើការងារគ្រប់គ្រងទុនបម្រុងអន្តរជាតិ។ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមក្នុងវេទិកាពិភាក្សាតុមូលជាន់ខ្ពស់ ស្តីពី "ការធ្វើបច្ចុប្បន្នកម្មលើការវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់កម្ពុជា" ក្នុងគោលបំណងពិភាក្សាអំពីការកំណត់គោលនយោបាយអាទិភាព សម្រាប់ជំរុញការអភិវឌ្ឍប្រកបដោយបរិយាបន្ន ព្រមទាំងបញ្ហាប្រឈមនិងដំណោះស្រាយ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងរៀបចំជាឯកសារវិនិច្ឆ័យស្ថានភាពប្រទេសដែលមានលក្ខណៈជាប្រព័ន្ធជំនាន់ទី២ (SCD-2) ដែលក្នុងនោះមានជាប់ពាក់ព័ន្ធនឹងការពង្រឹងបទប្បញ្ញត្តិ និងការត្រួតពិនិត្យវិស័យហិរញ្ញវត្ថុផងដែរ។

- **មជ្ឈមណ្ឌលស៊ាសិន (SEACEN)៖** នៅឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជា បន្តដឹកនាំក្រុមប្រឹក្សាទេសាភិបាលស៊ាសិន (BOG) និងបានចូលរួមសម្រេចការងារអាទិភាពរបស់ស៊ាសិនក្នុងការពង្រឹងការស្រាវជ្រាវ និងចែករំលែកចំណេះដឹង ព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក និងដៃគូយុទ្ធសាស្ត្រ។ ក្នុងនាមជាប្រធានគណៈកម្មាធិការប្រតិបត្តិសម្រាប់ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី២២ (EXCO) និងសិក្ខាសាលាជាន់ខ្ពស់លើកទី១៦ ដែលមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុដែលជាសមាជិកមជ្ឈមណ្ឌលស៊ាសិន និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ និងមានការចូលរួមពីវាគ្មិនកិត្តិយសមកពីសាកលវិទ្យាល័យអន្តរជាតិល្បីៗជាច្រើន។ ធនាគារជាតិនៃកម្ពុជា បានដឹកនាំកិច្ចសម្ភាសន៍បេក្ខជន និងការជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងនាយកប្រតិបត្តិ និងប្រធានទទួលបន្ទុកទៅលើស្ថិរភាពហិរញ្ញវត្ថុ ការត្រួតពិនិត្យ និងប្រព័ន្ធទូទាត់នៃមជ្ឈមណ្ឌលស៊ាសិន។ ធនាគារជាតិនៃកម្ពុជាក៏បានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលស៊ាសិនចំនួន ៣០ វគ្គ ព្រមទាំងបានសហការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ដើម្បីពង្រឹងសមត្ថភាពមន្ត្រីជំនាញផងដែរ។



- **កិច្ចសហការជាមួយស្ថាប័នផ្សេងៗ៖** ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិផ្សេងទៀតដូចជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) គណៈកម្មការសេដ្ឋកិច្ចនិងសង្គមកិច្ចសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP) កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP) កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) មូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ (UNCDF) សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ (KDIC) និងសមាគមអន្តរជាតិសម្រាប់ធានាប្រាក់បញ្ញើ (IADI) ជាដើម ដើម្បីរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ ពង្រឹងមូលដ្ឋានទិន្នន័យ គាំទ្រដល់ការថែរក្សាបរិស្ថាន ជំរុញសហគ្រិនភាពរបស់ស្ត្រី បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងហិរញ្ញវត្ថុ និងការជំរុញការប្រើប្រាស់រូបិយវត្ថុជាតិ ជាដើម។

## ប្រអប់ ៤៖ កិច្ចសហប្រតិបត្តិការពហុភាគីជាមួយស្ថាប័នផ្សេងៗ

- **ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ៖** JICA បាននិងកំពុងសហការជាមួយធនាគារជាតិនៃកម្ពុជាលើការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស ស្តីពី "ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ វិភាគសេដ្ឋកិច្ច និងប្រតិបត្តិការរូបិយវត្ថុ" ដែលមានរយៈពេល ៣ឆ្នាំ ចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៥ ក្នុងគោលបំណងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តនយោបាយរូបិយវត្ថុ តាមរយៈការធ្វើឱ្យប្រសើរឡើងនៃប្រតិបត្តិការទីផ្សាររូបិយវត្ថុអន្តរធនាគារ និងការពង្រឹងទំនាក់ទំនងជាមួយសាធារណជន សំដៅលើកកម្ពស់ការយល់ដឹងពីការអនុវត្តនយោបាយរូបិយវត្ថុ។ ក្រោមគម្រោងនេះ JICA បានរៀបចំវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន ស្តីពី "ការព្យាករសន្ទនីយភាព" ជូនដល់ក្រុមមន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជា ដើម្បី៖ i/-ពង្រឹងសមត្ថភាពលើការព្យាករចំណូល-ចំណាយរដ្ឋាភិបាល ii/-ក្របខណ្ឌព្យាករ iii/-ការតាមដានប្រតិបត្តិការទីផ្សារចំហ និង iv/-ការចេញផ្សាយរបាយការណ៍សន្ទនីយភាពរបស់ធនាគារកណ្តាលជប៉ុន។ ទន្ទឹមនេះ JICA បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈនូវសៀវភៅ "ដុល្លារូបនីយកម្មនៅកម្ពុជា៖ គោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs)" ដែលជាលទ្ធផលនៃកិច្ចសហការស្រាវជ្រាវរវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវ JICA Ogata Sadako។



- **គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (UNESCAP)៖** UNESCAP បានសហការរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់សហគ្រិនជាស្ត្រីក្នុងខេត្តចំនួន ៣ (ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបាត់ដំបង) ក្រោមគម្រោង ស្តីពី "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" ដែលមានគោលដៅសំខាន់ចំនួន ៣ រួមមាន៖ i/-សិក្សាអំពីលទ្ធភាពក្នុងការផ្តល់ឥណទានដោយមិនចាំបាច់មានទ្រព្យធានា ii/-ពង្រឹងសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជាលើបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការត្រួតពិនិត្យធនាគារ និង iii/-រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រី និងសហគ្រិនជាស្ត្រី ដើម្បីលើក-កម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុ

ផ្លូវការ។ ក្រោមកិច្ចសហការជាមួយ UNESCAP របាយការណ៍សិក្សាស្តីពី ការវិភាគទីផ្សារហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា "the Green and Sustainable Financial Market Analysis for the Financing Cambodia's Future" ត្រូវបានបញ្ចប់ជាស្ថាពរកាលពីដើមឆ្នាំ២០២៣។ ជាមួយគ្នានេះ បន្ទាប់ពីបានបញ្ចប់ការស្រាវជ្រាវលើប្រធានបទ "ការវិភាគលើទីផ្សារហិរញ្ញវត្ថុបៃតង និងចីរភាពហិរញ្ញវត្ថុនៅកម្ពុជា" អង្គការ UNESCAP និងធនាគារជាតិនៃកម្ពុជាក៏បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីការអភិវឌ្ឍផែនទីចង្អុលផ្លូវ "ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា" ដើម្បីពង្រឹងបន្ថែមទៀតនូវការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែមានភាពធន់ ស្ថិរភាព និងអាចចូលរួមក្នុងការកៀរគរហិរញ្ញប្បទានសម្រាប់សកម្មភាពទប់ទល់ការប្រែប្រួលអាកាសធាតុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមគំនិតជាមួយ UNESCAP និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតដែលរៀបចំវេទិកាស្តីពី "ការបង្កើនហិរញ្ញប្បទានដល់ស្ត្រី៖ ឧបករណ៍ក្នុងការពន្លឿនដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" ស្របពេលជាមួយកម្មវិធីនៃមហាសន្និបាតអង្គការសហប្រជាជាតិ។ វេទិកានេះបានជំរុញឱ្យសមាជិករបស់ UNESCAP បន្តយកចិត្តទុកដាក់លើការផ្តល់ហិរញ្ញប្បទានទប់ទល់អាកាសធាតុដែលយកចិត្តទុកដាក់ដល់ស្ត្រី (Gender Climate Financing) ការវិនិយោគដែលផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី (Gender Impact Investing) និងការពង្រឹងយន្តការនិងគោលនយោបាយកាត់បន្ថយវិសមភាពយេនឌ័រជាដើម។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំលើកទី៥ របស់គណៈកម្មការគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍរបស់ UNESCAP ដែលក្នុងនោះធនាគារជាតិនៃកម្ពុជាបានបង្កើតឱ្យមានគំនិតផ្តួចផ្តើមជាច្រើនក្នុងការរៀបចំយន្តការគាំទ្រហិរញ្ញប្បទានប្រកបដោយចីរភាព រួមមាន ការរៀបចំឱ្យមានផែនទីចង្អុលផ្លូវសម្រាប់ការជំរុញហិរញ្ញប្បទានប្រកបដោយចីរភាព ការបង្កើតឱ្យមានវេទិកាសាស្ត្រសម្រាប់គាំទ្រលំហូរមូលធន ការដាក់ចេញនូវក្របខ័ណ្ឌនៃការរាយការណ៍ និងការកសាងសមត្ថភាព ជាដើម។ ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាក៏បានប្រជុំទ្វេភាគីជាមួយអគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាអគ្គលេខាធិការអង្គការ UNESCAP ដើម្បីពិភាក្សាពីកិច្ចសហប្រតិបត្តិការដែលកំពុងអនុវត្ត និងបានឯកភាពលើចំណុចសំខាន់ក្នុងការជំរុញលំហូរមូលធន ដើម្បីបង្កើនការវិនិយោគបៃតង និងប្រកបដោយចីរភាព នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយ UNESCAP ដើម្បីសហការរៀបចំបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់កម្ពុជា (Sustainable Finance Roadmaps)។



- **កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ (UNEP)៖** ធនាគារជាតិនៃកម្ពុជាបានជួបពិភាក្សាជាមួយ UNEP អំពីគម្រោង "EmPower II៖ ស្ត្រីសម្រាប់សង្គមដែលមានភាពរឹងមាំទប់ទល់នឹងការប្រែប្រួលអាកាសធាតុ" ក្នុងគោលបំណងចូលរួមចំណែកដាក់ចេញអនុសាសន៍គោលនយោបាយចំពោះការប្រែប្រួលអាកាសធាតុ និងពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់សិទ្ធិអំណាចដល់ស្ត្រីនិងសមភាពយេនឌ័រក្នុងការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងសកម្មភាពទាំងឡាយដែលកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធម្មជាតិ។
- **កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP)៖** ធនាគារជាតិនៃកម្ពុជាបានចូលរួមសហការជាមួយ UNDP ដើម្បីពិភាក្សាលើគម្រោង "Blended Finance" សម្រាប់វិស័យសុខាភិបាល ដោយប្រើប្រាស់ហិរញ្ញប្បទានរបស់គម្រោងអភិវឌ្ឍន៍ជួយដល់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចក្នុងគោលដៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ពាក់ព័ន្ធនឹងការអង្កេតលើការប្រើប្រាស់រូបិយវត្ថុរបស់រោងចក្រ និងសហគ្រាស ធនាគារជាតិនៃកម្ពុជា និង UNDP បានសហការសិក្សាពីកម្រិតដុល្លារូបនីយកម្មនៅកម្ពុជា ដោយបច្ចុប្បន្នបានសម្រេចសេចក្តីព្រាងឯកសារស្រាវជ្រាវក្រោមប្រធានបទ "ដុល្លារូបនីយកម្មនិងឥទ្ធិពលទៅលើវិស័យវាយនភ័ណ្ឌនៅកម្ពុជា៖ ឆ្ពោះទៅកាន់ការជំរុញការប្រើប្រាស់ប្រាក់រៀលក្នុងការបើកប្រាក់បៀវត្ស"។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលរួមពិភាក្សាលើសេចក្តីព្រាងឯកសារកម្មវិធីប្រចាំប្រទេសឆ្នាំ២០២៤-២០២៨ (New Country Programme) ក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់អន្តរក្រសួង ដែលរៀបចំដោយ UNDP ក្នុងគោលបំណងសម្រេចតាមកម្មវិធីរបស់ UNDP យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងក្របខណ្ឌកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយ UNDP រៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំក្រោមប្រធានបទ ហានិភ័យអាកាសធាតុនិងអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង។
- **មូលនិធិអភិវឌ្ឍន៍ទុនរបស់អង្គការសហប្រជាជាតិ (UNCDF)៖** ធនាគារជាតិនៃកម្ពុជា និង UNCDF បានសហការប្រមូលទិន្នន័យសម្រាប់ជាសូចនាករមូលដ្ឋាន (Baseline) ក្នុងការវាស់វែងកម្រិតបរិយាបន្នហិរញ្ញវត្ថុ ដោយផ្តោតលើការទទួលបាន ការប្រើប្រាស់ និងការពង្រឹងគុណភាពសេវាហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់ តាមរយៈការសិក្សាទៅលើផ្នែកផ្គត់ផ្គង់ (Supply Side) និងផ្នែកតម្រូវការ (Demand Side) ហើយជាលទ្ធផល របាយការណ៍វាយតម្លៃលើដំណើរការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាសម្រាប់ឆ្នាំ២០២១ ត្រូវបាន

ផ្សព្វផ្សាយជាសាធារណៈ។ ទន្ទឹមនេះ ការបកប្រែនិងបោះពុម្ពសៀវភៅស្តីពី លទ្ធផលសង្ខេបនៃការអង្កេតអ្នកប្រើប្រាស់សម្រាប់ឆ្នាំ២០២១ ជាខេមរភាសាសម្រាប់ផ្សព្វផ្សាយជូនសាធារណជនត្រូវបានបញ្ចប់ជាស្ថាពរ ដែលសៀវភៅនេះផ្តោតលើព័ត៌មានសំខាន់ៗនៃការប្រែប្រួលបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជារវាងឆ្នាំ២០១៥ និងឆ្នាំ២០២១ ដែលរួមមាន៖ i/-ចំនួនប៉ាន់គំរូបែងចែកតាមខេត្ត/ក្រុង អាយុ ភេទ និងកម្រិតអប់រំ ii/-ទិន្នន័យបរិយាបន្នហិរញ្ញវត្ថុ iii/-ទិន្នន័យបរិយាបន្នហិរញ្ញវត្ថុត្រួតស៊ីគ្នា iv/-ទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមតំបន់ អាយុ ភេទ និងកម្រិតអប់រំ v/-ទិន្នន័យនៃការប្រើប្រាស់សេវាឥណទាន vi/-ទិន្នន័យនៃការប្រើប្រាស់សេវាសន្សំ vii/-ទិន្នន័យនៃការប្រើប្រាស់សេវាធានារ៉ាប់រង និង viii/-ទិន្នន័យនៃការប្រើប្រាស់សេវាផ្ទេរប្រាក់ ជាដើម។

- **សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI)៖** ក្រោមជំនួយរបស់ AFI ផែនទីចង្អុលផ្លូវស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ឆ្នាំ២០២៣-២០២៨ ត្រូវបានបន្តធ្វើបច្ចុប្បន្នកម្មសម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងកំណត់ក្របខ័ណ្ឌលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថល ដើម្បីជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការបង្កើនការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយបរិយាបន្ននិងចីរភាព។ ធនាគារជាតិនៃកម្ពុជា និង AFI ក៏បានសហការអភិវឌ្ឍក្របខ័ណ្ឌប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទ ក្នុងគោលដៅកំណត់ចន្លោះខ្វះខាតនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុបែងចែកតាមភេទឱ្យកាន់តែមានប្រសិទ្ធភាពនិងត្រឹមត្រូវ ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញគោលនយោបាយដែលនឹងជួយជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុរបស់ស្ត្រីស្របតាមគោលដៅនៃយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា បានបញ្ចប់សេចក្តីព្រាងទម្រង់របាយការណ៍ចំនួន ៨ រួមមាន៖ i/-របាយការណ៍ប្រាក់បញ្ញើបែងចែកតាមប្រភេទ និងតាមភេទ ii/-របាយការណ៍ប្រាក់បញ្ញើឯកត្តជនបែងចែកតាមភេទ ប្រភេទ ក្រុមអាយុ និងខេត្ត/ក្រុង iii/-របាយការណ៍ឥណទានបែងចែកតាមភេទ និងប្រភេទ iv/-របាយការណ៍ឥណទានបែងចែកតាមភេទ ចំណាត់ថ្នាក់ឥណទាន និងខេត្ត/ក្រុង v/-របាយការណ៍អ្នកខ្ចីប្រាក់បែងចែកតាមភេទ ចំណាត់ថ្នាក់ឥណទាន និងក្រុមអាយុ vi/-របាយការណ៍ទូទាត់ប្រាក់បែងចែកតាមភេទ និងប្រភេទប្រតិបត្តិការ vii/-របាយការណ៍បរិយាបន្នហិរញ្ញវត្ថុផ្សេងទៀតបែងចែកតាមភេទ និង viii/-របាយការណ៍ប្រជាសាស្ត្រ និងសូចនាករម៉ាក្រូសេដ្ឋកិច្ច។ របាយការណ៍ប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទទាំងនេះ ត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តសាកល្បងក្នុងត្រីមាសទី៤ ឆ្នាំ២០២៣។ក្រោមកិច្ចសហការរវាង AFI និងធនាគារកណ្តាលហ្វីលីពីន ធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ កិច្ចប្រជុំក្រុមការងារនិងវេទិកាគោលនយោបាយសកលក្នុងគោលបំណងពិភាក្សាពីគោលនយោបាយនិងការដោះស្រាយបញ្ហាប្រឈមនានាសម្រាប់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងនិរន្តរភាពហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមប្រជុំក្រុមប្រឹក្សាភិបាលរបស់ AFI និងកិច្ចប្រជុំទ្វេភាគីជាមួយនាយកប្រតិបត្តិ AFI និងអង្គការក្រុមប្រឹក្សាយោបល់សម្រាប់ជួយដល់ជនក្រីក្រ (CGAP) ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនិងទិសដៅអនាគតនៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។

- **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** ធនាគារជាតិនៃកម្ពុជា និង IFC បានសហការអនុវត្តគម្រោងស្តីពី ការអភិវឌ្ឍទីផ្សារខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុនៅកម្ពុជា (Cambodia Supply Chain Finance Market Development) ក្នុងគោលដៅអភិវឌ្ឍទីផ្សារខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុដើម្បីពង្រីកលទ្ធភាពដល់ការទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្មនៅកម្ពុជា ជាពិសេស សហគ្រាសធុនតូច និងមធ្យម ព្រមទាំងពង្រឹងខ្សែច្រវាក់ផលិតកម្មនៅកម្ពុជា។ ជាមួយគ្នានេះ IFC បានសហការជាមួយ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា រៀបចំសិក្ខាសាលាសម្រាប់និយ័តករ ស្តីពី "ការអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទនៅកម្ពុជា៖ ឧបករណ៍សម្រាប់គ្រប់គ្រងហានិភ័យ" ដើម្បីចូលរួមចំណែកអភិវឌ្ឍទីផ្សារឧបករណ៍និស្សន្ទចារឹកជាប្រាក់រៀលឱ្យមានបទប្បញ្ញត្តិគ្រប់គ្រងត្រឹមត្រូវ ហើយប្រើប្រាស់ជាឧបករណ៍គ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព សំដៅជំរុញការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុចារឹកជាប្រាក់រៀល ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ IFC និង ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមពង្រឹងការអនុវត្តតាមទីផ្សារ និងកិច្ចការពារអ្នកប្រើប្រាស់ ដោយបានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីធនាគារជាតិនៃកម្ពុជា លើប្រធានបទ ស្តីពី យន្តការត្រួតពិនិត្យទីផ្សារ និងកិច្ចការពារអតិថិជន ព្រមទាំងបានគាំទ្រក្នុងការងារធ្វើបច្ចុប្បន្នកម្មប្រកាស ស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលបានដាក់ចេញនៅក្នុងឆ្នាំ២០១៧ ដើម្បីឱ្យស្របតាមច្បាប់ ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ ដែលបានដាក់ចេញនៅក្នុងឆ្នាំ២០១៩។ លើសពីនេះ IFC និងសមាគមធនាគារនៅកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពីការអភិវឌ្ឍទីផ្សារខ្សែច្រវាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំកម្ពុជា ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពី ការអភិវឌ្ឍប្រព័ន្ធវត្ថិករសាស្ត្រ និងទីផ្សារហិរញ្ញវត្ថុបៃតងកម្ពុជា ក្នុងគោលបំណងដើម្បីចូលរួមដោះស្រាយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងពន្លឿនការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចបៃតង។ កិច្ចសហប្រតិបត្តិការនេះនឹងជួយជំរុញការអភិវឌ្ឍប្រព័ន្ធវត្ថិករសាស្ត្រហិរញ្ញវត្ថុបៃតងកម្ពុជា ពង្រឹងសមត្ថភាពស្ថាប័នហិរញ្ញវត្ថុ និងបង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុអំណោយផលសម្រាប់គម្រោងវិនិយោគបៃតង សំដៅលើកកម្ពស់ដំណើរការអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- **សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើកូរ៉េ (KDIC)៖** ធនាគារជាតិនៃកម្ពុជា និង KDIC បានចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគី ក្នុងគោលបំណងចែករំលែកចំណេះដឹង វគ្គបណ្តុះបណ្តាល និងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងការការពារប្រាក់បញ្ញើ និងដំណោះស្រាយសម្រាប់ធនាគារសំដៅរៀបចំប្រព័ន្ធការពារប្រាក់បញ្ញើ និងដំណោះស្រាយសម្រាប់ធនាគារនៅកម្ពុជា។
- **សមាគមន៍អន្តរជាតិសម្រាប់ធានាប្រាក់បញ្ញើ (IADI)៖** ធនាគារជាតិនៃកម្ពុជា បានចូលជាសមាជិកមិនពេញលេញរបស់សមាគមន៍ IADI ចាប់តាំងពីឆ្នាំ២០១៨ ហើយបានបន្តទទួលបានការផ្តល់ប្រឹក្សាលើគោលការណ៍ស្នូលនៃប្រព័ន្ធការពារប្រាក់បញ្ញើ ក៏ដូចជាទទួលបាននូវការកសាងសមត្ថភាពដល់មន្ត្រីបុគ្គលិកលើការការពារប្រាក់បញ្ញើ។

## ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុនានា ទាំងក្នុងតំបន់និងពិភពលោក ដែលក្នុងនោះសមិទ្ធផលការងារចម្បងៗរួមមាន៖



- រៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគារកណ្តាលថៃ នៅរាជធានីភ្នំពេញ ព្រមទាំងរៀបចំកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (QR Code) រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដំណាក់កាលទី២ "ថៃស្កេនឃ្យូអរកូតនៅកម្ពុជា" ដែលអនុញ្ញាតប្រជាជនកម្ពុជានិងថៃអាចស្កេន QR Code ដើម្បីទូទាត់ថ្លៃទិញទំនិញនិងសេវាបាន។ លើសពីនេះ ក្រោមស្មារតីនៃកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលថៃ ធនាគារជាតិនៃកម្ពុជាក៏បញ្ជូនមន្ត្រីជំនាញទៅធ្វើទស្សនកិច្ចសិក្សានៅធនាគារកណ្តាលថៃ ដើម្បីស្វែងយល់និងអភិវឌ្ឍការងារប្រតិបត្តិការធនាគារកណ្តាល។



- រៀបចំកិច្ចប្រជុំទ្វេភាគីជាមួយធនាគាររដ្ឋវៀតណាមនៅខេត្តសៀមរាប និងបានរៀបចំកម្មវិធីដាក់ឱ្យដំណើរការជាផ្លូវការនៃការទូទាត់ឆ្លងដែនតាម QR Code រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជា និងវៀតណាមអាចស្កេន QR Code ដើម្បីទូទាត់ថ្លៃទំនិញ និងសេវាបាន។



- ចូលរួមកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគារកណ្តាលឡាវនៅប្រទេសឡាវ និងកម្មវិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ការទូទាត់ឆ្លងដែនតាមរយៈ QR Code រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាធ្វើការទូទាត់ការទិញទំនិញនិងសេវាតាមរយៈការស្កេន QR Code នៅប្រទេសឡាវបាន។ ទន្ទឹមនេះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយធនាគារកណ្តាលឡាវកម្រិត

បច្ចេកទេស ធនាគារកណ្តាលទាំងពីរបានអនុវត្តកម្មវិធីទស្សនកិច្ចសិក្សាលើប្រធានបទចំនួន ៤ និងបានឯកភាពលើប្រធានបទចំនួន ១១ នាពេលអនាគត ដើម្បីពង្រឹងសមត្ថភាព និងចំណងមិត្តភាពរវាងមន្ត្រីជំនាញនៃស្ថាប័នទាំងពីរ។

- ចូលរួមសហការជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរីដើម្បីសម្ពោធជាផ្លូវការលើគម្រោង ការផ្តល់សេវាចែករំលែកព័ត៌មានឥណទានឆ្លងតំបន់រវាងប្រទេសកម្ពុជា និងសិង្ហបុរី ក្នុងគោលបំណងបង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថល សម្រាប់សម្រួល ដល់ពាណិជ្ជកម្ម និងធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពនៃការទទួលបានសេវាហិរញ្ញវត្ថុឆ្លងដែនរវាងសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលធ្វើឱ្យប្រតិបត្តិការអាជីវកម្មរបស់សហគ្រាសទាំងនោះកាន់តែរីកចម្រើន និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច។



- បានចុះអនុស្សរណៈយោគយល់ជាមួយក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន ស្តីពី "ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត (Unified QR Code-Based Payment) ក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលកម្ពុជា-ជប៉ុន នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ក្នុងគោលបំណងកំណត់ក្របខ័ណ្ឌជាក់លាក់ សម្រាប់កិច្ចសហប្រតិបត្តិការលើកកម្ពស់សកម្មភាពប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាម QR Code ប្រកបដោយភាពងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាព។

- រៀបចំចុះអនុស្សរណៈយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលឥណ្ឌូណេស៊ី។ ជាមួយគ្នានេះ ក្រុមមន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជាធ្វើទស្សនកិច្ចសិក្សានៅធនាគារកណ្តាលឥណ្ឌូណេស៊ី ដើម្បីសិក្សាស្វែងយល់ពីប្រតិបត្តិការធនាគារកណ្តាលរបស់ឥណ្ឌូណេស៊ី និងបានចូលរួមចែករំលែកបទពិសោធន៍ស្តីពីសេវាធនាគារកណ្តាល ដែលរៀបចំឡើងដោយធនាគារកណ្តាលឥណ្ឌូណេស៊ី។



- ធ្វើទស្សនកិច្ចសិក្សានៅធនាគារកណ្តាលម៉ាឡេស៊ី ដើម្បីសិក្សាស្វែងយល់ពីប្រតិបត្តិការធនាគារកណ្តាលម៉ាឡេស៊ី ក្នុងគោលបំណងពង្រឹងសមត្ថភាពប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា។

- បានចុះអនុស្សរណៈយោគយល់ចំនួន ២ ជាមួយធនាគារកណ្តាលចិន ស្តីពី i/-កិច្ចសហប្រតិបត្តិការនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់សងប្រាក់ និង ii/-ការបង្កើតកិច្ចសម្របសម្រួលក្នុងការទូទាត់និងផាត់ទាត់នៅកម្ពុជា នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងជំរុញនវានុវត្តន៍ក្នុងវិស័យធនាគារនិងប្រព័ន្ធទូទាត់សងប្រាក់ លើកកម្ពស់សុវត្ថិភាព និងប្រសិទ្ធភាពប្រតិបត្តិការទូទាត់ឆ្លងដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន និងកសាងសមត្ថភាពវិស័យធនាគារនៅកម្ពុជាដើម្បីឆ្លើយតបទៅនឹងកំណើននៃពាណិជ្ជកម្ម ការវិនិយោគ និងលំហូរហិរញ្ញវត្ថុទ្វេភាគីរវាងប្រទេសចិននិងកម្ពុជា។



- បានចុះអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុជាមួយធនាគារកណ្តាលនៃកោះសូឡូម៉ូន នៅរាជធានីភ្នំពេញ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ ដើម្បីចែករំលែកព័ត៌មានស្តីអំពីនវានុវត្តន៍ និងការទូទាត់តាមបែបឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចែករំលែកបទពិសោធន៍ជាមួយធនាគារកណ្តាលនៃកោះសូឡូម៉ូន ស្តីពី ការផ្តល់អាជ្ញាបណ្ណ វិធីសាស្ត្រក្នុងការត្រួតពិនិត្យ សវនកម្ម ការអភិវឌ្ឍព័ត៌មានឥណទានឆ្លងដែន និងប្រវត្តិនិងការបង្កើតប្រព័ន្ធទូទាត់បាគង ជាដើម។



- បានចុះអនុស្សរណៈយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុជាមួយធនាគារកណ្តាលហ្វីជី នៅរាជធានីភ្នំពេញ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ ដើម្បីចែករំលែកព័ត៌មានពាក់ព័ន្ធស្តីពីនវានុវត្តន៍ និងការទូទាត់តាមបែបឌីជីថលសម្រាប់សេវាកម្មហិរញ្ញវត្ថុ។



- បានចុះអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងផ្នែកផ្សេងៗ នៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ" ជាមួយធនាគារកណ្តាលរវ៉ាន់ដា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ ព្រមទាំងដើម្បីចែករំលែកព័ត៌មាននិងចំណេះដឹងស្តីពីនវានុវត្តន៍ ការទូទាត់ឌីជីថលសម្រាប់សេវាហិរញ្ញវត្ថុ ការចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានចូលរួមក្នុងវេទិកាបរិយាបន្នបច្ចេកវិទ្យាហិរញ្ញវត្ថុ "INCLUSIVE FINTECH FORUM" នៅប្រទេសរវ៉ាន់ដា ដើម្បីបង្ហាញអំពីវឌ្ឍនភាពនៃប្រព័ន្ធបាគង និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅប្រទេសកម្ពុជាដល់បណ្តាប្រទេសនៅក្នុងតំបន់អាហ្វ្រិក ក៏ដូចជាស្វែងរកនូវកិច្ចសហប្រតិបត្តិការជាលក្ខណៈទ្វេភាគីបន្ថែមទៀត។



- បានចូលរួមក្នុងវេទិកាពិភាក្សាតុមូលវ៉ាឌូស (Vaduz Roundtable) ស្តីពី "ប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ២០២៣" នៅរាជធានីវ៉ាឌូស ប្រទេសលិចតិនស្តាញ ដើម្បីពិភាក្សា និងផ្លាស់ប្តូរទស្សនៈនិងបទពិសោធន៍ ក្នុងគោលបំណងលើកកម្ពស់ការច្នៃប្រឌិតនវានុវត្តន៍ឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុ។
- បានសហការរៀបចំកម្មវិធីស្រាវជ្រាវរួមគ្នាជាមួយធនាគារកណ្តាលកូរ៉េក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹងរបស់ធនាគារកណ្តាលកូរ៉េ (BOK-KPP)" សម្រាប់ឆ្នាំ២០២៣ លើប្រធានបទ "ការទំនាក់ទំនង និងផ្សព្វផ្សាយសាធារណៈរបស់ធនាគារកណ្តាល"។



- បានចែករំលែកបទពិសោធន៍ក្នុងការរៀបចំ និងគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ការផ្តល់អាជ្ញាបណ្ណ វិធីសាស្ត្រក្នុងការត្រួតពិនិត្យ សវនកម្ម ការអភិវឌ្ឍព័ត៌មានឥណទានឆ្លងដែន ព្រមទាំងប្រវត្តិនិងការបង្កើតប្រព័ន្ធទូទាត់បាគង ជាមួយធនាគារកណ្តាលនៃប្រទេសមួយចំនួនដូចជា ប្រទេសប៉ាពួអាស៊ីនូវែលហ្គីណេ និងប្រទេសវ៉ានូទូ។

ក្រោមកិច្ចសហប្រតិបត្តិការល្អជាមួយធនាគារកណ្តាល និងស្ថានទូតនានាប្រចាំកម្ពុជា មន្ត្រីធនាគារជាតិនៃកម្ពុជាទទួលបានអាហារូបករណ៍និងវគ្គបណ្តុះបណ្តាលទៅសិក្សានៅក្រៅប្រទេសជាបន្តបន្ទាប់ ដែលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។ ជាក់ស្តែង ក្នុងឆ្នាំ២០២៣ មានមន្ត្រីចំនួន២៣រូប បានទៅសិក្សានៅក្រៅប្រទេស រួមមាន ប្រទេសនូវែលសេឡង់ កូរ៉េ អូស្ត្រាលី ជប៉ុន សហរដ្ឋអាមេរិក សាធារណរដ្ឋឆែក លុចសំបួរ ចិន និងអាល្លឺម៉ង់ជាដើម។

## ៣- សន្និដ្ឋាន

ជារួម ក្នុងឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជាបានខិតខំបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី តាមរយៈការចូលរួមសហការក្នុងគំនិតផ្តួចផ្តើមនានាដើម្បីលើកកម្ពស់សមាហរណកម្មឱ្យស៊ីជម្រៅ ការចុះអនុស្សរណៈសំដៅជំរុញកិច្ចសហប្រតិបត្តិការ ការចែករំលែកចំណេះដឹងនិងបទពិសោធន៍ ការបញ្ជូនមន្ត្រីបុគ្គលិកទៅសិក្សារៀនសូត្រពីឧត្តមានុវត្តនានាពាក់ព័ន្ធនឹងការងារបច្ចេកទេសរបស់ធនាគារកណ្តាល ការចូលរួមធ្វើការសិក្សាស្រាវជ្រាវរួមគ្នា និងការទទួលយកគោលនយោបាយនិងអនុសាសន៍ល្អដែលមានអត្ថប្រយោជន៍មកពិចារណា។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់ និងកសាងសមត្ថភាពជាលំដាប់ដើម្បីទាញយកប្រយោជន៍ពីការរីកចម្រើន និងការអភិវឌ្ឍថ្មីៗជាសកល ព្រមទាំងលើកស្ទួយកិត្តិនាមកម្ពុជាលើឆាកអន្តរជាតិ សំដៅរួមចំណែកអភិវឌ្ឍស្ថាប័ននិងសង្គមជាតិប្រកបដោយចីរភាពនិងបរិយាបន្ន ឱ្យស្របទៅតាមទិសដៅនិងនិន្នាការនៃការវិវឌ្ឍនៅក្នុងតំបន់និងពិភពលោក។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖



**លោកជំទាវ ជា សិរី**

អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

ជាប្រធាន



**ឯកឧត្តម ស៊ុំ សន្និសិទ្ធ**

ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា

ជាសមាជិក



**ឯកឧត្តម ហួត ពុំ**

តំណាងប្រមុខរាជរដ្ឋាភិបាល

ជាសមាជិក



**ឯកឧត្តម រស់ សីលវ៉ា**

តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាសមាជិក



**លោកស្រី អេង នេត្រា**

តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា

ជាសមាជិកា



**លោក ឡាយ ម៉េងស៊ុន**

តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច

ជាសមាជិក



**លោក មុំ ដារ៉េត**

តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា

ជាសមាជិក

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើក គឺកិច្ចប្រជុំក្រុមប្រឹក្សាភិបាលៈ

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៦ កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២២។
- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៧ កាលពីថ្ងៃពុធ ៣រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២២ និងផែនការឆ្នាំ២០២៣។
- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៨ កាលពីថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជា។
- លើកទី៤៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៥៩ កាលពីថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ដើម្បីប្រកាសអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា និងអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្មី។
- លើកទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦០ កាលពីថ្ងៃពុធ ៦កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីប្រកាសសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាថ្មី និងរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា។
- លើកទី៦៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦១ កាលពីថ្ងៃចន្ទ ១៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា។

កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម ជា ចាន់តូ ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់តែងតាំងជាអគ្គទេសាភិបាលកិត្តិយសនៃធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី ហើយនៅថ្ងៃដដែលនេះ លោកជំទាវ ជា សិរី ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់តែងតាំងជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី។ ក្នុងឋានៈជាទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា លោកជំទាវ ទេសាភិបាល ក៏ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាថ្មីផងដែរ។ ជាមួយគ្នានេះ សមាជិកក្រុមប្រឹក្សាភិបាលចំនួន ២រូបបានបញ្ចប់អាណត្តិគឺ ឯកឧត្តម ជូ គឹមឡេង តំណាងប្រមុខរាជរដ្ឋាភិបាល និង ឯកឧត្តម អ៊ឺរ ចុង តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា។ សមាសភាពក្រុមប្រឹក្សាភិបាលទាំង២ ត្រូវបានជំនួសដោយ៖ i/- ឯកឧត្តម ហួត ពុំ តំណាងប្រមុខរាជរដ្ឋាភិបាល និង ii/- លោកស្រី អេង នេត្រា តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា។





## ២- ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនមន្ត្រី-បុគ្គលិកប្រកបដោយគុណវុឌ្ឍិ រចនាសម្ព័ន្ធការងាររឹងមាំ និងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានអភិវឌ្ឍស្របនឹងតម្រូវការនៃសមាហរណកម្មនៅក្នុងតំបន់និងពិភពលោក ព្រមទាំងគោលការណ៍នៃស្ថិរភាព និងប្រសិទ្ធភាពការងារ។

មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាត្រូវបានបញ្ជូនទៅសិក្សាលើវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនិងវែង ទាំងក្នុងនិងក្រៅប្រទេស រួមមានកម្រិតសិក្សាបរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិតផងដែរ។

**ក្រាហ្វ ១០៨៖ ស្ថិតិមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា តាមកម្រិតវប្បធម៌**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងពង្រឹងបន្ថែមទៀតលើវគ្គសិក្សា FSI-Connect និងវគ្គសិក្សា FPP និងវគ្គបណ្តុះបណ្តាលផ្ទៃក្នុងផ្សេងទៀត ដើម្បីពង្រឹងសមត្ថភាពចំណេះដឹង ចំណេះធ្វើដល់មន្ត្រី-បុគ្គលិកសាខារបស់ខ្លួន។

### ក- ស្ថិតិមន្ត្រី-បុគ្គលិក

មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសមានចំនួន ១.៩៣២ រូប (ប្រុស ៩៨១ រូប ស្រី ៩៥១ រូប) ក្នុងនោះទីស្នាក់ការកណ្តាលមាន ១.៤១៩ រូប (ប្រុស ៧៤៤ រូប ស្រី ៦៧៥ រូប) និងសាខារាជធានី-ខេត្ត មាន ៥១៣ រូប (ប្រុស ២៣៧ រូប ស្រី ២៧៦ រូប)។ នៅឆ្នាំ២០២៣នេះ ក្របខ័ណ្ឌមន្ត្រី-បុគ្គលិកនៅទីស្នាក់ការកណ្តាលបានកើនឡើង ៩១ រូប ខណៈសាខាបានកើនឡើង ២ រូប។




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- ការបណ្ដុះបណ្ដាល

### - ការងារបណ្ដុះបណ្ដាលក្នុងប្រទេស

សមត្ថភាពមន្ត្រីបុគ្គលិកត្រូវបានអភិវឌ្ឍជាប្រចាំតាមរយៈ វគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងកិច្ចប្រជុំដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា និងជាការអញ្ជើញរបស់ក្រសួង-ស្ថាប័ននានា ដែលរួមមាន៖ សិក្ខាសាលាចំនួន ៩០ លើក (សិក្ខាកាមចូលរួម ៣៥០ រូប) វគ្គសិក្សា ១៥ លើក (សិក្ខាកាមចូលរួម ៩០០ រូប) និងកិច្ចប្រជុំ ៨០ លើក (មន្ត្រីបុគ្គលិកចូលរួម ១.១០០ រូប) ។ ទន្ទឹមនេះ កម្មវិធីចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាត្រូវបានរៀបចំជូនសិស្ស-និស្សិតមកពីបណ្ដាគ្រឹះស្ថានឧត្តមសិក្សា ១៥ លើក (សិស្ស-និស្សិតចូលរួមចំនួន ២៥០ រូប)។









ជាមួយគ្នានេះ គិតត្រឹមឆ្នាំ២០២៣ ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញក៏ត្រូវបានរៀបចំឡើងចំនួន ៣ វគ្គសិក្សា គឺ i/- វគ្គសិក្សា NBC FSI-Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ត្រូវបានរៀបចំដល់ជំនាន់ទី៧ និងមានសិក្ខាកាមចូលរួមសិក្សាសរុបចំនួន ៣៨១រូប ក្នុងនោះមានសិក្ខាកាមអាហារូបករណ៍ ២៥ រូប។ គុណភាពសិក្សាត្រូវបានវាយតម្លៃតាមរយៈការប្រឡងតាមប្រព័ន្ធអនឡាញជាបន្តបន្ទាប់បានចំនួន ៥១ លើក ហើយមានមន្ត្រី-បុគ្គលិកប្រឡងបញ្ចប់កម្រិតបឋមមានចំនួន ១២៨ រូប កម្រិតមធ្យម ៧៩ រូប និងកម្រិតខ្ពស់ ១០៨ រូប ii/-វគ្គសិក្សា ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មាន ៤ ជំនាន់ និងមានសិក្ខាកាមសរុបចំនួន ៣០៨រូប ក្នុងនោះមន្ត្រីបុគ្គលិកជំនាន់ទី១ មាន ៥១ រូប ជំនាន់ទី២មាន ១០៥ រូប ជំនាន់ទី៣មាន ៩៩ រូប និងជំនាន់ទី៤ មាន ៤៩ រូប ដោយសិក្ខាកាមទាំង៤ជំនាន់នេះ បានប្រឡងបញ្ចប់កម្មវិធីសិក្សាទាំងពីរកម្រិតតាមប្រព័ន្ធអនឡាញជាផ្លូវការដោយជោគជ័យ និង iii/-វគ្គសិក្សា Macroeconomic Diagnostics របស់ IMF មាន ១ ជំនាន់ និងមានសិក្ខាកាមកំពុងសិក្សាចំនួន ៤៣ រូប ដែលគ្រោងនឹងប្រឡងបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០២៣។

**- មណ្ឌលសិក្សាបច្ចេកទេសធនាគារ**

មណ្ឌលសិក្សាបច្ចេកទេសធនាគារ បានដើរតួនាទីយ៉ាងសកម្មក្នុងការកសាងមូលធនមនុស្សផ្នែកជំនាញបច្ចេកទេសធនាគារ សម្រាប់បម្រើការអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារនៅកម្ពុជា។

បច្ចុប្បន្ន មណ្ឌលសិក្សាបច្ចេកទេសធនាគារ មាននិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារបាននិងកំពុងសិក្សាចំនួន ២៨០រូប (ស្រី២០៧រូប ប្រុស៧៣រូប) ក្នុងនោះមាននិស្សិតជំនាន់ទី៣២ ចំនួន ១៤៨រូប (ស្រី១០៥រូប) និងនិស្សិតជំនាន់ទី៣១ ចំនួន ១៣២រូប (ស្រី ១០៥រូប)។ ចំណែកឯ និស្សិតជំនាន់ទី៣០ មានចំនួន ១៤០រូប បានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២៣ និងនិស្សិតជំនាន់ទី៣១ ចំនួន ១៣២រូប ទើបបានប្រឡងបញ្ចប់។

ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាឆ្លើយតបនឹងយន្តការការងារនិងគោលនយោបាយអភិវឌ្ឍមូលធនមនុស្សក្នុងបរិបទសេដ្ឋកិច្ច-សង្គមឌីជីថលមណ្ឌលសិក្សាកំពុងសហការជាមួយវិទ្យាស្ថាន Louis Bachelier នៃប្រទេសបារាំងអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារទៅថ្នាក់បរិញ្ញាបត្រ ឬថ្នាក់សមមូល។ សៀវភៅសិក្សាថ្នាក់ប្រកាសនីយបត្របច្ចេកទេសធនាគារជាន់ខ្ពស់ក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មចំនួន ៣០មុខវិជ្ជា ហើយសៀវភៅមុខវិជ្ជា Digital Banking ដែលជាមុខវិជ្ជាថ្មីសម្រាប់ដាក់ក្នុងកម្មវិធីសិក្សាឆ្នាំទី១ ឆមាសទី២ ផងដែរ។

ក្រៅពីនេះ មណ្ឌលសិក្សាបានសហការជាមួយដៃគូយុទ្ធសាស្ត្រ ដូចជា សមាគមមីក្រូហិរញ្ញវត្ថុ (CMA) សមាគមធនាគារនៅកម្ពុជា (ABC) និងគ្រឹះស្ថានធនាគាររៀបចំវគ្គសិក្សាជំនាញខ្លីៗសម្រាប់មន្ត្រីជំនាញ នាយកគ្រប់គ្រងសាខា និងរៀបចំសិក្ខាសាលាសម្រាប់ភាគទុនិក សមាជិកក្រុមប្រឹក្សាភិបាល និង CEO របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។

## តារាង ២៖ ស្ថិតិសាស្ត្រាចារ្យនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២៣

| បរិយាយ | ជំនាន់ទី៣១ | | | ជំនាន់ទី៣២ | | | |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | សរុបរួម |
| បរិញ្ញាបត្រ | ១ | ១ | ២ | ០ | ៣ | ៣ | ៥ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ២៥ | ៧ | ៣២ | ២៧ | ៦ | ៣៣ | ៦៥ |
| បណ្ឌិត | ១ | ០ | ១ | ១ | ០ | ១ | ២ |
| សរុប | ២៧ | ៨ | ៣៥ | ២៨ | ៩ | ៣៧ | ៧២ |
| សរុបជំនាន់ទី៣១ និង៣២ | ៧២ រូប (ប្រុស ៥៥រូប, ស្រី ១៧រូប) | | | | | | |






## តារាង ៣៖ ស្ថិតិនិស្សិតនៅមណ្ឌលសិក្សាបច្ចេកទេសធនាគារឆ្នាំ២០២៣

| បរិយាយ | ជំនាន់ទី៣១ | | | ជំនាន់ទី៣២ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | **សរុប** | ប្រុស | ស្រី | **សរុប** |
| វគ្គសិក្សាទី៥៨ និង៥៩ | ៣១ | ១០៧ | **១៣៨** | ៤៣ | ១០៧ | **១៥០** |
| **និស្សិតជំនាន់ទី៣១ និងទី៣២** | សរុប ២៨៨ រូប (ស្រី ២១៤ រូប, ប្រុស ៧៤ រូប) | | | | | |

**ក្រាហ្វ ១១០៖ ស្ថិតិនិស្សិតមណ្ឌលសិក្សា**

(ឆ្នាំ២០១៨-២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **ការងារបណ្តុះបណ្តាលក្រៅប្រទេស**

មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាត្រូវបានចាត់បញ្ជូនឱ្យចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ចំនួន ២៨៦ លើក (មន្ត្រី-បុគ្គលិកចូលរួម ៧១៣ រូប) វគ្គសិក្សារយៈពេលខ្លី តាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ១៩៣ លើក (មន្ត្រី-បុគ្គលិកចូលរួម ៨០០ រូប) និងវគ្គសិក្សារយៈពេលវែងថ្នាក់អនុបណ្ឌិត ២៣ លើក (មន្ត្រី-បុគ្គលិកចូលរួមចំនួន ២៣ រូប)។ បច្ចុប្បន្ន មន្ត្រីបុគ្គលិកកំពុងសិក្សានៅក្រៅប្រទេសថ្នាក់បរិញ្ញាបត្រមានចំនួន ២ រូប អនុបណ្ឌិត ៥៣ រូប និងបណ្ឌិត ២ រូប។

ជារួមសកម្មភាពបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសបានកើនឡើងបន្តបន្ទាប់តាមរយៈកម្មវិធីបណ្តុះបណ្តាលដែលត្រូវបានធ្វើឡើងតាមប្រព័ន្ធ Hybrid ផង និងដោយផ្ទាល់ផង។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យផ្ទៃក្នុង ធនាគារជាតិនៃកម្ពុជាបន្តអនុវត្តការងារសវនកម្មនិងអធិការកិច្ចទៅតាមផែនការ សំដៅលើកកម្ពស់ការប្រតិបត្តិតាមបទប្បញ្ញត្តិ សេចក្តីណែនាំ និងនីតិវិធីការងារ ជាពិសេសដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អនិងការគ្រប់គ្រងហានិភ័យនៅធនាគារជាតិនៃកម្ពុជា។

នៅក្នុងឆ្នាំ២០២៣ ការធ្វើសវនកម្មផ្ទៃក្នុងនៅស្នាក់ការកណ្តាលត្រូវបានអនុវត្តលើការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ការងារដឹកជញ្ជូនធនប័ត្រ និងការងារគ្រប់គ្រងគណនី ហើយនៅសាខារាជធានី-ខេត្ត បានអនុវត្តលើគ្រប់ប្រតិបត្តិការធនាគារស្នូលនៅខេត្តចំនួន៦ (ខេត្តកណ្តាល កំពង់ស្ពឺ ព្រះសីហនុ

បាត់ដំបង ព្រៃវែង និងរតនគីរី)។ ទន្ទឹមនេះ ការតាមដានការអនុវត្តតាមអនុសាសន៍ត្រូវបានអនុវត្តលើសវនដ្ឋានដែលត្រូវបានធ្វើសវនកម្មកាលពីឆ្នាំកន្លងទៅ រួមមាន នាយកដ្ឋានចំនួន៣ និងសាខារាជធានី-ខេត្តចំនួន៩ (ខេត្តស្វាយរៀង សៀមរាប កំពង់ធំ ពោធិ៍សាត់ កំពត ក្រចេះ តាកែវ កំពង់ចាម និងបន្ទាយមានជ័យ)។ លើសពីនេះ ការងារអធិការកិច្ចត្រូវបានអនុវត្តនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ចំនួន១៩ និងលើការពិនិត្យការបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែក។

នៅក្នុងការអនុវត្តការងារសវនកម្មនិងអធិការកិច្ច ធនាគារជាតិនៃកម្ពុជាតែងតែរៀបចំផែនការសវនកម្មនិងអធិការកិច្ចសម្រាប់អនុវត្តប្រចាំឆ្នាំ។

ចំពោះការងារគ្រប់គ្រងហានិភ័យ គណៈកម្មការគ្រប់គ្រងហានិភ័យប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជាបានប្រជុំចំនួន ៤លើក ដើម្បីពិភាក្សាអំពីការបិទបញ្ជីប្រចាំឆ្នាំ២០២២ ការធ្វើបច្ចុប្បន្នកម្មអ្នកប្រើប្រាស់ប្រព័ន្ធធនាគារស្នូល ការពិនិត្យនិងកែសម្រួលទម្រង់របាយការណ៍នៅក្នុងប្រព័ន្ធធនាគារស្នូលសម្រាប់សាខារាជធានី-ខេត្ត និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារស្នូល។

ក្នុងក្របខ័ណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំប្រធានសវនករផ្ទៃក្នុងធនាគារកណ្ដាលអាស៊ានប្រចាំឆ្នាំលើកទី៨ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៦-២៧ ខែតុលា ឆ្នាំ២០២៣ នៅខេត្តសៀមរាប។







## ៤- សាខាធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការនៅតាមបណ្ដាសាខាត្រូវបានលើកកម្ពស់ ដើម្បីគ្រប់គ្រងចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ សំដៅគាំទ្រការរីកចម្រើនសេដ្ឋកិច្ចក្នុងតំបន់។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំង១៩ បន្តផ្តល់សេវាគ្រប់គ្រងគណនី ទទួល បើកប្រាក់ និងផ្ទេរប្រាក់ជូនដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាល។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តក៏បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមរយៈការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក ជូនសាធារណជន ព្រមទាំងផ្តល់ព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុដល់សាធារណជនតាមប្រព័ន្ធ Hotline ផងដែរ។ ក្រៅពីនេះ គ្រប់បណ្តាសាខារាជធានី-ខេត្តបានចូលរួមបំពេញការងារមួយចំនួនទៀតដែលរួមមាន៖ ការសហការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និងការចូលរួមតាមដានការប្រែប្រួលថ្លៃ អត្រាប្តូរប្រាក់ និងសូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀតដែលរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ចជារួមនៅក្នុងបណ្តាខេត្តនីមួយៗ។





## ៥- សន្និដ្ឋាន

ការពង្រឹងអភិបាលកិច្ច និងការអភិវឌ្ឍធនធានមនុស្ស គឺជាការងារអាទិភាពសម្រាប់ការរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា។ ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចត្រូវបានបន្តពង្រឹង ដើម្បីបន្តធានាបានអភិបាលកិច្ចល្អ។ ចំនួនមន្ត្រី-បុគ្គលិក និងសមត្ថភាពបានកើនឡើងជាលំដាប់ស្របតាមបរិការណ៍នៃការរីកចម្រើននៃវិស័យធនាគារ។ វគ្គបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេសត្រូវបានរៀបចំឡើង ហើយការសិក្សាតាមប្រព័ន្ធអនឡាញលើជំនាញសំខាន់ៗក៏ត្រូវបានលើកកម្ពស់ផងដែរ។ លើសពីនេះ មណ្ឌលសិក្សាបច្ចេកទេសធនាគារ ក៏បានបន្តរួមចំណែកអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធនាគារយ៉ាងសកម្ម។

## IX- ការងារផ្សព្វផ្សាយសាធារណៈ

### ១- ការផ្សព្វផ្សាយពីសារៈសំខាន់នៃប្រាក់រៀល

សកម្មភាពបញ្ជ្រាបចំណេះដឹង អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀលត្រូវបានបន្តលើកកម្ពស់ឱ្យកាន់តែទូលំទូលាយ។ នៅឆ្នាំ២០២៣ កម្មវិធីផ្សព្វផ្សាយស្តីពី ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន ៣ រួមមាន កំពង់ស្ពឺ ព្រះសីហនុ និងកំពង់ធំ ដោយមានវត្តមានចូលរួមពីមន្ត្រីរាជការ តំណាងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សិស្សានុសិស្ស និងសាធារណជនទូទៅ។ កម្មវិធីផ្សព្វផ្សាយនេះបានទាក់ទាញសាធារណជនយ៉ាងច្រើនកុះករ ដោយចំនួនអ្នកចូលរួមសរុបមានរហូតដល់ជាង ១៣ ពាន់នាក់ និងអ្នកទស្សនាការផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាមានជាង ៤០ ពាន់នាក់។ កម្មវិធីផ្សព្វផ្សាយនេះមានសកម្មភាពសំខាន់ៗ ដូចជា៖ ជួយប្តូរក្រដាសប្រាក់រៀលចាស់ ទក់ ឬ រហែកជាមួយក្រដាសប្រាក់រៀលថ្មី ពិព័រណ៍ស្តីពីប្រព័ន្ធរូបិយវត្ថុកម្ពុជាតាំងពីសតវត្សរ៍ទី ១ នៃអាណាចក្រហ្វូណនរហូតដល់បច្ចុប្បន្ន ការតាំងបង្ហាញប្រព័ន្ធទូទាត់បាគង និងការផ្សព្វផ្សាយផលិតផលនិងសេវាហិរញ្ញវត្ថុជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ក្នុងអំឡុងពេលផ្សព្វផ្សាយនោះ សាធារណជនបានយកក្រដាសប្រាក់រៀលចាស់ ទក់ រហែក សរុបប្រមាណ ១,២ ប៊ីលានរៀល មកប្តូរយកក្រដាសប្រាក់រៀលថ្មី។ លើសពីនេះ សាធារណជនបានបើកគណនីបាគង និងគណនីតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុយ៉ាងច្រើន ព្រមទាំងទទួលបានសារអប់រំបណ្តុះគំនិតឱ្យកាន់តែស្រលាញ់ និងប្រើប្រាស់ប្រាក់រៀលថែមទៀត។ ការរៀបចំទិវាប្រាក់រៀលបានបង្ហាញពីការយកចិត្តទុកដាក់របស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជារដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល សំដៅពង្រឹងអធិបតេយ្យភាព សេដ្ឋកិច្ច និងរូបិយវត្ថុ អត្តសញ្ញាណជាតិ និងអត្ថប្រយោជន៍ដ៏ច្រើនពីការប្រើប្រាស់ប្រាក់រៀល។



ធនាគារជាតិនៃកម្ពុជា សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានផ្សព្វផ្សាយសៀវភៅ ស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច"។ សៀវភៅនេះគឺជាលទ្ធផលនៃការសិក្សារួមគ្នាលើបញ្ហាដុល្លារូបនីយកម្មរវាងធនាគារជាតិនៃកម្ពុជា និង JICA ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ និងបានរួមចំណែកលើកកម្ពស់ការយល់ដឹងពីកម្រិតដុល្លារូបនីយកម្មនៅកម្ពុជា ដោយបានវិភាគយ៉ាងលម្អិតនូវទម្រង់និងយន្តការនៃចរាចរូបិយប័ណ្ណក្នុងគ្រប់អង្គភាព រួមមាន គ្រួសារ ក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុ ជាដើម ដោយប្រើប្រាស់ទិន្នន័យអង្កេតមីក្រូ។



## ២- ការអនុវត្តការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

### ក- ការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ។ គម្រោងនេះមានគោលដៅបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅពីថ្នាក់ទី១ ដល់ទី១២ ដែលក្នុងនោះ រួមមាន៖ ការរៀបចំនូវក្របខ័ណ្ឌអប់រំ សេចក្តីព្រាងលទ្ធផលសិក្សាលើគ្រប់មុខវិជ្ជាពាក់ព័ន្ធ ការកំណត់និងរៀបចំប្រធានបទសិក្សា និងការរៀបចំសៀវភៅណែនាំសម្រាប់គ្រូបង្រៀននិងសៀវភៅមេរៀនសម្រាប់សិស្ស។ ក្រុមការងារទាំងពីរភាគីបានបញ្ចប់ការរៀបចំក្របខ័ណ្ឌអប់រំផ្នែកហិរញ្ញវត្ថុ សេចក្តីព្រាងលទ្ធផលសិក្សាលើគ្រប់មុខវិជ្ជាពាក់ព័ន្ធ ការកំណត់និងរៀបចំប្រធានបទសិក្សាពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ បច្ចុប្បន្ន ខ្លឹមសារមេរៀននៃសៀវភៅណែនាំសម្រាប់គ្រូ និងសៀវភៅមេរៀនសម្រាប់សិស្សក្នុងកម្រិតសិក្សាថ្នាក់ទី៤ និងថ្នាក់ទី៧ ត្រូវបានក្រុមការងារនៃភាគីទាំងពីរ បានពិនិត្យ និងរៀបចំរួចរាល់ហើយ។ មេរៀនសម្រាប់ថ្នាក់ទី៤រួមមាន៖ គណិតវិទ្យា សិក្សាសង្គម និងបំណិនជីវិតតាមមូលដ្ឋាន ហើយមេរៀនសម្រាប់ថ្នាក់ទី៧ រួមមាន៖ គណិតវិទ្យា បំណិនជីវិតតាមមូលដ្ឋាន គេហសេដ្ឋកិច្ចវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា។ ដោយឡែក ចំពោះការរៀបចំខ្លឹមសារមេរៀនសម្រាប់កម្រិតសិក្សាថ្នាក់ផ្សេងទៀត ក្រុមការងារនៃភាគីទាំងពីរគ្រោងនឹងអនុវត្តក្នុងដំណាក់កាលទី៣ នៃគម្រោង។

### ខ- ការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី

ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បានសហការអនុវត្តលើអនុស្សរណៈយោគយល់ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី" ដែលមានទិសដៅបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុទៅកាន់គ្រូបង្គោលដែលជាស្ត្រីនៅតាមសាលារៀន និងសហគមន៍ ដើម្បីអាចឱ្យគ្រូបង្គោលដែលត្រូវបានជ្រើសរើស មានសមត្ថភាពគ្រប់គ្រាន់ចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុបន្តនៅក្នុងមូលដ្ឋានរបស់ខ្លួន។ បន្ថែមពីនេះ ភាគីទាំងពីរក៏បានសហការគ្នារៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងវេទិកាសាធារណៈសម្រាប់ស្ត្រី សហគ្រិនជាស្ត្រី និងសិស្សសាកលវិទ្យាល័យដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ប្រភេទសេវាហិរញ្ញវត្ថុឌីជីថល និងការការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាដើម។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី កំពុងសិក្សាលើការរៀបចំអនុស្សរណៈយោគយល់ ដែលផ្តល់លទ្ធភាពដល់ការកំណត់ផែនការសកម្មភាព និងកិច្ចសហការក្នុងការបន្តលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី។



### គ- យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ"





ធនាគារជាតិនៃកម្ពុជា និងអង្គការ Good Return បានសហការអនុវត្តយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ" នៅក្នុងឆ្នាំ២០១៦។ ក្នុងឆ្នាំ២០២៣ ភាគីទាំងពីរបាននិងកំពុងអនុវត្តយុទ្ធនាការ "តោះ! និយាយពីលុយ" ជំហានទី២ ដោយផ្តោតលើការបណ្តុះបណ្តាលគ្រូបង្គោលពីសមាគម CWPD ដើម្បីផ្សព្វផ្សាយបន្តដល់កម្មករ និងកម្មការិនីរោងចក្រ (ភាគច្រើនជាកម្មការិនី) ដែលប្រធានបទក្នុងវគ្គបណ្តុះបណ្តាលផ្តោតលើ៖ ១/-ការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុឌីជីថលតាមរយៈការការពារព័ត៌មានផ្ទាល់ខ្លួនក្នុងការប្រើប្រាស់សេវាឌីជីថល និងការប្រើប្រាស់កម្មវិធីទូរស័ព្ទ "បញ្ជីលុយខ្ញុំ" សម្រាប់គ្រប់គ្រង និងកត់ត្រារាល់ចំណូល-ចំណាយ ២/-ការសន្សំ ៣/-ការជំរុញការពិភាក្សា និងសម្រេចចិត្តផ្នែកហិរញ្ញវត្ថុរវាងបុរសនិងស្ត្រីក្នុងគ្រួសារ និង ៤/-ការលើកកម្ពស់ចំណេះដឹង និងទំនុកចិត្តមកលើសេវាហិរញ្ញវត្ថុផ្លូវការ។ ទន្ទឹមនេះ ការបណ្តុះបណ្តាលដល់កម្មករ និងកម្មការិនីរោងចក្រ ត្រូវបានអនុវត្តតាមរយៈវិធីសាស្រ្តចម្រុះ ដូចជា៖ ១/-ការផ្សព្វផ្សាយវីដេអូអប់រំខ្លីចំនួន ៤ វគ្គ ២/-កម្មវិធី

ផ្សព្វផ្សាយតាមវិទ្យុដែលចាក់ផ្សាយក្នុងរោងចក្រ ៣/-ការបណ្តុះបណ្តាលដោយផ្ទាល់នៅតាមរោងចក្រ និង ៤/-ការផ្សព្វផ្សាយនៅតាមបណ្តាញសង្គម។ បន្ថែមពីនេះ ក្នុងឆ្នាំ២០២៣ វគ្គបណ្តុះបណ្តាលដោយផ្ទាល់ ត្រូវបានរៀបចំឡើងចំនួន ១៦ លើក នៅរាជធានីភ្នំពេញ កណ្តាល កំពង់ស្ពឺ កំពង់ចាម តាកែវ កោះកុង និងសៀមរាប ដែលមានកម្មករនិងកម្មការិនីរោងចក្រ ចូលរួមសរុបប្រមាណ ១.០០០ នាក់។

### ឃ- ការងាររៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា"

ធនាគារជាតិនៃកម្ពុជាបានបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅតាមបណ្តាខេត្ត និងក្រុង/ស្រុកនានា ក្នុងទិសដៅបន្តពង្រឹងចំណេះដឹងពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ និងធានាឱ្យមានការរីកចម្រើនប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងកិច្ចការពារអត្ថប្រយោជន៍ជូនអ្នកប្រើ-ប្រាស់។ សម្រាប់ឆ្នាំ២០២៣ សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ថ្នាក់ស្រុក ត្រូវបានរៀបចំចំនួន ៤ លើក នៅស្រុកចំការលើនៃខេត្តកំពង់ចាម ស្រុកថ្មគោលនៃខេត្តបាត់ដំបង ស្រុកព្រះនេត្រព្រះនៃខេត្តបន្ទាយមានជ័យ និងស្រុកសន្ទុកនៃខេត្តកំពង់ធំ និងថ្នាក់ខេត្តចំនួន ២ លើក នៅខេត្តកំពង់ធំ និងសៀមរាប។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជាអាចប្រមូលជាធាតុចូលសំខាន់ៗជាច្រើនដែលជាប្រយោជន៍សម្រាប់បន្តអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន។






## ខ- គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍"

ធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានផ្តួចផ្តើមគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ដោយមានការចូលរួមសហការពី អង្គការ CFRISE+SPTF អង្គការ Appui au Développement Autonome (ADA) សមាគមធនាគារនៅកម្ពុជា និងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី ក្នុងគោលដៅពង្រឹងសុវត្ថិភាពក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនៅតាមសហគមន៍ ដែលស្របទៅនឹងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលដំបូង គម្រោងនេះគ្រោងនឹងអនុវត្តសាកល្បងនៅក្នុងឃុំចំនួន ៤ ក្នុងខេត្តកំពង់ធំ កំពង់ស្ពឺ ស្វាយរៀង និងបាត់ដំបង ដោយផ្តោតសំខាន់លើការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ បង្កើនភាពអង់អាចរបស់អ្នកប្រើប្រាស់ និងពង្រឹងកិច្ចការពារអតិថិជន។ យុទ្ធសាស្ត្រក្នុងការអនុវត្តគម្រោងនេះ រួមមាន៖ ១/-លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកិច្ចការពារអតិថិជន ២/-ពង្រឹងភាពជាដៃគូតាមរយៈការកៀរគរធនធាន និងការចូលរួមពីរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ៣/-ជំរុញការអភិវឌ្ឍក្បួន និងឧបករណ៍នានាសម្រាប់ការអនុវត្តគម្រោង និងលើកកម្ពស់គុណភាពនៃគម្រោង ៤/-ចងក្រងឯកសារភស្តុតាងស្រាវជ្រាវ និងអនុវត្តមេរៀនបទពិសោធន៍ល្អៗ ឆ្ពោះទៅរកការពង្រីកវិសាលភាពនៃគម្រោង និង ៥/-ពង្រឹងយន្តការដឹកនាំ គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធនានា។ ក្នុងដំណាក់កាលដំបូង ក្រុមការងារអនុវត្តគម្រោងបានបញ្ចប់នូវ ១/-ការសម្ភាសជាមួយប្រជាពលរដ្ឋដើម្បីស្វែងយល់ពីកម្រិតនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុនិងបញ្ហាប្រឈមពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ២/-សិក្ខាសាលា និងកិច្ចពិភាក្សាជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៣/-ការកំណត់យុទ្ធសាស្ត្រក្នុងការអនុវត្តគម្រោង ៤/-សិក្ខាសាលាពិគ្រោះយោបល់ចំនួន ៤ ជាមួយអាជ្ញាធរមូលដ្ឋាន និងជនបង្គោលនៅក្នុងឃុំចំនួន ៤ ដែលត្រូវបានជ្រើសរើសសម្រាប់ការសាកល្បង ៥/-ការរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ ថ្ងៃ នៅធនាគារជាតិនៃកម្ពុជា ជូនជនបង្គោលចំនួន ៥៦រូប មកពីឃុំចំនួន ៤ ក្រោមប្រធានបទ "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ភាពអង់អាច និងកិច្ចការពារអតិថិជន" ៦/-រៀបចំខ្លឹមសារមេរៀនចំនួន ៥ និង ៧/-រៀបចំវគ្គបណ្តុះបណ្តាលដោយផ្ទាល់ចំនួន ២ដង ក្នុងមួយឃុំ លើប្រធានបទចំនួន ២ ដោយមានអ្នកចូលរួមសរុបចំនួន ១.៩១៣ នាក់។



### ច- ការអភិវឌ្ឍផែនទីមគ្គុទ្ទេសក៍ ស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ឆ្នាំ២០២៤-២០២៨

ធនាគារជាតិនៃកម្ពុជា ក្រោមជំនួយរបស់សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI) បាននិងកំពុងអភិវឌ្ឍផែនទីចង្អុលផ្លូវស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ឆ្នាំ២០២៣-២០២៨ សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងគោលដៅកំណត់ក្របខ័ណ្ឌលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថលដែលមានសារៈសំខាន់ក្នុងការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការបង្កើនការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការប្រកបដោយបរិយាបន្ននិងចីរភាព។ ផែនទីមគ្គុទ្ទេសក៍នេះនឹងចូលរួមពង្រឹងសុខុមាលភាពផ្នែកហិរញ្ញវត្ថុសម្រាប់ប្រជាជនកម្ពុជា ដោយជួយឱ្យពួកគាត់មានការយល់ដឹង ចំណេះជំនាញ ភាពជឿជាក់ និងសមត្ថភាពក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនិងមានសុវត្ថិភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់មន្ត្រីធនាគារជាតិនៃកម្ពុជាក្នុងការធានានូវការអនុវត្តក្របខ័ណ្ឌនៃកិច្ចការពារអតិថិជនឱ្យមានប្រសិទ្ធភាព និងជួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការធានាឱ្យបាននូវការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ ផែនទីមគ្គុទ្ទេសក៍នេះបានកំណត់នូវគោលដៅនិងផែនការសកម្មភាពជាក់លាក់ដោយមានទិសដៅអនុវត្តចំពោះស្ត្រី យុវវ័យ មនុស្សពេញវ័យ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធនាគារជាតិនៃកម្ពុជាអាចផ្តួចផ្តើម និងសហការជាមួយភាគីពាក់ព័ន្ធនានាក្នុងការអនុវត្តកម្មវិធី ដែលនឹងជួយលើក-កម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថល ពង្រឹងសមត្ថភាពផ្នែកហិរញ្ញវត្ថុ និងធានានូវសុខុមាលភាពផ្នែកហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់។

## ៣- ការអនុវត្តតាមទីផ្សារ និងយន្តការនៃកិច្ចការពារអ្នកប្រើប្រាស់

### ក- ការពង្រឹងយន្តការសម្របសម្រួលដោះស្រាយបណ្តឹងអតិថិជន

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តពង្រឹងយន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងអតិថិជនតាមរយៈការសម្របសម្រួលដោះស្រាយបណ្តឹងរបស់អតិថិជន ដែលប្រើប្រាស់សេវារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈលេខទូរស័ព្ទហាតឡាញ (Hotline) របស់ធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាលចំនួន ៥ ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តចំនួន ២១ ខ្សែ) ឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា និងមានសង្គតិភាព ដើម្បីធានាពីកិច្ចការពារអតិថិជន។ ក្នុងឆ្នាំ២០២៣ បណ្តឹង និងការសាកសួរព័ត៌មានសរុប មានចំនួន ៥៤១ ករណី ដែលក្នុងនោះ ៥២៩ ករណីបានដោះស្រាយរួចរាល់ ៦ ករណី កំពុងដោះស្រាយ និង ៦ ករណីស្ថិតក្នុងនីតិវិធីតុលាការ។ បណ្តឹងភាគច្រើនពាក់ព័ន្ធនឹង៖ ១/-ការស្នើសុំបង់ផ្តាច់ឥណទានមុនកាលកំណត់ និងដកទ្រព្យធានា ២/-ការស្នើសុំកែប្រែព័ត៌មាន ឬលុបឈ្មោះចេញពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ៣/-ការស្នើសុំការអនុគ្រោះផ្សេងៗ ៤/-ការស្នើសុំលើកលែងប្រាក់ពិន័យ ៥/-ការមិនអាចដកប្រាក់បញ្ញើ ៦/-ការប្រើប្រាស់កម្ចីក្រៅផ្លូវការ និងការឆបោកតាមប្រព័ន្ធឌីជីថល និង ៧/-ការសាកសួរព័ត៌មានផ្សេងៗអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាដើម។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តពង្រឹងកិច្ចការពារអតិថិជនក្នុងប្រព័ន្ធធនាគារនៅកម្ពុជាជាប់ជាប្រចាំតាមរយៈយន្តការ គំនិតផ្តួចផ្តើម និងកិច្ចសហប្រតិបត្តិការដូចខាងក្រោម៖

- ការពង្រឹងយន្តការគ្រប់គ្រងរបាយការណ៍ហាតឡាញរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា និងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងហាតឡាញរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាការពង្រឹងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហាតឡាញធនាគារជាតិនៃកម្ពុជា តាមរយៈការរៀបចំវគ្គចែករំលែកចំណេះដឹង និងការរៀបចំឯកសារជំនួយស្មារតីសម្រាប់មន្ត្រីទទួលបន្ទុកហាតឡាញ

- ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន តាមរយៈការធ្វើបច្ចុប្បន្នកម្មប្រកាសស្តីពីការដោះស្រាយបណ្តឹងអតិថិជន ឱ្យស្របតាមច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់ និងការរីកចម្រើននៃប្រព័ន្ធធនាគារនៅកម្ពុជា និង

- ការចូលរួមទប់ស្កាត់ការផ្តល់ឥណទានខុសច្បាប់ និងការផ្សព្វផ្សាយនានាក្នុងការផ្តល់សេវាហិរញ្ញវត្ថុដោយគ្មានច្បាប់អនុញ្ញាត តាមរយៈសេចក្តីថ្លែងការណ៍រួមរវាងធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការនគរបាលជាតិ ក្នុងការចាត់វិធានការតឹងរ៉ឹងតាមផ្លូវច្បាប់ដល់ការផ្តល់ឥណទានខុសច្បាប់ និងការផ្សព្វផ្សាយនានាក្នុងការផ្តល់សេវាហិរញ្ញវត្ថុដោយគ្មានច្បាប់អនុញ្ញាត។

### ខ- ការបង្កើតស្តង់ដារកិច្ចសន្យាឥណទាន និងខចែងស្តង់ដារនៃកិច្ចសន្យាឥណទាន

ធនាគារជាតិនៃកម្ពុជាបានគាំទ្រនិងចូលរួមជាមួយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងការបង្កើតស្តង់ដារកិច្ចសន្យាឥណទាន និងការកំណត់ខចែងស្តង់ដារនៃកិច្ចសន្យាឥណទាន ដែលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសិទ្ធិនិងប្រយោជន៍របស់អតិថិជន និងផ្តល់ការប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពគ្នា។ ការប្រើប្រាស់ស្តង់ដារកិច្ចសន្យាឥណទាន និងខចែងស្តង់ដារនៃកិច្ចសន្យាឥណទានដែលមានតម្លាភាពនិងសមភាព នឹងអនុញ្ញាតឱ្យអ្នកខ្ចីប្រាក់អាចងាយស្រួលយល់ច្បាស់ពីលក្ខខណ្ឌចម្បងៗ ដើម្បីអាចប្រៀបធៀបនិងជ្រើសរើសសេវាឥណទានរបស់គ្រឹះស្ថានណាមួយ។

### គ- សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

ធនាគារជាតិនៃកម្ពុជាតែងតែគាំទ្រដល់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ចំពោះគំនិតផ្តួចផ្តើមនិងសកម្មភាពនានាដែលចូលរួមលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ននិងចីរភាព។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានអនុញ្ញាតឱ្យគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា អាចប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដូចជា៖ ឯកសារគន្លឹះ វីដេអូអប់រំ ឬពាក្យស្លោក សម្រាប់សមាគម និងគ្រឹះស្ថានដែលជាសមាជិកអាចធ្វើការផ្សព្វផ្សាយបន្តនៅក្នុងសិក្ខាសាលា យុទ្ធនាការ និងកម្មវិធីនានារបស់គណៈ-កម្មាធិការ ក៏ដូចជាសមាគម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា តាមរយៈសមាគម តែងតែជំរុញនិងលើកទឹកចិត្តឱ្យគ្រប់គ្រឹះស្ថានដែលជាសមាជិក បន្តចូលរួមក្នុងសកម្មភាពបរិយាបន្នហិរញ្ញវត្ថុ ការលើក-កម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការអនុវត្តតាមទីផ្សារនិងកិច្ចការពារអតិថិជន ព្រមទាំងបន្តរួមចំណែកក្នុងដំណើរការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយចីរភាព។ បន្ថែមពីនេះ មន្ត្រីធនាគារជាតិនៃកម្ពុជាតែងតែជួបប្រជុំប្រចាំត្រីមាសជាមួយសមាជិកគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីពិភាក្សាលើវឌ្ឍនភាព សមិទ្ធផលការងារ បញ្ហាប្រឈម និងផែនការសកម្មភាពរបស់គណៈកម្មាធិការ។

### ឃ- ការគាំទ្រដល់សភាយុវជន

ធនាគារជាតិនៃកម្ពុជាបានគាំទ្រដល់សភាយុវជន (Youth Assembly) នៃសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តស្វាយរៀង លើគំនិតផ្តួចផ្តើមក្នុងការអនុវត្តគម្រោង "រៀនពីលុយ" ចាប់ពីឆ្នាំ២០២២ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់យុវជន តាមរយៈការជំរុញការយល់ដឹងអំពីការគ្រប់គ្រងលុយ និងការរៀបចំផែនការហិរញ្ញវត្ថុសម្រាប់ពេលអនាគត ជាដើម។ ក្នុងដំណាក់កាលទី១ មន្ត្រីជំនាញធនាគារជាតិនៃកម្ពុជាបានចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សា និងគណៈកម្មការវាយតម្លៃចំពោះកម្មវិធីប្រកួតប្រជែងរបស់យុវជនក្រោមប្រធានបទ ស្តីពី "យុវជន និងអក្ខរកម្មហិរញ្ញវត្ថុ" ផងដែរ។ នៅឆ្នាំ២០២៣ សភាយុវជនបាននិងកំពុងអនុវត្តគម្រោង "រៀនពី

លុយ ២.០" ដែលជាដំណាក់ទី២ ដើម្បីបន្តចូលរួមលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់យុវជន តាមរយៈការចុះបង្រៀននិងផ្សព្វផ្សាយចំណេះដឹង ស្តីពី ហិរញ្ញវត្ថុផ្ទាល់ខ្លួនជូនដល់សិស្សានុសិស្ស ថ្នាក់ទី១០ នៅតាមវិទ្យាល័យរដ្ឋចំនួន ៥ ក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តស្វាយរៀង។ ក្នុងដំណាក់កាលទី២ ធនាគារជាតិនៃកម្ពុជានៅបន្តគាំទ្រដល់កម្មវិធីចែករំលែកចំណេះដឹង ស្តីពី ហិរញ្ញវត្ថុផ្ទាល់ខ្លួននៃគម្រោង "រៀនពីលុយ ២.០" ដោយចូលរួមផ្តល់យោបល់ក្នុងខ្លឹមសារមេរៀន និងចុះបង្រៀននិងផ្សព្វផ្សាយជាមួយក្រុមការងារសភាយុវជននៅតាមវិទ្យាល័យគោលដៅទាំង ៥។

## ៤- ប្រព័ន្ធបាគង

នៅឆ្នាំ២០២៣ ក្រុមការងារបាគងនៃធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តអនុវត្តគម្រោងនិងកម្មវិធីមួយចំនួនដូចជា៖



ក្រុមការងារប្រព័ន្ធបាគង [illegible]

i)- បទបង្ហាញអំពីប្រព័ន្ធបាគង KHQR ជាមួយគ្រឹះស្ថានសាធារណៈ និងឯកជន តាមរយៈការចុះបង្រៀនដោយផ្ទាល់ និងផ្សព្វផ្សាយនូវចំណេះដឹងស្តីពី អត្ថប្រយោជន៍នៃប្រព័ន្ធបាគង ការធ្វើប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់តាមខេអេចឃ្យូអរកូត ជូនមន្ត្រីបុគ្គលិក សាស្ត្រាចារ្យ សិស្ស និស្សិត នៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនក្នុងរាជធានីភ្នំពេញ (សាលាភូមិន្ទរដ្ឋបាល សាកលវិទ្យាល័យជាតិគ្រប់គ្រង ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងសាកលវិទ្យាល័យផ្សេងទៀត) ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងបណ្តាខេត្តផ្សេងទៀត។

ii)- ការផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រព័ន្ធបាគង KHQR ក្រុមការងារបាគងបាននិងកំពុងបន្តអនុវត្តគម្រោង ដើម្បីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់សងប្រាក់របស់សាធារណជន តាមរយៈការចូលរួមរៀបចំដាក់ស្តង់បាគងក្នុងព្រឹត្តិការណ៍ ឬកម្មវិធីជាអាទិ៍មានដូចជាកម្មវិធីការប្រកួតប្រជែងរ៉ូបូតរត់តាមខ្សែឧបសគ្គ ការសហការជាមួយសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជារៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ការចូលរួមផ្សព្វផ្សាយ និងពន្យល់ពីការប្រើប្រាស់ KHQR នៅក្នុងទិវាសន្សំអាស៊ាន ព្រមទាំងនៅតាម



ក្រុមការងារបាគង ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី ប្រាក់រៀល ចំណេះដឹងហិរញ្ញវត្ថុ និងប្រព័ន្ធបាគង

ទីផ្សារក្នុងទីរួមខេត្តកំពង់ធំ ការចូលរួមក្នុងកម្មវិធីសន្និសីទស្តីពី ការជំរុញអភិបាលកិច្ច និងបច្ចេកវិទ្យាឌីជីថលក្រោមប្រធានបទ ការជំរុញបរិវត្តកម្មឌីជីថលនៅក្នុងវិស័យសាធារណៈ ក្នុងបរិវេណបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា កម្មវិធីផ្សព្វផ្សាយស្តីពីប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ការសហការរៀបចំនិងចូលរួមវេទិកា "Inclusive FINTECH Forum" នៅទីក្រុង Kigali ប្រទេស Rwanda និងបណ្តាកម្មវិធីផ្សេងទៀត។ ក្រុមការងារក៏បានចុះអនុវត្តគម្រោងផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រព័ន្ធបាគង KHQR តាមទីប្រជុំជន និងទីផ្សារដល់សាធារណជន និងអាជីវករទទួលបានចំណេះដឹងបន្ថែមក្នុងការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឈានទៅរកការទូទាត់ក្នុងប្រព័ន្ធអេកូឡូស៊ី (Payment Ecosystem)។

iii)- ការអនុវត្តគម្រោង ការចូលរួមជួយកិច្ចការសង្គម និងរួមចំណែកក្នុងការលើកកម្ពស់ចំណេះដឹងទូទៅសុខុមាលភាពជូនដល់កូនសិស្សប្រជាពលរដ្ឋនៅតាមទីជនបទ ដោយលើកកម្ពស់ការអប់រំនៅតាមជនបទ ដូចជា៖ បានចូលរួមក្នុងកម្មវិធីសុខភាពភ្នែក ដែលផ្តល់ការពិនិត្យ និង ព្យាបាលឥតគិតថ្លៃ ជូនប្រជាពលរដ្ឋមកពីខេត្តកំពង់ធំ ដែលមានជំងឺភ្នែកឡើងបាយ និងកន្ទុយថ្លែន ដោយមានការសហការពីមូលនិធិចក្ខុខ្មែរ ការចូលរួមក្នុងកម្មវិធីសុខភាពភ្នែកដែលផ្តល់ការពិនិត្យ និងព្យាបាលឥតគិតថ្លៃ ជូនប្រជាពលរដ្ឋមកពីបណ្តាខេត្ត ការសហការជាមួយក្រុមគ្រូពេទ្យមនុស្សធម៌មកពីប្រទេសអូស្ត្រាលី តាមរយៈអង្គការ Australian Health Humanitarian Aid (AHHA) មូលនិធិចក្ខុខ្មែរ និងមូលនិធិរក្សាកុមារ (Raksa Koma Foundation) ដើម្បីពិនិត្យ និងព្យាបាលអ្នកជំងឺភ្នែកឡើងបាយ ដោយឥតគិតថ្លៃ ជូនប្រជាពលរដ្ឋមកពីខេត្តកំពង់ធំ ការចូលរួមការលើកកម្ពស់ការអប់រំជនបទ នៅសាលាបឋមរង្វាន់ ខេត្តបន្ទាយមានជ័យ និងកម្មវិធីជួយកិច្ចការសង្គមផ្សេងទៀត។



[illegible]



ក្រុមការងារបានចូលរួមក្នុងការលើកកម្ពស់ ការអប់រំជនបទ នៅសាលាបឋមរង្វាន់ ខេត្តបន្ទាយមានជ័យ

## ៥- សារមន្ទីរព្រះស្រីឰសានវរ្ម័ន

សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឰសានវរ្ម័ន (ស.ស.រ) ត្រូវបានចាប់ផ្តើមកសាងឡើង បន្ទាប់ពីទទួលបានអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩ ក្នុងគោលបំណងបង្ហាញជូនសាធារណជនជាតិនិងអន្តរជាតិពីប្រវត្តិសេដ្ឋកិច្ចនិងរូបិយវត្ថុរបស់កម្ពុជា។ ការកសាងសារមន្ទីរនេះបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការស្វែងយល់ពីប្រវត្តិរឿងរ៉ាវនៃសេដ្ឋកិច្ចនិងរូបិយវត្ថុខ្មែរ ដែលមិនសូវមានឯកសារប្រវត្តិសាស្ត្របានលើកយកមកបង្ហាញឱ្យបានក្បោះក្បាយ។ អគារសារមន្ទីរនេះ ស្ថិតនៅចំកណ្តាលរាជធានីភ្នំពេញដែលត្រូវបានជួសជុលកែលម្អឡើងវិញលើសំណង់សល់ពីសម័យអាណាព្យាបាលបារាំង ហើយទីតាំងនេះក៏ធ្លាប់ជាអតីតសាលារាជធានីភ្នំពេញ ដែលសព្វថ្ងៃស្ថិតនៅអគារលេខ១៩ ផ្លូវលេខ១០៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

នាឆ្នាំ២០២៣ សារមន្ទីរ ស.ស.រ បានទទួលភ្ញៀវចូលមកទស្សនាសរុបចំនួន ៣៩.២៧១នាក់ ដែលក្នុងនោះមានភ្ញៀវអន្តរជាតិ ១៣% និងភ្ញៀវជាសិស្ស-និស្សិត ៥២%។ ចំនួនភ្ញៀវទស្សនាបានកើនឡើង ១៨៩% ធៀបនឹងឆ្នាំ២០២២។ ជាមួយគ្នានេះ សារមន្ទីរបានដាក់តាំងពិព័រណ៍មិនអចិន្ត្រៃយ៍ ក្រោមប្រធានបទ «ព្រះរាជទស្សនកិច្ចទៅកាន់ប្រទេសបារាំងរបស់ព្រះបាទ ស៊ីសុវត្ថិ» ដោយទទួលបានភ្ញៀវចូលមកទស្សនាសរុបចំនួន ១២.០០០នាក់។ សារមន្ទីរបានបន្តពង្រីកបន្ថែម និងកែលម្អខ្លឹមសារនៃពិព័រណ៍ ស្តីអំពីសម័យឯករាជ្យ សម័យសាធារណរដ្ឋខ្មែរ និងសម័យខ្មែរក្រហម ដែលការងារនេះនឹងឈានទៅសម្រេចនៅឆ្នាំ២០២៤ខាងមុខនេះ។

បន្ថែមពីលើការងារបដិសណ្ឋារកិច្ច និងទទួលភ្ញៀវមកទស្សនា សារមន្ទីរ ស.ស.រ បានចូលរួមរៀបចំពិព័រណ៍ក្នុងព្រះរាជពិធី ច្រត់ព្រះនង្គ័ល នៅខេត្តកំពង់ធំ ដោយមានការយាងទតពី **ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបានរៀបចំក្នុងកម្មវិធីពិព័រណ៍សៀវភៅនៅខេត្តសៀមរាប ចំនួន ១លើក និងនៅរាជធានីភ្នំពេញ ចំនួន ៣លើក ដើម្បីចូលរួមចំណែកក្នុងការជំរុញវិស័យនៃការអាន និងការសរសេរនៅប្រទេសកម្ពុជា។ សារមន្ទីរ ស.ស.រ បានបោះផ្សាយសៀវភៅចំនួន ២ ប្រភេទ៖ i/- សៀវភៅស្តីពី "ព្រះករុណា ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះរាជដំណើរ ទៅក្រុងបារាំងសែស " របស់ អ្នកឧកញ៉ា វាំង ជួន និង ii/- សៀវភៅកាតាឡុកនៃពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពី "ព្រះរាជទស្សនកិច្ចទៅកាន់ប្រទេសបារាំងរបស់ព្រះបាទ ស៊ីសុវត្ថិ៖ គ្រាដំបូងនៃការស្វែងយល់ចិត្តគ្នា រវាងខ្មែរនិងបារាំង"។ សារមន្ទីរក៏បានរៀបចំសិក្ខាសាលាដែលមានវាគ្មិនជាអ្នកប្រវត្តិសាស្ត្រជូនដល់សាធារណជនទូទៅផងដែរ។

សារមន្ទីរ ស.ស.រ បានពង្រឹងទំនាក់ទំនងជាមួយស្ថាប័នក្រៅប្រទេសដូចជា៖ វិទ្យាស្ថានបោះប្រាក់នៃទីក្រុងប៉ារីស និងបណ្តាសារមន្ទីរធនាគារនិងរូបិយវត្ថុ តាមរយៈកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មាធិការសារមន្ទីររូបិយវត្ថុរបស់ក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរ (ICOM) នៅទីក្រុងក្វាឡាឡាំពួរ ដែលអ្នកចូលរួមជាតំណាងពីសារមន្ទីរ និងស្ថាប័នមកពីជាង២០ប្រទេស។ បន្ថែមពីនេះ សារមន្ទីរក៏បានធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយតាមរយៈបណ្តាញសង្គម និងតាមរយៈការទំនាក់ទំនងជាមួយសារព័ត៌មានជាតិ-អន្តរជាតិ។

**ក្រាហ្វ១១៖ ចំនួនភ្ញៀវទស្សនាសរុប**

(ឆ្នាំ២០១៩ - ឆ្នាំ២០២៣)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា









## ៦- សន្និដ្ឋាន

ការងារផ្សព្វផ្សាយសាធារណៈជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការពង្រឹងជំនឿទុកចិត្ត កិច្ចសហការ និងការគាំទ្ររបស់សាធារណជននិងស្ថាប័នពាក់ព័ន្ធ មកលើការអនុវត្តគោលនយោបាយនិងវិធានការដែលត្រូវបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។ ក្នុងទិសដៅនេះ កម្មវិធីផ្សព្វផ្សាយ សិក្ខាសាលា និងការតាំងពិព័រណ៍ពាក់ព័ន្ធនឹងការលើកកម្ពស់ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ប្រព័ន្ធបាគង ត្រូវបានរៀបចំនិងពង្រឹងជាប្រចាំទាំងនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។ ជាមួយគ្នានេះ សារមន្ទីរព្រះស្រីល្បសានវង្កែ បានដើរតួនាទីកាន់តែសកម្មក្នុងការផ្ដល់ចំណេះដឹងប្រវត្តិសាស្ត្រនៃសេដ្ឋកិច្ចនិងរូបិយវត្ថុ ដែលបានរួមចំណែកបង្កើនការយល់ដឹងរបស់សាធារណជនទៅលើសារៈសំខាន់នៃរូបិយវត្ថុជាតិ ក៏ដូចជាចំណេះដឹងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សេចក្តីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាបន្តងើបឡើងខ្ពស់ជាងឆ្នាំមុនបន្តិច បើទោះជាបានរងផលប៉ះពាល់ពីការថមថយកំណើនសេដ្ឋកិច្ចពិភពលោកក៏ដោយ។ អតិផរណាបានថយចុះមកកម្រិតក្រោម ៣% វិញ ជាមួយនឹងស្ថិរភាពអត្រាប្តូរប្រាក់ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ទុនបម្រុងអន្តរជាតិបានកើនឡើងវិញនិងរក្សាបានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានបម្រើដល់ការអនុវត្តនយោបាយអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាព និងពង្រឹងជំនឿទុកចិត្តវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ និងមានវឌ្ឍនភាពជាលំដាប់ ដែលបានដើរតួនាទីស្នូលមួយក្នុងការគាំទ្រការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ច តាមរយៈការកៀរគរប្រភពទុន ទាំងក្នុងស្រុកនិងក្រៅស្រុកមកផ្តល់តម្រូវការហិរញ្ញប្បទាន និងការបន្ធូរបន្ថយបទប្បញ្ញត្តិប្រុងប្រយ័ត្ន សម្រាប់គាំទ្រវិស័យចម្បងៗនៃសេដ្ឋកិច្ច បើទោះជាអត្រាកំណើនឥណទានបានថមថយក៏ដោយ។ ការត្រួតពិនិត្យបទប្បញ្ញត្តិ និងកិច្ចការពារអតិថិជន ត្រូវបានពង្រឹង ទន្ទឹមនឹងការលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុជាប្រចាំ។ ម្យ៉ាងទៀត ការអភិវឌ្ឍប្រព័ន្ធទូទាត់បានលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ ជាពិសេសតាមប្រព័ន្ធអេឡិចត្រូនិក ស្របតាមគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល ដែលបានជំរុញប្រតិបត្តិការដោះដូរនិងផ្ទេរប្រាក់នៅក្នុងស្រុក និងគាំទ្រដល់ការប្រើប្រាស់ប្រាក់រៀល។ លើសពីនេះ កម្ពុជាក៏បានតភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ ដែលបានសម្រួលនិងគាំទ្រដល់ការរីកចម្រើននៃពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍។ ជាមួយគ្នានេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានរួមចំណែកយ៉ាងសកម្មក្នុងការបំពេញតាមលក្ខខណ្ឌចាំបាច់នានា រហូតសម្រេចបានជោគជ័យក្នុងការដកកម្ពុជាចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ហើយកំពុងបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

កិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី ត្រូវបានបន្តពង្រឹង ដែលបានលើកកម្ពស់សមាហរណកម្មនិងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ នៅក្នុងតំបន់និងពិភពលោក ក៏ដូចជាការជំរុញបរិយាបន្នហិរញ្ញវត្ថុ សេដ្ឋកិច្ចឌីជីថល និងហិរញ្ញប្បទានបៃតង។ ធនាគារជាតិនៃកម្ពុជាក៏បានអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងអភិបាលកិច្ចល្អ ដែលបានលើកកម្ពស់ប្រសិទ្ធភាពការងារ និងលើកមុខមាត់កម្ពុជានៅលើឆាកអន្តរជាតិផងដែរ។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆ្នាំ២០២៤

## ទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០២៤

សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងបន្តថយល្បឿនបន្តិចថែមទៀតក្នុងអត្រាកំណើន ២,៩% នៅឆ្នាំ២០២៤ ធៀបនឹង ៣% នាឆ្នាំ២០២៣ ដែលក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍នឹងថមថយមក ១,៤% ពី ១,៥% ខណៈដែលសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍នឹងរក្សាកំណើន ៤% ហើយសេដ្ឋកិច្ចប្រទេសអាស៊ាន-៥ រំពឹងកើនដល់ ៤,៥% ពី ៤,២%។ ទន្ទឹមនេះ សេដ្ឋកិច្ចពិភពលោកអាចប្រឈមនឹងហានិភ័យចម្បងៗ ដែលអាចបន្ទាបកំណើន ដែលរួមមាន៖ i/-ភាពតានតឹងភូមិសាស្ត្រនយោបាយ ដូចជា ការបន្តអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការរីកសាយនៃសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ា ដែលអាចប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងតម្លៃប្រេងឥន្ធនៈ ii/-ការថមថយកំណើនសេដ្ឋកិច្ចចិន ដែលនាំឱ្យមានឥទ្ធិពលអវិជ្ជមានដល់ការវិនិយោគ ពាណិជ្ជកម្ម និងទេសចរដល់ប្រទេសដទៃទៀត iii/-ការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត ដែលធ្វើឱ្យអត្រាការប្រាក់មានកម្រិតខ្ពស់ ដែលបន្ថយកំណើនការប្រើប្រាស់និងការវិនិយោគ iv/-ការកើនឡើងបំណុលសាធារណៈនិងឯកជន ដែលជាផលវិបាកដក់សល់ពីវិបត្តិកូវីដ-១៩ ស្របពេលដែលអត្រាការប្រាក់លើទីផ្សារមានកម្រិតខ្ពស់ v/-ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចដែលរាំងស្ទះដល់លំហូរពាណិជ្ជកម្មនិងវិនិយោគ និង vi/-ការប្រែប្រួលអាកាសធាតុ។

**ហានិភ័យនិងបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោក**



## កំណើនសេដ្ឋកិច្ចពិភពលោក តំបន់ និងបណ្ដាប្រទេសមួយចំនួន[១]

| | ពិភពលោក | ប្រទេសអភិវឌ្ឍន៍ | ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ | អាមេរិក | តំបន់អឺរ៉ូ | ចក្រភពអង់គ្លេស | ចិន[២] | អាស៊ាន-៥[៣] |
|---|---|---|---|---|---|---|---|---|
| ២០២៤ | ២,៩ ▼ | ១,៤ ▼ | ៤ | ១,៥ ▼ | ១,២ ▲ | ០,៦ ▲ | ៤,៦ ▼ | ៤,៥ ▲ |
| ២០២៣ | ៣ | ១,៥ | ៤ | ២,១ | ០,៧ | ០,៥ | ៥,៤ | ៤,២ |

ចំពោះកម្ពុជា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០២៤ រំពឹងថានឹងសម្រេចបានក្នុងអត្រា ៦,៤% ដែលគាំទ្រដោយចម្បងដោយការបន្តរក្សាបានកំណើនខ្ពស់នៃវិស័យទេសចរណ៍ កម្មន្តសាលមិនមែនកាត់ដេរ និងកសិកម្ម។ វិស័យទេសចរណ៍ត្រូវបានរំពឹងថានឹងបន្តមានកំណើនខ្ពស់ ១៩,៥% ដោយសារការបន្តកើនឡើងនៃការតភ្ជាប់ជើងហោះហើរមកកម្ពុជា ការងើបឡើងនៃវិស័យទេសចរណ៍ក្នុងតំបន់ និងការដាក់ចេញនូវគោលនយោបាយគាំទ្របន្ថែមរបស់រាជរដ្ឋាភិបាល ដូចជា កម្មវិធី "ទស្សនាសៀមរាបឆ្នាំ២០២៤" ជាដើម។ ការបន្តរក្សាបានកំណើនខ្ពស់នៃវិស័យទេសចរណ៍នឹងផ្ដល់ផលវិជ្ជមានដល់វិស័យសេវាគាំទ្រផ្សេងៗ ដែលបម្រើដល់ទេសចរណ៍ ដូចជា ពាណិជ្ជកម្មលក់ដុំនិងរាយនិងការដឹកជញ្ជូនជាដើម ឱ្យមានវឌ្ឍនភាពល្អប្រសើរ។ ទន្ទឹមនេះ ការងើបឡើងនៃសេដ្ឋកិច្ចប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា និងការផ្ដល់ការលើកទឹកចិត្តដល់ការវិនិយោគផ្នែកកម្មន្តសាល នឹងជំរុញឱ្យអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរបន្តមានកំណើនរឹងមាំក្នុងអត្រា ១៤,២% និងអនុវិស័យកម្មន្តសាលកាត់ដេរកើន ៧,៦%។ វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ជាងមុនបន្តិចក្នុងអត្រា ១,៣% ក្រោមគោលនយោបាយជំរុញរបស់រដ្ឋាភិបាលដើម្បីលើកស្ទួយកសិផល រកទីផ្សារ និងរក្សាលំនឹងថ្លៃផលកសិកម្ម និងការដាក់ពង្រាយមន្ត្រីកសិកម្មឱ្យបានគ្រប់ឃុំ ស្របពេលដែលកម្ពុជាទទួលអំណោយផលពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី។ ដោយឡែក វិស័យសំណង់និងអចលនទ្រព្យដែលបានទទួលរងឥទ្ធិពលពីវិបត្តិកន្លងមក ត្រូវបានព្យាករថានឹងបន្តមានកំណើនទាប ដែលគាំទ្រដោយការបន្តអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធសាធារណៈ គួបផ្សំនឹងការងើបឡើងវិញសន្សឹមៗនៃតម្រូវការក្នុងស្រុក ដែលផ្ដោតលើលំនៅឋានដែលមានតម្លៃសមរម្យ ក្នុងពេលដែលតម្រូវការសំណង់ប្រណីតដែលបម្រើដល់អនិវាសនជនត្រូវបានរំពឹងថានឹងបន្តមានភាពទន់ខ្សោយ។ ជាមួយគ្នានេះ វិស័យធនាគាររំពឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមគាំទ្រកំណើនសេដ្ឋកិច្ច ដោយកំណើនឥណទានរំពឹងថាមានអត្រា ១១%។

---

[១] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក (WEO), IMF, ខែតុលា ឆ្នាំ២០២៣។

[២] របាយការណ៍ Article IV សម្រាប់ប្រទេសចិន, IMF, ខែវិច្ឆិកា ឆ្នាំ២០២៣។

[៣] អាស៊ាន-៥ រួមមាន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម។

អតិផរណានៅឆ្នាំ២០២៤ ត្រូវបានព្យាករថាមានកម្រិត ២,៥% ខ្ពស់ជាងឆ្នាំ២០២៣ (២,១%) ជាចម្បងដោយសារថ្លៃប្រេងនៅពិភពលោកត្រូវបានរំពឹងថានឹងកើនឡើង។ ការព្យាករនេះ ស្ថិតក្រោមការសន្មតៈ i/-ថ្លៃទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈកើនជាមធ្យម ១,២% (នៅឆ្នាំ២០២៣ មានអត្រា -២,៧%) ដោយសារការរំពឹងថាប្រទេសសមាជិក OPEC+ នឹងកាត់បន្ថយការផ្គត់ផ្គង់ប្រមាណ ៣៥០.០០០ បារ៉ែលក្នុងមួយថ្ងៃ នៅឆ្នាំ២០២៤ ធៀបនឹងឆ្នាំ២០២៣, ii/-អតិផរណាម្ហូបអាហារមានកម្រិត ៣,៣% ប្រហាក់ប្រហែលនឹងឆ្នាំ២០២៣ (៣,២%) ដោយសារថ្លៃដើមផលិតកើនឡើង បើទោះជាវិស័យកសិកម្មរំពឹងថាមានកំណើនខ្ពស់ជាងឆ្នាំ២០២៣ និងអតិផរណាម្ហូបអាហារពីប្រទេសនាំចូលសំខាន់ៗរំពឹងថានឹងថយចុះ និង iii/-អតិផរណាស្នូលនឹងកើនដល់ ២,២% (នៅឆ្នាំ២០២៣ មានអត្រា ២%) ដោយសារកំណើនតម្រូវការក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជារំពឹងថានឹងមានកំណើនខ្ពស់ជាងឆ្នាំ២០២៣។

**ក្រាហ្វ ១០៣ ៖ អតិផរណាព្យាករណ៍**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆ្នាំ២០២៤ព)




ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, ព=ព្យាករណ៍

**តារាង ៤ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាតាមវិស័យ**

| | ឆ្នាំ២០២២ | ឆ្នាំ២០២៣ប | ឆ្នាំ២០២៤ព |
|---|---|---|---|
| កសិកម្ម | ០,៣% | ១,១% | ១,៣% |
| ឧស្សាហកម្ម | ៨,៩% | ៦,៧% | ៨,៦% |
| សេវាកម្ម | ៣,៣% | ៦,២% | ៦,៤% |
| **កំណើនផ.ស.ស** | **៥,២%** | **៥,៥%** | **៦,៤%** |

*សម្គាល់ៈ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

**តារាង ៥ ៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា ដោយរាជរដ្ឋាភិបាលនិងស្ថាប័នអន្តរជាតិនានា**

| | ឆ្នាំ២០២៣ប | ឆ្នាំ២០២៤ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៥,៦% | ៦,៦% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៥,៣% | ៦,១% |
| ធនាគារពិភពលោក (WB) | ៥,៤% | ៥,៨% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៥,៣% | ៦% |

*សម្គាល់ៈ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

## ប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេ ក្នុងឆ្នាំ ២០២៤

### ការព្យាករកំណើន ផ.ស.ស.




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ (ខែតុលា ២០២៣)

# កត្តាអំណោយផល ហានិភ័យ និងបញ្ហាប្រឈមចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា

## កត្តាអំណោយផល

### កត្តាខាងក្រៅ

- ការកើនឡើងវិញនៃសកម្មភាពទេសចរណ៍
- ការកើនឡើងការវិនិយោគក្នុងវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងកសិ-ឧស្សាហកម្ម មកកម្ពុជា
- ភាពអំណោយផលពីកិច្ចព្រមព្រៀង RCEP និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី

### កត្តាខាងក្នុង

- ស្ថិរភាពនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងប្រព័ន្ធធនាគារ
- សេដ្ឋកិច្ចមានភាពបើកទូលាយ និងសមាហរណកម្មខ្ពស់
- មានទីតាំងភូមិសាស្ត្រនៅចំកណ្ដាលអាស៊ាន
- កត្តាភាគលាភប្រជាសាស្ត្រ
- វឌ្ឍនភាពល្អនៃប្រព័ន្ធទូទាត់ឌីជីថល

## ហានិភ័យ

### កត្តាខាងក្រៅ

- កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចប្រទេសជាដៃគូសេដ្ឋកិច្ចចម្បងៗ
- ការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិត
- ភាពតានតឹងភូមិសាស្ត្រនយោបាយពិភពលោក
- ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចពិភពលោក
- ការប្រែប្រួលអាកាសធាតុ

### កត្តាខាងក្នុង

- កម្រិតខ្ពស់នៃបំណុលវិស័យឯកជន និងការកើនឡើងនៃឥណទានមិនដំណើរការ
- ការងើបឡើងទន់ខ្សោយនៃវិស័យសំណង់ និងការថយចុះតម្រូវការក្នុងវិស័យអចលនទ្រព្យ
- ទេសចរចូលកម្ពុជាតាមផ្លូវអាកាសនៅមានកម្រិតទាប

## បញ្ហាប្រឈមជារចនាសម្ព័ន្ធ

- ពិពិធកម្មសេដ្ឋកិច្ចនិងការនាំចេញនៅមានសន្ទុះយឺត
- សមត្ថភាពជំនាញ និងផលិតភាពនៅមានកម្រិត
- ថ្លៃដឹកជញ្ជូននិងអគ្គិសនីខ្ពស់
- វិស័យកសិកម្មងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ
- ដុល្លារូបនីយកម្មនៅមានកម្រិតខ្ពស់

ទន្ទឹមនឹងការព្យាករដោយសុទិដ្ឋិនិយមនៃកំណើន សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដែលកត្តាខាងក្រៅរួមមាន i/-កំណើនទាបជាងការរំពឹងទុកនៃសេដ្ឋកិច្ចប្រទេសជាដៃគូសេដ្ឋកិច្ចចម្បងៗរបស់កម្ពុជា ដូចជា ចិន អាមេរិក និងអឺរ៉ុប ដែលអាចប៉ះពាល់ដល់ការវិនិយោគ តម្រូវការសម្រាប់នាំចេញវិស័យទេសចរណ៍ សំណង់ និងអចលនទ្រព្យ ii/-ការបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតត្បិតនៅក្នុងប្រទេសអភិវឌ្ឍន៍ ដែលអាចនាំឱ្យអត្រាការប្រាក់លើទីផ្សារអន្តរជាតិកើនឡើងនិងដាក់សម្ពាធលើអត្រាការប្រាក់នៅកម្ពុជា iii/-ការកើនឡើងនៃភាពតានតឹងនិងការបែងចែកភូមិសាស្ត្រនយោបាយ-សេដ្ឋកិច្ចពិភពលោក ដែលអាចរាំងស្ទះដល់ខ្សែច្រវាក់ផ្គត់ផ្គង់និងដាក់សម្ពាធលើសន្ទុះកំណើនការនាំចេញ និង iv/-ការប្រែប្រួលអាកាសធាតុដែលធ្វើឱ្យវិស័យកសិកម្មមានកំណើនទាប។ ទន្ទឹមនេះ ហានិភ័យខាងក្នុងសេដ្ឋកិច្ចកម្ពុជារួមមាន i/-កម្រិតខ្ពស់នៃបំណុលវិស័យឯកជននិងការកើនឡើងនៃឥណទានមិនដំណើរការ ដែលជាឥទ្ធិពលដក់សល់ពីវិបត្តិកូវីដ-១៩ ii/-ការងើបឡើងទន់ខ្សោយនៃវិស័យសំណង់ និងការថយចុះតម្រូវការក្នុងវិស័យអចលនទ្រព្យ និង iii/-ចំនួនភ្ញៀវទេសចរចូលកម្ពុជាតាមផ្លូវអាកាសនៅមានកម្រិតទាប។ ជាមួយគ្នានេះ កម្ពុជាក៏នៅប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធចម្បងៗ ដូចជា i/-ពិពិធកម្មសេដ្ឋកិច្ចនិងការនាំចេញនៅមានសន្ទុះយឺត ii/-សមត្ថភាពជំនាញ និងផលិតភាពនៅមានកម្រិត iii/-ថ្លៃដឹកជញ្ជូននិងអគ្គិសនីខ្ពស់ធៀបនឹងប្រទេសជាដៃគូប្រកួតប្រជែងសម្រាប់ការនាំចេញ

iv/-វិស័យកសិកម្មមានភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និង v/-ដុល្លារូបនីយកម្មនៅមានកម្រិតខ្ពស់។

ជាមួយនឹងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចតំបន់និងពិភពលោក ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបន្តអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២៤ ដូចខាងក្រោមៈ

## ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយតាមដាននិងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ
- លើកកម្ពស់ការប្រើប្រាស់និងចំណេះដឹងពីប្រាក់រៀល
- កែលម្អ និងពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមាន និងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ
- អភិវឌ្ឍក្របខ័ណ្ឌកូរីដ័រអត្រាការប្រាក់ និងដាក់អនុវត្តអត្រាការប្រាក់គោល
- ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ និង
- លើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុស្តីពី ក្របខ័ណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

## ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- អនុវត្តសេចក្តីណែនាំការវិនិយោគសម្រាប់ឆ្នាំ២០២៤
- សិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យនិងបង្កើនចំណូល
- ពង្រឹងការវាស់វែងសមិទ្ធផលសំពៀតវិនិយោគ តាមរយៈការសិក្សាស្រាវជ្រាវលើម៉ូឌែលថ្មីៗបន្ថែម និង
- សិក្សាពីឱកាស និងលទ្ធភាពពង្រីកការវិនិយោគក្រោមក្របខ័ណ្ឌការវិនិយោគប្រកបដោយការទទួលខុសត្រូវលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ។

## ៣- ប្រព័ន្ធទូទាត់សងប្រាក់

- ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ក្នុងនោះរួមមាន ប្រព័ន្ធទូទាត់រាយនិងប្រព័ន្ធទូទាត់តម្លៃធំ
